EDU/MAN-0150

អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

# សៀវភៅណែនាំ
# ស្តីពី
# ការតាមដាន និងវាយតំលៃរបស់
# កម្មវិធីសិលា

ខែ មេសា ឆ្នាំ ២០០៣



361.25 SEI

បណ្ណាល័យ
គ.ជ.អ.ប

# មាតិកា

**ផ្នែកទី១: សេចក្តីផ្តើម**

**១.១. គោលបំណងរបស់សៀវភៅណែនាំស្តីពីការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា** ........ ១

**១.២.ទំហំនិងការកំណត់នៃសៀវភៅណែនាំ ស្តីពី ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា** ........ ២

**១.៣.រចនាសម្ព័ន្ធរបស់សៀវភៅណែនាំតាមដាននិងវាយតំលៃកម្មវិធីសិលា** ........ ៤

**ផ្នែកទី២: ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលា**

**២.១.ការតាមដាននិងវាយតំលៃ** ........ ១

២.១.១. និយមន័យរបស់ការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា ........ ១

២.១.២. ភាពស្រដៀងគ្នា និងភាពខុសគ្នារវាងការតាមដាន និងវាយតំលៃ ........ ៣

**២.២. លក្ខណៈទូទៅនៃកម្មវិធី** ........ ៦

**២.៣ តារាងតក្កភាពកម្មវិធីសិលា និងការតាមដាននិងវាយតំលៃ** ........ ៧

**២.៤ ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា** ........ ១៣

២.៤.១. ទំនាក់ទំនងរវាងកម្មវិធីសិលា និងប្រព័ន្ធតាមដាន វាយតំលៃរបស់កម្មវិធីសិលា ........ ១៣

២.៤.២. ចំណុចដែលត្រូវពិចារណាសំរាប់បង្កើតប្រព័ន្ធតាមដាននិងវាយតំលៃ ........ ១៤

២.៤.៣. ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃក្នុងកម្មវិធីសិលា ........ ១៥

២.៤.៤ ចំណុចសំខាន់ៗ ដើម្បីបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃក្នុងកម្មវិធីសិលា ........ ១៦

២.៤.៥ សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់ ........ ១៨

**២.៦ ការគាំទ្រលើការបង្កើតប្រព័ន្ធនិងគោលនយោបាយនានា** ........ ២៦

**២.៧ តំរូវការសំរាប់ការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា** ........ ២៧

**ផ្នែកទី៣: ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ**

**៣.១. សេចក្តីផ្តើម** ........ ១

៣.១.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់កម្មវិធីសិលាថ្នាក់ជាតិ ........ ១

៣.១.២ ការអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ជាតិ ........ ២

៣.១.៣ ប្រព័ន្ធនិងគោលការណ៍ណែនាំរបស់រដ្ឋាភិបាលនិងកម្មវិធីសិលា ដែលមានទំនាក់ទងនៅថ្នាក់ជាតិ ........ ២

**៣.២ ការតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ** ........ ៤

NCDD Library
002258
361.25
មេរ
Sh: M&E

៣.២.១. ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃកម្មវិធីសិលា នៅថ្នាក់ជាតិ ..... ៤
៣.២.២. ការប្រមូលទិន្នន័យ និងគ្រប់គ្រងពត៌មាន ..... ១៣
៣.២.៣. ពិនិត្យយ៉ាងហ្មត់ចត់ដើម្បីកែតំរូវសកម្មភាព ..... ១៥
៣.២.៤. ទំនាក់ទំនង និងការសរសេររបាយការណ៍លទ្ធផល ..... ១៥
៣.៣. **តួនាទី និងការទទួលខុសត្រូវ លើការតាមដាននិងវាយតំលៃកម្មវិធីសិលាថ្នាក់ជាតិ** ..... ១៦
៣.៣.១. ក្រសួង និងភ្នាក់ងារឬស្ថាប័នថ្នាក់ជាតិផ្សេងៗទៀត ..... ១៦
៣.៣.២. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ១រួមផ្សេង ..... ១៧
៣.៤. **ការកសាងសមត្ថភាព សំរាប់ការតាមដាននិងវាយតំលៃ នៅថ្នាក់ជាតិ** ..... ២៣

**ផ្នែកទី៤: ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ខេត្ត**

៤.១. **សេចក្តីផ្តើម** ..... ១
៤.១.១. រចនាសម្ព័ន្ធគ្រប់គ្រងរបស់កម្មវិធីសិលាថ្នាក់ខេត្ត ..... ១
៤.១.២. ការអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ខេត្ត ..... ២
៤.១.៣.ប្រព័ន្ធនិងគោលការណ៍ណែនាំផ្សេងៗរបស់រដ្ឋាភិបាល និងកម្មវិធីសិលាដែលមានទំនាក់ទំនងជាមួយខេត្ត ..... ៣
៤.២**ការតាមដាន និងវាយតំលៃរបស់កម្មវិធីសិលាថ្នាក់ខេត្ត** ..... ៤
៤.២.១ ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃនៅថ្នាក់ខេត្ត ..... ៤
៤.២.២. ការប្រមូល និងគ្រប់គ្រងពត៌មាន ..... ១១
៤.២.៣.ធ្វើការផ្ទះបញ្ជាំងរកចំណុចខ្វះខាត ដើម្បីធ្វើការកែលំអសកម្មភាព ..... ១៣
៤.២.៤. ការទំនាក់ទំនង និងរបាយការណ៍លទ្ធផល ..... ១៤
៤.៣. **ការរៀបចំការតាមដាននិងវាយតំលៃលើកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍** ..... ១៤
៤.៣.១ ផែនការសកម្មភាពតាមដាន និងវាយតំលៃ ..... ១៥
៤.៣.២ ការរៀបចំផែនការសកម្មភាពតាមដាននិងវាយតំលៃ ..... ១៦
៤.៣.៣ ការរៀបចំនិងការអនុវត្តន៍ការវាយតំលៃៈការសិក្សាស្រាវជ្រាវឬការពិនិត្យឡើងវិញ ..... ២៣
៤.៣.៤ ការរៀបចំថវិកាសំរាប់ការតាមដាននិងវាយតំលៃ ..... ២៦
៤.៤ **តួនាទីនិងការទទួលខុសត្រូវលើការងារ M&E របស់កម្មវិធីសិលាថ្នាក់ខេត្ត** ..... ២៩
៤.៤.១ ភ្នាក់ងារអនុវត្តន៍ ..... ២៩
៤.៤.២ ផ្នែកគ្រប់គ្រងកិច្ចសន្យា ..... ៣០
៤.៤.៣ ផ្នែករដ្ឋបាលមូលដ្ឋាន ..... ៣២

៤.៤.៤ ផ្នែកគាំទ្របច្ចេកទេស ---------- ៣៣
៤.៤.៥ ផ្នែកហិរញ្ញវត្ថុ ---------- ៣៣
៤.៤.៦ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និង គណៈកម្មាធិការប្រតិបត្តិ ---------- ៣៤
**៤.៥ ការបណ្តុះបណ្តាលលើការតាមដាននិងវាយតំលៃនៅតាមខេត្ត** ---------- ៣៥


## ផ្នែកទី៥: ប្រព័ន្ធតាមដាននិងវាយតំលៃនៅថ្នាក់ខេត្ត


**៥.១. សេចក្តីផ្តើមពីរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ឃុំ** ---------- ១
**៥.២. ការតាមដាននិងវាយតំលៃថ្នាក់ឃុំ** ---------- ២
៥.២.១. ការតាមដាននិងវាយតំលៃថ្នាក់ឃុំដោយអ្នកខាងក្នុង ---------- ២
៥.២.២. ការតាមដាននិងវាយតំលៃថ្នាក់ឃុំ ដោយអ្នកខាងក្រៅ ---------- ៣
**៥.៣. សូចនាករសំរាប់ប្រព័ន្ធតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ** ---------- ៤
**៥.៤. តួនាទី និងការទទួលខុសត្រូវលើការតាមដាននិងវាយតំលៃនៅថ្នាក់ឃុំ** ---------- ៦
**៥.៥. ការប្រមូលទិន្នន័យ និងមធ្យោបាយផ្ទៀងផ្ទាត់** ---------- ៨
**៥.៦. ការប្រមូលនិងការវិភាគទិន្នន័យ ការប្រើប្រាស់ពត៌មាននិងការសរសេររបាយការណ៍** ---------- ១០
៥.៦.១. ប្រព័ន្ធទិន្នន័យឃុំ (CDB) ---------- ១០
៥.៦.២. ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID) ---------- ១២
៥.៦.៣. តារាងកិច្ចការតាមដានសកម្មភាពសំខាន់ៗ ដែលកើតមាននៅក្នុងឃុំ និងប្រព័ន្ធរបាយការណ៍ឃុំ ---------- ១៣
៥.៦.៤. ការអនុវត្តន៍តាមប្រព័ន្ធនានា និងការពិនិត្យឡើងវិញលើប្រព័ន្ធទាំងនោះ ---------- ១៤
៥.៦.៥. ការប៉ាន់ប្រមាណ និងការស្ទាបស្ទង់ ---------- ១៦
**៥.៧. ការគ្រប់គ្រង ការធ្វើផែនការ និងហិរញ្ញវត្ថុសំរាប់ការងារ M&E នៅថ្នាក់ឃុំ** ---------- ១៧
៥.៧.១.ការរៀបចំផែនការតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ ---------- ១៧
៥.៧.២. ហិរញ្ញវត្ថុ និងធនធានសំរាប់តាមដាន និងវាយតំលៃថ្នាក់ឃុំ ---------- ១៨
**៥.៨. ការកសាងសមត្ថភាពសំរាប់ការងារ M&E នៅថ្នាក់ឃុំ** ---------- ១៨
៥.៨.១. ការជ្រើសរើសមន្ត្រីបង្គោល M&E ---------- ១៨
៥.៨.២. ការកសាងមត្ថភាព ---------- ១៩


## ផ្នែកទី៦: ការប្រមូល និងការវិភាគទិន្នន័យ


**៦.១ ការប្រមូលទិន្នន័យ** ---------- ១

៦.១.១. ទិន្នន័យ និងការប្រមូលទិន្នន័យ ............................................................ ១
៦.១.២. ឧទាហរណ៍ នៃវិធីសាស្ត្រប្រមូលទិន្នន័យមួយចំនួន ............................................ ២
៦.១.៣. ការរៀបចំឧបករណ៍ប្រមូលទិន្នន័យ ............................................................ ៦
៦.២. **ការវិភាគទិន្នន័យ** ............................................................ ៨
៦.២.១. ដំណាក់កាលទាំង២ក្នុងការវិភាគទិន្នន័យ ............................................ ៨
៦.២.២. គោលការណ៍ណែនាំទូទៅសំរាប់វិភាគទិន្នន័យ ............................................ ១០
៦.២.៣. ការគ្រប់គ្រប់ពត៌មាន និង ការទុកដាក់ទិន្នន័យ ............................................ ១១
៦.៣. **ប្រព័ន្ធទិន្នន័យនៅក្នុងកម្មវិធីសិលា** ............................................ ១៤
៦.៣.១ ប្រព័ន្ធទិន្នន័យឃុំ ............................................................ ១៤
៦.៣.២ ប្រព័ន្ធទិន្នន័យកិច្ចសន្យារបស់កម្មវិធីសិលា (SCD) ............................................ ១៦
៦.៣.៣ ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID) ............................................ ១៩

**ផ្នែកទី៧: របាយការណ៍ និងការប្រើប្រាស់ពត៌មាន**

**៧.១. សេចក្តីផ្តើម** ............................................................ ១
**៧.២. គោលការណ៍ណែនាំទូទៅសំរាប់សរសេររបាយការណ៍** ............................................ ២
**៧.៣. ការសរសេររបាយការណ៍ក្នុងកម្មវិធីសិលា** ............................................ ៣
៧.៣.១. ភ្នាក់ងារអនុវត្តន៍នៅថ្នាក់ខេត្ត ............................................................ ៥
៧.៣.២. គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ............................................ ៦
៧.៣.៣. ក្រសួង/ភ្នាក់ងារនៅថ្នាក់ជាតិ ............................................................ ៧
៧.៣.៤. គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា STF ............................................ ៨
៧.៣.៥. ភាពញឹញាប់ក្នុងការសរសេររបាយការណ៍លើសូចនាកររបស់កម្មវិធីសិលា ............................................ ៩
**៧.៤. ការប្រើប្រាស់ពត៌មាន និងការធ្វើសេចក្តីសំរេចចិត្ត** ............................................ ១៦

ឧបសម្ព័ន្ធទី១: ............................................................ ១

# សៀវភៅណែនាំ ស្តីពី
# ការតាមដាន និងវាយតំលៃរបស់
# កម្មវិធីសិលា

## ផ្នែកទី១

## សេចក្តីផ្តើម



## ១.១. គោលបំណងរបស់សៀវភៅណែនាំស្តីពីការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា

សៀវភៅណែនាំនេះ បង្ហាញពីប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលា ឆ្នាំ ២០០១-២០០៥។ គោលបំណងនៃសៀវភៅណែនាំនេះ គឺដើម្បីជួយដល់អ្នកទាំងឡាយដែលពាក់ព័ន្ធក្នុងកម្មវិធីសិលា អោយបានយល់ច្បាស់ ថាតើអ្វីទៅ ដែលហៅថាការតាមដាននិងវាយតំលៃ និងថាតើអ្នកដែលពាក់ព័ន្ធ ត្រូវមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះ ក្នុងការអនុវត្តន៍ និងគ្រប់គ្រងកម្មវិធីសិលា តាមថ្នាក់ផ្សេងៗគ្នា ហើយថាតើត្រូវធ្វើការតាមដាននិងវាយតំលៃយ៉ាងដូចម្តេច នៅតាមថ្នាក់នីមួយៗនោះ។

សៀវភៅណែនាំនេះ គឺជាមធ្យោបាយមួយសំរាប់អោយមន្ត្រីកម្មវិធីសិលា ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្តក្រុង[1] ព្រមទាំងអ្នកអនុវត្តកម្មវិធីសិលាទាំងអស់ប្រើប្រាស់។ ទោះបីជាកម្មវិធីសិលា គឺជាកម្មវិធីដ៏ធំមួយ ដែលកំពុងត្រូវបានអនុវត្តនិងសាកល្បងប្រព័ន្ធនិងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ យ៉ាងណាក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើង ដើម្បីធ្វើអោយគំរូបែបបទ របាយការណ៍ ដំណើរការ និងប្រព័ន្ធទាំងនេះ មានលក្ខណៈងាយស្រួលនិងសាមញ្ញបំផុតសំរាប់អ្នកប្រើប្រាស់។ ក្រៅពីការតាមដាន និងវាយតំលៃលើសកម្មភាព លទ្ធផលរំពឹងទុក និងហិរញ្ញវត្ថុ ការដកស្រង់បទពិសោធន៍ជាច្រើន ការវិភាគលើគោលនយោបាយ ការសន្ទនា និងការរៀបចំឯកសារក៏ជាផ្នែកមួយនៃសកម្មភាពរបស់កម្មវិធីសិលាផងដែរ។

សៀវភៅណែនាំ ស្តីពីប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា មិនមែនត្រូវបានបង្កើតឡើងនិងអនុវត្តតែឯកឯងនោះទេ។ វាគឺជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រង និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជានិងរបស់កម្មវិធីសិលាដែលត្រូវបានប្រើប្រាស់ ដើម្បីអនុវត្តសកម្មភាពរបស់កម្មវិធីសិលា អោយសំរេចបានគោលដៅនិងទិសដៅរបស់កម្មវិធី។ ប្រព័ន្ធនិងគោលការណ៍ណែនាំសំខាន់ៗបំផុតរបស់កម្មវិធីសិលា គឺមាននៅក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា សៀវភៅណែនាំស្តីពីការគ្រប់គ្រងរដ្ឋបាលកម្មវិធី និងនៅក្នុងសៀវភៅណែនាំ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុកម្មវិធីសិលាផងដែរ។

---

[1] ដើម្បីជាការងាយស្រួលអាន ក្នុងឯកសារនេះ ពាក្យថា " ខេត្ត " និង " ក្រុង " ត្រូវបានប្រើក្នុងឯកសារនេះ ជាពាក្យកាត់សំរាប់ " ខេត្ត ក្រុង " ។ ដូចគ្នានេះដែរ " ស្រុក " ត្រូវបានប្រើជាពាក្យកាត់អោយ " ស្រុក ខណ្ឌ " ហើយ " ឃុំ " ជាពាក្យកាត់អោយ " ឃុំ សង្កាត់ "

ប្រព័ន្ធទិន្នន័យមួយចំនួន ត្រូវបានបង្កើតឡើង ដើម្បីជួយធ្វើការវិភាគ ទុកដាក់ និងរាយការណ៍ពត៌មាន ដើម្បីគាំទ្រដល់ការអនុវត្តន៍កម្មវិធីសិលា។ ប្រព័ន្ធទិន្នន័យមួយចំនួន គឺនៅជាប្រព័ន្ធទិន្នន័យរបស់កម្មវិធីសិលា ដូចជាប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យារបស់កម្មវិធីសិលា ប៉ុន្តែនៅមានប្រព័ន្ធទិន្នន័យផ្សេងទៀត ដូចជាប្រព័ន្ធទិន្នន័យឃុំដែលត្រូវបានដាក់អោយប្រើប្រាស់នៅតាមរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល និងដែលគ្រប់គ្រងដោយនាយកដ្ឋានផែនការនៃក្រសួងផែនការ។ ហើយប្រព័ន្ធទិន្នន័យមួយផ្សេងទៀតគឺប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង(PID)ដែលជំនួសអោយប្រព័ន្ធទិន្នន័យមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន(LDF) ទំនងជានឹងត្រូវដាក់អោយប្រើប្រាស់តាមស្ថាប័នរដ្ឋាភិបាលក្នុងពេលឆាប់ៗខាងមុខនេះ។ អ្នកដែលប្រើប្រាស់ប្រព័ន្ធទិន្នន័យទាំងនេះ ចាំបាច់ត្រូវពិនិត្យមើលលើសៀវភៅណែនាំ សំរាប់ប្រព័ន្ធទិន្នន័យនីមួយៗ។

## ១.២. ទំហំនិងការកំណត់នៃសៀវភៅណែនាំ ស្តីពី ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធី សិលា

សៀវភៅណែនាំ ស្តីពីប្រព័ន្ធតាមដាននិងវាយតំលៃនេះ ត្រូវបានបង្កើតឡើង ដោយផ្អែកជាសំខាន់លើបទពិសោធន៍ សកម្មភាព ប្រព័ន្ធ និងគំរូបែបបទនានាជាច្រើនរបស់កម្មវិធីសិលា ដែលបានអនុវត្តចាប់តាំងពីឆ្នាំ ១៩៩៦មក។ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ប្រព័ន្ធតាមដាននិងវាយតំលៃនេះ ក៏ដូចជាកម្មវិធីសិលាខ្លួនឯង អាចនឹងមានការផ្លាស់ប្តូរជាបន្តទៀត។ ដោយសារតែមានការបង្កើតឡើងថ្មីៗ ដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ ការសំរបសំរួលគោលនយោបាយថ្នាក់ជាតិ និងដោយសារតែការដាក់អោយប្រើប្រាស់បទបញ្ញត្តិនិងគោលការណ៍ណែនាំនានា ដើម្បីអនុវត្តចំនុចខាងលើនេះ វានឹងធ្វើអោយមានការផ្លាស់ប្តូរនៅគ្រប់ថ្នាក់ទាំងអស់។ ហេតុដូចនេះ កម្មវិធីសិលា និងប្រព័ន្ធតាមដាននិងវាយតំលៃរបស់ខ្លួន ចាំបាច់ត្រូវតែធ្វើការពិនិត្យឡើងវិញ និងសំរបសំរួលអោយស្របទៅនឹងការផ្លាស់ប្តូរទាំងនេះ តាមដែលអាចធ្វើទៅបាន។

សៀវភៅណែនាំ ស្តីពីប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលានេះ មិនអាចឆ្លើយបាននូវគ្រប់ចំងល់បានឡើយ។ អ្នកប្រើប្រព័ន្ធនេះ នឹងជួបនូវការខកចិត្ត នៅពេលដែលគេមានអារម្មណ៍ថា សៀវភៅណែនាំបច្ចុប្បន្ននេះ មិនបានពន្យល់គេអោយបានច្បាស់លាស់ និងគ្រប់គ្រាន់ ពីរបៀបដែលត្រូវអនុវត្ត និងគ្រប់គ្រង

សកម្មភាពតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា។ សៀវភៅណែនាំនេះ គឺជាគ្រឹះមួយដ៏សំខាន់ សំរាប់កសាងសកម្មភាពតាមដាននិងវាយតំលៃ ព្រោះថា វាត្រូវបានប្រើប្រាស់នៅក្នុងខេត្ត ក្រសួង និងភ្នាក់ងារថ្នាក់ជាតិផ្សេងៗគ្នា និងរហូតដល់កម្មវិធីខ្លះដែលមានទំនាក់ទំនងនឹងកម្មវិធីសិលា ក៏បានប្រើប្រាស់សៀវភៅនេះដែរ។ នៅពេលដែលប្រព័ន្ធតាមដាននិងវាយតំលៃនេះ ចាប់ផ្តើមអនុវត្ត ឧទាហរណ៍ជាក់លាក់មួយចំនួនស្តីពីការអនុវត្តន៍ការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា នឹងត្រូវបានចងក្រងឡើង ដើម្បីដកស្រង់នូវបទពិសោធន៍ផ្សេងៗនិងយ៉ាងទូលំទូលាយទាំងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ ទោះបីជាការប្រមូលគំរូឧទាហរណ៍នេះ ត្រូវធ្វើឡើងគ្មានទីបញ្ចប់ក៏ដោយ តែទីបំផុត វាអាចជួយអោយយើងធ្វើការពិនិត្យឡើងវិញលើសៀវភៅណែនាំតាមដាននិងវាយតំលៃនេះ និងធ្វើអោយវាកាន់តែមានប្រយោជន៍បន្ថែមទៀត សំរាប់ប្រើប្រាស់ក្នុងពេលអនាគត។

វាទាមទារនូវរយៈពេលមួយ ដើម្បីបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា អោយបានចប់សព្វគ្រប់។ មានមនុស្សជាច្រើនបានចូលរួមក្នុងការអនុវត្តន៍កម្មវិធីសិលា ហើយនៅប៉ុន្មានឆ្នាំខាងមុខទៀត នឹងមានមនុស្សជាច្រើនទៀតដែលត្រូវចូលរួមក្នុងកម្មវិធីនេះ។ រហូតមកដល់ពេលនេះ មានអ្នកខ្លះធ្លាប់បានយល់ដឹងខ្លះៗស្រាប់មកហើយ ពីប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា ប៉ុន្តែក៏នៅមានចំនុចមួយចំនួនទៀតដែលថ្មីសំរាប់ពួកគេ ដែលទាមទារអោយមានការសិក្សានិងអនុវត្តន៍បន្ថែមទៀត។ ទន្ទឹមនឹងនេះ កម្មវិធីសិលា និងប្រព័ន្ធតាមដាននិងវាយតំលៃរបស់វា ហាក់បីដូចជាថ្មីស្រឡាងសំរាប់មនុស្សមួយចំនួនធំទៀត។ ដូចនេះ ចាំបាច់ត្រូវចាប់ផ្តើមការកសាងសមត្ថភាព និងការបណ្តុះបណ្តាលលើគោលដៅនិងទិសដៅ របស់កម្មវិធីសិលា ព្រមទាំងទស្សនទានជាមូលដ្ឋាននិងវិធីសាស្រ្តតាមដាននិងវាយតំលៃសំរាប់អ្នកទាំងនោះ។

ជាការសំខាន់ដែលយើងត្រូវចងចាំអោយច្បាស់ថា ចំនុចសំខាន់ៗមួយចំនួនសំរាប់ការតាមដាននិងវាយតំលៃ គឺៈការសិក្សាស្វែងយល់ ថាតើសំនួរអ្វីខ្លះដែលត្រូវសួរ ត្រូវសួរអ្នកណា និងតើត្រូវប្រមូលពត៌មាន និងទិន្នន័យដែលឆ្លើយតបនឹងសំនួរទាំងនោះនៅទីណា។ ប៉ុន្តែនេះ គឺជារូបភាពត្រឹមតែពាក់កណ្តាល នៃការងារតាមដាននិងវាយតំលៃតែប៉ុណ្ណោះ។ ពត៌មានដែលទទួលបានពីការវិភាគទិន្នន័យ និង បទពិសោធន៍ទាំងឡាយ ត្រូវតែប្រើប្រាស់ផងដែរ ដើម្បីធ្វើអោយប្រសើរឡើងដល់កម្មវិធី និងការអនុវត្តន៍គំរោង និងដើម្បីផ្តល់ពត៌មាន

ដល់ការធ្វើសេចក្តីសំរេចចិត្ត ហើយបន្ទាប់មកទៀត ដើម្បីជួយអ្នកទាំងឡាយនិងស្ថាប័ននានានៅគ្រប់លំដាប់ថ្នាក់ទាំងអស់ អោយកាន់តែមានសមត្ថភាព ក្នុងការ កាត់បន្ថយភាពក្រីក្រ ក្នុងប្រទេសកម្ពុជា។

## ១.៣. រចនាសម្ព័ន្ធរបស់សៀវភៅណែនាំតាមដាននិងវាយតំលៃកម្មវិធីសិលា

សៀវភៅណែនាំនេះ ចែងចែកចេញជា ៧ ផ្នែកធំៗ ។ ផ្នែកបន្ទាប់ពីផ្នែកនេះទៅ គឺផ្នែកទី២ ដែលបកស្រាយពីទស្សនទាន និងគោលការណ៍តាមដាន និងវាយតំលៃក្នុងកម្មវិធីសិលា។ ក្នុងផ្នែកទី២នេះផងដែរក៏មាននិយាយពីនិយមន័យរបស់ពាក្យ តាមដាន និងវាយតំលៃ ទិសដៅនៃប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលា ទំនាក់ទំនងរវាងការតាមដាននិងវាយតំលៃនឹងតារាងតក្កភាពរបស់កម្មវិធីសិលា ព្រមទាំងមានការពិពណ៌នាពីតួនាទីនិងការទទួលខុសត្រូវរបស់អ្នកអនុវត្តន៍ការងារនេះ នៅតាមថ្នាក់ផ្សេងៗគ្នាទាំងអស់។

ដោយសារកម្មវិធីសិលា គឺជាកម្មវិធីដ៏ធំមួយ ដែលគិតត្រឹមខែមីនា ឆ្នាំ ២០០៣នេះ កម្មវិធីបានគ្របដណ្តប់វិសាលភាពទូទាំងប្រទេស ហើយដែលមានការពាក់ព័ន្ធជាមួយមនុស្សជាច្រើន និងត្រូវអនុវត្តនៅតាមថ្នាក់ផ្សេងៗគ្នា ទើបតំរូវអោយមានការបកស្រាយលំអិតពីប្រព័ន្ធតាមដាននិងវាយតំលៃនេះ ផ្សេងៗពីគ្នាទៅសំរាប់ថ្នាក់នីមួយៗផងដែរ។ ផ្នែកទី៣ និងផ្នែកទី៤ បកស្រាយពីប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត។ ក្នុងផ្នែកនីមួយៗ បានបកស្រាយពីរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីសិលាប្រព័ន្ធតាមដាននិងវាយតំលៃ ដោយភ្ជាប់ជាមួយសូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់ តួនាទី និងការទទួលខុសត្រូវ និងការកសាងសមត្ថភាពលើការតាមដាននិងវាយតំលៃ សំរាប់ថ្នាក់នីមួយៗ។

ផ្នែកទី៥ បានបកស្រាយពីប្រព័ន្ធតាមដាននិងវាយតំលៃរបស់ឃុំ។ ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ កាលពីខែកុម្ភៈ ឆ្នាំ ២០០២មក ការអនុវត្តន៍សកម្មភាពអភិវឌ្ឍន៍ និងការផ្តល់សេវាកម្មនៅថ្នាក់នេះត្រូវបានគ្រប់គ្រងដោយបទបញ្ញាតិ និងនីតិវិធីរបស់រដ្ឋាភិបាល គឺមិននៅក្រោមការគ្រប់គ្រងរបស់កម្មវិធីសិលាទេ។ ប៉ុន្តែ ប្រព័ន្ធតាមដាននិងវាយតំលៃឃុំនេះ មិនទាន់បានបង្កើតឡើងចប់សព្វគ្រប់នៅឡើយទេ ហើយគោលបំណងរបស់ផ្នែកនេះគ្រាន់តែជាឯកសារបង្ហែកមួយសំរាប់អោយមន្ត្រីខេត្តអាចជួយបង្កើតប្រព័ន្ធ

តាមដាននិងវាយតំលៃ និងផ្តល់ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំតែប៉ុណ្ណោះ។ សង្ឃឹមថា សៀវភៅក្បួនស្តីពីការតាមដាននិងវាយតំលៃឃុំ ដាច់ដោយឡែកនិងសមស្រប ហើយសាមញ្ញមួយ នឹងត្រូវបានបង្កើតឡើងក្នុងពេលឆាប់ៗខាងមុខ ដើម្បីអោយក្រុមប្រឹក្សាឃុំប្រើប្រាស់។

ផ្នែកចុងក្រោមនៃសៀវភៅណែនាំនេះ គឺផ្នែកទី៦ ដែលនិយាយពីពត៌មានទូទៅ ស្តីពីការប្រមូលទិន្នន័យ និងការវិភាគ ហើយផ្នែកទី៧ និយាយពីការសរសេររបាយការណ៍ និងការប្រើប្រាស់ពត៌មាន។

សៀវភៅណែនាំ ស្ដីពី
ការតាមដាន និងវាយតំលៃរបស់
កម្មវិធីសិលា

# ផ្នែកទី២

# ទស្សនទាន និងគោលការណ៍ នៃ ការតាមដាន និងវាយតំលៃ របស់កម្មវិធីសិលា



# ទស្សនទាន និងគោលការណ៍នានា ស្តីពី
# ការតាមដាន និងវាយតំលៃ របស់កម្មវិធីសិលា

## ២.១.ការតាមដាននិងវាយតំលៃ

### ២.១.១. និយមន័យរបស់ការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា

តើការតាមដាននិងវាយតំលៃមានន័យយ៉ាងដូចម្តេច? រហូតមកដល់ពេលនេះ សំរាប់ការតាមដាន និង វាយតំលៃ នៅមិនទាន់មាននិយមន័យដែលមានលក្ខណៈជាគំរូ និងមានការទទួលស្គាល់ជាសកលនៅឡើយទេ។ ខាងក្រោមនេះ គឺជានិយមន័យដែលកម្មវិធីសិលា កំពុងប្រើ :-

***ការតាមដាន*** គឺជាការប្រមូលពត៌មានយ៉ាងទៀងទាត់ និងទាន់ពេលវេលាពីការរីកចំរើនរបស់កិច្ចសន្យា គំរោង ឬកម្មវិធី ដើម្បីកំណត់ថាតើសកម្មភាពទាំងឡាយ ត្រូវបានអនុវត្តតាមការគ្រោងទុកដែរឬទេ។ ការតាមដាន គឺជាដំណើរការការងារដែលត្រូវអនុវត្តជារៀងរាល់ថ្ងៃ។ ការតាមដាន គឺជាកិច្ចការផ្ទៃក្នុងរបស់កម្មវិធី ហើយពត៌មានដែលទទួលបានពីការតាមដាននេះ សំរាប់ធ្វើសេចក្តីសំរេចចិត្តដើម្បីធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រង និងការអនុវត្តន៍គំរោង ឬកម្មវិធី។

***ការតាមដាន*** គឺជាសកម្មភាពបន្តមួយ ដែលត្រូវបានធ្វើឡើងក្នុងរំឡុងពេលអនុវត្តគំរោង ឬ កម្មវិធី ហើយ វាជាអ្នកប្រមូលពត៌មានទាំងឡាយដោយផ្ទាល់ពីសកម្មភាព និងលទ្ធផលរបស់គំរោង។ វាក៏ជាអ្នកពិនិត្យមើល ថាតើសកម្មភាពត្រូវបានអនុវត្តដូចការគ្រោងទុកដែរឬទេ។ បុគ្គលិកគំរោង ត្រូវអនុវត្តការតាមដាននេះ ជាផ្នែកមួយនៃការងារប្រចាំថ្ងៃរបស់ខ្លួន ហើយប្រើពត៌មានដែលទទួលបានមកនេះ ដើម្បីវាយតំលៃលើការរីកចំរើនរបស់គំរោង និងដើម្បីធ្វើអោយប្រសើរឡើងដល់គុណភាពនៃការអនុវត្តន៍ និង ដើម្បីកែសំរួលគំរោង ឧទាហរណ៍: លទ្ធផលរបស់ការតាមដាន នឹងអាចធ្វើអោយមានការផ្លាស់ប្តូរលើសកម្មភាពកសាងផែនការ ជាដើម។ល។ តែការផ្លាស់ប្តូរអាចធ្វើបាន តែក្នុងករណីចាំបាច់តែប៉ុណ្ណោះ ដូចជាក្នុងករណីដែលបញ្ហា មួយចំនួនត្រូវបានរកឃើញ ឬក៏ដំណើរការអនុវត្តន៍សកម្មភាពមិនបានស្រប

តាមការគ្រោងទុកជាដើម។ ពត៌មានដែលបានពីការតាមដាន ក៏អាចត្រូវបានប្រើជាទុនមួយសំរាប់ការវាយតំលៃផងដែរ។

ដូចនេះ ***ការតាមដាន*** មានគោលបំណង៣ ដូចខាងក្រោម :-

**១. បង្កើនគណនេយ្យភាព**: ការតាមដានអាចជួយបញ្ជាក់ថាតើសកម្មភាពទាំងឡាយ ត្រូវបានអនុវត្តស្របទៅតាមអាណត្តិដែលមាន និងស្របទៅតាមផែនការដែលបានលើកឡើងដែរឬទេ។

**២. កែលំអការគ្រប់គ្រង និងការធ្វើសេចក្តីសំរេចចិត្ត** : ការតាមដាន អាចប្រមូលរាល់ពត៌មានស្តីពីការរីកចំរើនទូទៅ ក្នុងការអនុវត្តន៍កម្មវិធីឬគំរោង ហើយវាក៏អាចប្រមូលពត៌មានស្តីពីបញ្ហាទាំងឡាយដែលបានកើតឡើង ហើយដែលចាំបាច់ត្រូវអោយមានការដោះស្រាយផងដែរ។

**៣.ជំរុញអោយមានការសិក្សាស្វែងយល់** : តាមដានការអនុវត្តន៍កម្មវិធី អាចធ្វើអោយអ្នកដែលពាក់ព័ន្ធនឹងកម្មវិធី យល់បានកាន់តែច្បាស់ពីការងារអ្វីដែលបានអនុវត្តល្អ និងការងារដែលបានអនុវត្តមិនបានល្អ។ ទន្ទឹមនឹងនេះ គេអាចកែសំរួលធ្វើអោយកម្មវិធី មានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ឡើងវិញក្នុងពេលអនាគត ហើយមិនត្រឹមតែប៉ុណ្ណោះ បទពិសោធដែលទទួលបានពីការអនុវត្តន៍កម្មវិធីនេះ អាចត្រូវបានប្រើដើម្បីរៀបចំកម្មវិធីផ្សេងៗទៀត ឬដើម្បីបង្កើតគោលនយោបាយដែលទាក់ទងនឹងកម្មវិធីផងដែរ។

***ការវាយតំលៃ*** គឺជាដំណើរការមួយ ដើម្បីកំណត់ពីផលប៉ះពាល់ និងប្រសិទ្ធភាពរបស់គំរោង ឬកម្មវិធីណាមួយ ដើម្បីប្រើប្រាស់ជាបទពិសោធន៍ ហើយវាជាអ្នកកំណត់ពីសមិទ្ធិផល របស់គោលដៅ និងទិសដៅរបស់កម្មវិធី។ ការវាយតំលៃគំរោង ឬកម្មវិធី គឺជាសកម្មភាពដាច់ដោយឡែកពីគ្នា ដែលត្រូវអនុវត្តនៅកំឡុងពេលជាក់លាក់ណាមួយ ដោយបុគ្គលិកគំរោង ឬកម្មវិធី (ហៅថា ការវាយតំលៃដោយអ្នកខាងក្នុង) ហើយក៏អាចត្រូវបានអនុវត្តដោយអ្នកទាំងឡាយដែលមិនពាក់ព័ន្ធនឹងគំរោង ឬកម្មវិធី (ហៅថា ការវាយតំលៃធ្វើឡើងដោយអ្នកខាងក្រៅ) ឬ ត្រូវធ្វើឡើងដោយរួមគ្នាតែម្តង។

***ការវាយតំលៃ*** គឺត្រូវបានធ្វើឡើងនៅពេលវេលាកំណត់ច្បាស់លាស់មួយ ក្នុងកំឡុងពេលនៃការអនុវត្តន៍គំរោង ឬក្រោយពេលការអនុវត្តន៍ ហើយជារឿយៗ ការវាយតំលៃនេះត្រូវប្រមូលពត៌មាន ដែលមានលក្ខណៈលំអិតជាងការតាមដាន។ ការវាយតំលៃជាអ្នកពិនិត្យមើលថាតើការអនុវត្តន៍សំរេចបានគោលដៅនិងទិសដៅរបស់កម្មវិធី ឬគំរោងដែរឬទេ។ លទ្ធផលនៃការវាយតំលៃត្រូវបានប្រើ ដើម្បីវិនិច្ឆ័យពីផល

ប៉ះពាល់លើប្រជាពលរដ្ឋគោលដៅ កែតំរូវទិសដៅ និងកម្មវិធី ព្រមទាំងដើម្បីសំរេចពីអនាគត របស់កម្មវិធី ឬគំរោង។

## ២.១.២. ភាពស្រដៀងគ្នា និងភាពខុសគ្នារវាងការតាមដាន និងវាយតំលៃ

ជាក់ស្តែងតក្កភាពនៅពីក្រោយការលើកគំរោង គឺតែងតែមានឥទ្ធិពលយ៉ាងខ្លាំងដល់ការកំណត់ថាតើត្រូវធ្វើការតាមដាន និងវាយតំលៃលើចំណុចអ្វីខ្លះ (សូមមើលក្នុងក្រាភិចខាងក្រោម[២])។ ការសំរេចចិត្តអនុវត្តគំរោង ឬប្រើប្រាស់ឱកាសណាមួយ គឺតែងតែភ្ជាប់មកជាមួយនូវបញ្ហាជានិច្ច។ អ្នកអនុវត្តន៍គំរោងព្យាយាមធ្វើអោយសំរេចបានទិសដៅ និងគោលដៅដែលបានកំណត់ ដោយប្រើប្រាស់ធនធានដែលមានសំរាប់អនុវត្តសកម្មភាពចាំបាច់មួយចំនួនដើម្បីសំរេចបានលទ្ធផលរំពឹងទុក ហើយដែលលទ្ធផលរំពឹងទុកនេះឯង នឹងត្រូវចូលរួមធ្វើអោយសំរេចបាននូវផលប៉ះពាល់រំពឹងទុក។




[២] ប្រភព: Woodhill, Jim and Lisa Robins, 1998, Participatory Evaluation for Landcare and Catchment Groups: A Guide for Facilitators, Greening Australia, Yarraluma, Australia

ការតាមដាននិងវាយតំលៃ ជាធម្មតាផ្តោតទៅលើ ៣កំរិត ដូចខាងក្រោម :-

- តាមដានលើ<u>**ធនធាន**</u> ដែលអាចប្រាប់យើងពីធនធានទាំងឡាយដែលត្រូវប្រើប្រាស់ដើម្បីអនុវត្តសកម្មភាព :
  - ហិរញ្ញវត្ថុរបស់គំរោង (ដែលត្រូវចំណាយលើសំភារៈ និងកំលាំងពលកម្ម
  - ពេលវេលា សំភារៈ ឧបករណ៍ និងមូលនិធិដែលចូលរួមដោយសហគមន៍
- តាមដានលើសូចនាករ <u>**លទ្ធផលរំពឹងទុក**</u> ដែលអាចប្រាប់យើងពីការរីកចំរើន និងកំរិតនៃការអនុវត្តន៍សកម្មភាព :
  - តើអ្វីខ្លះដែលបានសាងសង់ ឬដែលបានអនុវត្ត
  - តើគំរោង ត្រូវបានអនុវត្តស្របទៅតាមកាលវិភាគដែរឺទេ
  - ការអង្កេត អារម្មណ៍ និងការយកចិត្តទុកដាក់របស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងគំរោងពីកំរិតនៃការងារដែលបានអនុវត្ត
- សូចនាករ <u>**ផលប៉ះពាល់**</u> ដែលអាចប្រាប់យើងបានថាតើ គំរោងទទួលបានជោគជ័យ ឬមិនបានជោគជ័យ :
  - ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទើបតែធ្វើអោយប្រសើរឡើង ឬថ្មីស្រឡាង ដែលយើងចង់បាន
  - ការអនុវត្តន៍ជំនាញ និងចំណេះដឹង ដែលទទួលបានថ្មីៗ
  - ការផ្លាស់ប្តូរឥរិយាបថ

ជាទូទៅសំនួរសំខាន់មួយចំនួនដែលយើងប្រើក្នុងការតាមដាននិងវាយតំលៃ គឺតែងតែទាក់ទងនឹង ***ភាពសមស្រប*** ឬ ***ការជាប់ពាក់ព័ន្ធ សមត្ថភាព*** និង ***ប្រសិទ្ធភាព*** នៃសកម្មភាពដែលបានអនុវត្ត។

***ភាពសមស្រប ឬការជាប់ពាក់ព័ន្ធ*** *:* តើជាគំនិតល្អដែរឺទេ ដែលត្រូវអនុវត្តគំរោងណាមួយនោះ? តើទិសដៅ និងគោលដៅរបស់គំរោង (ទាក់ទងនឹងតំរូវការរបស់ប្រជាពលរដ្ឋ និងកាលៈទេសៈ ដែលត្រូវអនុវត្តសកម្មភាព) ត្រូវបានជ្រើសរើសត្រឹមត្រូវដែរឺទេ? តើសកម្មភាពដែលបានលើកឡើង សមស្របទៅនឹងធនធាន (ថវិកា និងពេលវេលា) ដែលមានដែរឺទេ?

**ប្រសិទ្ធភាព** : តើគំរោងមានដំណើរការដែរឺទេ? តើគំរោងសំរេចបានទិសដៅ និងគោលដៅរបស់វា ដែល បានលើកឡើងដែរឺទេ? បើសិនជាមិនបានសំរេច តើបណ្តាលមកពីការអនុវត្តន៍គំរោងដ៏ល្អនេះ មិនបានត្រឹម ត្រូវមែនទេ?

**សមត្ថភាព** : តើគំរោងត្រូវបានអនុវត្ត ដោយវិធីសាស្រ្តល្អបំផុតមែនទេ? តើធនធាន ត្រូវបានប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពដែរឺទេ? តើគំរោងនេះ នឹងអាចទទួលបានលទ្ធផលដូចគ្នា ក្នុងរយៈពេលឆាប់ ជាង នេះ ឬដោយប្រើធនធានតិចជាងនេះ ដែរឺទេ?

ការពិចារណាទៅលើភាពសមស្រប ប្រសិទ្ធភាព និងសមត្ថភាព ដូចដែលបានលើកឡើងខាងលើ គឺវាក៍ មានការទាក់ទងផងដែរ ទៅនឹងតារាងតក្កភាពរបស់គំរោង ដូចដែលមានបង្ហាញនៅទំព័របន្ទាប់ ខាង មុខនេះ។

នៅពេលដែលអនុវត្តគំរោង ឬផ្តល់សេវាកម្មអ្វីមួយ ការផ្តោតលើការតាមដានជាដំបូង ត្រូវផ្តោតទៅលើ **ការតាមដានលើធនធាន លទ្ធផល និងសមត្ថភាព**។ តើមានធនធានគ្រប់គ្រាន់ចាំបាច់ ដើម្បីអនុវត្ត សកម្មភាពដែរឺទេ? បើសិនជាមាន តើទទួលបានលទ្ធផល ដូចការគ្រោងទុកដែរឺទេ (ដោយគិតទៅ តាមបរិមាណ គុណភាព និងពេលវេលាដែលយើងគ្រោងទុក)?

ការតាមដាន ត្រូវផ្តោតយ៉ាងស៊ីជំរៅទៅលើលទ្ធផល និងវាយតំលៃពីផលប៉ះពាល់របស់គំរោង នៅពេល ដែលយើងចាប់ផ្តើមរៀបចំរបាយការណ៍ប្រចាំឆ្នាំ ពេលបញ្ចប់គំរោងឬនៅចុងឆ្នាំ។ តើហេដ្ឋារចនាសម្ព័ន្ធ ដែលគំរោងទើបតែបានសាងសង់ថ្មី ត្រូវបានក្រុមជនគោលដៅប្រើប្រាស់ ដោយគ្មានផលលំបាក ដូចតាម ការរំពឹងទុកដែរឺទេ? តើទទួលបានលទ្ធផលពីសេវាកម្មដែលបានផ្តល់ទៅក្រុមជនគោលដៅ ដូចការរំពឹង ទុកដែរឺទេ? តើមានស្ថានភាពផ្លាស់ប្តូរដែរឺទេ បើប្រៀបធៀបទៅនឹង ពេលដែលមិនបានអនុវត្ត ឬផ្តល់ សេវាកម្ម?

មានតែសូចនាករដែលជាគ្រោងឆ្អឹងដ៏សំខាន់របស់ប្រព័ន្ធតាមដាននិងវាយតំលៃទេ ដែលអាចផ្តល់ចំលើយ ទៅនឹងសំនួរខាងលើទាំងនេះបាន។




## ២.២. លក្ខណៈទូទៅនៃកម្មវិធី

កម្មវិធីសិលា គឺជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើអោយប្រសើរឡើង នូវអភិបាលកិច្ចមូលដ្ឋាន។ គោលដៅអភិវឌ្ឍន៍របស់កម្មវិធីសិលា ជំហានបន្ទាប់គឺ " រួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈអភិបាលកិច្ចល្អ "។ ហើយទិសដៅបន្ទាន់ គឺ "រៀបចំបង្កើតប្រព័ន្ធ និងវិធីសាស្រ្តវិមជ្ឈការ ដើម្បីគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ប្រកបដោយចីរភាព "។ ទិសដៅនេះ អាចនឹងសំរេចទៅបានតាមរយៈលទ្ធផលរំពឹងទុក៣ របស់កម្មវិធី គឺ:

១. ស្ថាប័នពាក់ព័ន្ធ នៅគ្រប់លំដាប់ថ្នាក់ ត្រូវបានពង្រឹង និងអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ប្រកបដោយប្រសិទ្ធិភាព។
២. សេវាកម្ម និងការវិនិយោគប្រកបដោយប្រសិទ្ធិភាព និងគុណភាព ត្រូវបានផ្តល់សំរាប់ កិច្ចអភិវឌ្ឍន៍មូលដ្ឋាន។
៣. រួមចំណែកក្នុងការរៀបចំគោលនយោបាយ និងបទបញ្ញត្តិផ្សេងៗ ស្តីពីវិមជ្ឈការ វិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ។

ថ្នាក់ជាតិ ព្រមទាំងខេត្ត និងឃុំជាអ្នកទទួលខុសត្រូវអនុវត្តកម្មវិធីសិលានេះ។ ថ្នាក់ជាតិ កម្មវិធី ផ្តោតទៅលើការកសាង និងការធ្វើអោយប្រសើរឡើងវិញនូវប្រព័ន្ធ និងបទបញ្ញត្តិនានា និងជួយក្នុងការបង្កើតគោលនយោបាយណែនាំផ្សេងៗ ហើយនៅថ្នាក់ក្រោមជាអ្នកធ្វើអោយស្ថាប័នគោលដៅ ប្រកបដោយសមត្ថភាព និងគណនេយ្យភាព និងជាអ្នកជំរុញអោយមានភាពជាដៃគូ ព្រមទាំងការសន្ទនាសំរាប់ស្ថាប័នទាំងនោះផងដែរ។ ក្រៅពីនេះ កម្មវិធីសិលា ក៏បានគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់មូលនិធិវិនិយោគ លើផ្នែកហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ និងដល់ការបង្កើតប្រព័ន្ធមួយដើម្បីធ្វើ អោយប្រសើរឡើងដល់អភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព។ សមាសធាតុសំខាន់ ទី៣របស់កម្មវិធីសិលា គឺការគាំទ្រដល់ការកសាងសមត្ថភាពនៅថ្នាក់ជាតិ ថ្នាក់ខេត្ត ស្រុក និងនៅថ្នាក់ឃុំ។

ពត៌មានលំអិតដ៏ទៃទៀតដែលទាក់ទងទៅនឹងកម្មវិធីសិលា ប្រព័ន្ធគ្រប់គ្រង និងរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធី គឺមាននៅក្នុងឯកសារកម្មវិធីសិលា និងសៀវភៅណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា។

## ២.៣ តារាងតក្កភាពកម្មវិធីសិលា និងការតាមដាននិងវាយតំលៃ

វិធីសាស្រ្តមួយដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់ក្នុងការរៀបចំកម្មវិធី ឬគំរោងនោះ គឺជារបៀបបកស្រាយគំរោងតាមតារាងតក្កភាព (Logical Framework Approach) ។ វិធីសាស្រ្តនេះ គឺបានជួយក្នុងការវិភាគ និងកំណត់ពី **អ្វី** ដែលគំរោង ឬកម្មវិធីចង់ធ្វើអោយសំរេចបាន **ដោយរបៀបណា**។

លទ្ធផល ទទួលបានពីការវិភាគនេះ ជាធម្មតាត្រូវដាក់នៅក្នុងតារាងមួយ ឬក្នុងម៉ាទ្រិក ដែលហៅថា គំរោងម៉ាទ្រិក ឬ **តារាងតក្កភាព** (Logframe)។

កូឡោនតារាងតក្កភាពផ្តល់ពត៌មានសង្ខេបទៅលើ :

- **ឋានានុក្រមទិសដៅ** (Objective Hierarchy): វាបញ្ជាក់ពីអ្វី ដែលគំរោង ឬ កម្មវិធីចង់សំរេចបាន ចាប់ពីគោលដៅរួម រហូតដល់សកម្មភាពជាក់លាក់។ របៀបបកស្រាយ គំរោងតាមតារាងតក្កភាព ផ្អែក ទៅលើ ថាតើធនធានទាំងឡាយដែលបានគ្រោងទុក (ដូចជា លុយ សំភារៈ មនុស្ស ។ល។) មាន គ្រប់គ្រាន់ហើយរឺនៅ " ដែលហៅថា : មធ្យោបាយ-ស្ថានភាពបញ្ចប់ (Means-end logic)" បើសិនជា មានគ្រប់គ្រាន់ហើយនោះ សកម្មភាពមួយចំនួនអាចនឹងចាប់ផ្តើមអនុវត្តបាន។ បើសិនជា ការសន្មត់លើផែនការពិតជាត្រឹមត្រូវ លទ្ធផលរំពឹងទុកមួយចំនួន ពិតជាអាចសំរេចបាន។ បើសិនជា លទ្ធផលទាំងនេះ សំរេចបានហើយនោះ មានន័យថា វាក៏អាចធ្វើអោយទិសដៅរំពឹងទុកមួយចំនួន សំរេចដូចគ្នាដែរ បន្ទាប់មកទៀត ទិសដៅរំពឹងទុកទាំងនេះ នឹងអាចធ្វើអោយសំរេចបាននូវទិសដៅ ទាំងឡាយដែលកាន់តែទំលំទូលាយថែមទៀត។ ឋានានុក្រមទិសដៅរបស់កម្មវិធីសិលា ដូចដែល បានលើកឡើងនៅក្នុងឯកសារ កម្មវិធី គឺមាននៅទំព័របន្ទាប់ ៣។
- **ការអនុវត្តន៍សំខាន់ ឬសូចនាករដែលអាចផ្ទៀងផ្ទាត់បាន** (Key Performance or Verifiable Indicators): សំនួរពីការអនុវត្តន៍ និង/ឬ សូចនាករសំខាន់ៗ ត្រូវបានប្រើដើម្បីតាមដានការ រីកចំរើន និងសមិទ្ធិផលទូទៅរបស់គំរោង ឬកម្មវិធី។
- **មធ្យោបាយផ្ទៀងផ្ទាត់** (Means of Verification): គឺជាយន្តការមួយ ឬជាឧបករណ៍មួយដែល បង្ហាញពីវិធីសាស្រ្តសំរាប់ តាមដានសូចនាករ និងទីកន្លែងដែលអាចប្រមូលពត៌មានបាន។
- **ការសន្មត់និងការប្រថុយផ្សេងៗ**(Assumptions and Risks):ការសន្មត់ទាំងឡាយនឹងខុសពីការពិត បើសិនជាការសន្មត់ពីរបៀបដែលត្រូវអនុវត្តសកម្មភាពរបស់គំរោងខុសរួមផ្សំនឹងការប្រថុយប្រថាន ផ្សេងៗទៀតនោះ។

តារាងតក្កភាពនៃកម្មវិធីសិលា គឺជាទិដ្ឋភាពរួមមួយរបស់កម្មវិធី ដែលបង្កើតបានជាផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់កម្មវិធី។ ដំណើរការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ជួយក្នុងការរៀបចំ យុទ្ធសាស្រ្តកម្មវិធី អោយទៅជាផែនការសកម្មភាពនិងថវិកាប្រតិបត្តិមួយ ដែលមានលក្ខណៈច្បាស់លាស់

[3] ការប្រើពាក្យមួយចំនួនក្នុងតារាងតក្កភាព (ក្នុងឯកសារកម្មវិធីសិលា ២០០១-២០០៥) ត្រូវបានផ្លាស់ប្តូរ ។ ដើម្បីធ្វើអោយស្របគ្នាជាមួយនឹងឯកភាពក្នុង ការប្រើពាក្យ ដែលមាននៅក្នុង ការណែនាំសំរាប់មេរៀន ការតាមដាន និងវាយតំលៃ របស់ AFAD ឆ្នាំ ២០០២ ។

សំរាប់មន្ត្រី និងដៃគូ ដូចដែលបានសង្ខេបក្នុងតារាងតក្កភាពស្រាប់។ ទិសដៅរបស់ផែនការសកម្មភាព និងថវិកា គឺធ្វើយ៉ាងណាអោយមន្ត្រីរបស់គំរោង និងភ្នាក់ងារអនុវត្តន៍កម្មវិធីបានយល់ច្បាស់ ពីអ្វីដែលត្រូវធ្វើ ត្រូវធ្វើនៅពេលណា ហើយត្រូវធ្វើបែបណា និងត្រូវមានធនធានអ្វីខ្លះ។ ជាងនេះទៅទៀត ផែនការសកម្មភាពក៏បាន បង្ហាញពីការងារដែលត្រូវអនុវត្តប្រចាំថ្ងៃផងដែរ។

ជាការសំខាន់ដែលត្រូវយល់ថា កម្មវិធីសិលា និងការធ្វើផែនការសកម្មភាពកម្មវិធីសិលា គឺត្រូវបានធ្វើឡើងជាដំណាក់ៗតាមកំរិតនីមួយៗ: មានន័យថា ឯកសារកម្មវិធីសិលា ២០០១-២០០៥ គឺជាមូលដានមួយសំរាប់រៀបចំផែនការសកម្មភាព និងថវិកាថ្នាក់ជាតិប្រចាំឆ្នាំ ដែលមានថវិកាវិភាជន៍និងសកម្មភាពសង្ខេបដែលត្រូវអនុវត្តដោយកម្មវិធីសិលាទាំងមូល។ ផែនការសកម្មភាពលំអិតមួយ ត្រូវបានធ្វើឡើងដោយអគ្គលេខាធិការដ្ឋាន នៃ គ.ជ.ន.ស ក្រសួងដែលអនុវត្តកម្មវិធីសិលា និង គ.អ.ជ.ខ ដែលត្រូវអនុវត្តប្រចាំឆ្នាំ។ ក្រសួងទាំងឡាយ និងគ.អ.ជ.ខ របស់ខេត្តនីមួយៗ ត្រូវរៀបចំថវិកា ហើយចុះហត្ថលេខាលើកិច្ចសន្យាជាមួយ គ.ជ.ន.ស។ ផែនការសកម្មភាពនិងថវិកាទាំងនេះ គឺជាមូលដ្ឋានមួយចាំបាច់សំរាប់ការតាមដានជាប្រចាំ។

ថ្នាក់ខេត្តក៏ត្រូវអនុវត្តដំណើរការស្រដៀងគ្នានេះដែរ ដោយ គ.ប្រ/គ.អ.ជ.ខ ភ្នាក់ងារអនុវត្តន៍ និងមន្ទីរវិស័យត្រូវរៀបចំផែនការសកម្មភាព និងគំរោងយ៉ាងលំអិត បន្ទាប់មកចុះហត្ថលេខា ព្រមព្រៀង ជាមួយ គ.អ.ជ.ខ។

| | | |
|---|---|---|
| **គោលដៅ** | | |
| ចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈអភិបាលកិច្ចល្អ ។ | | |
| **ទិសដៅ** | | |
| រៀបចំប្រព័ន្ធ និងយុទ្ធសាស្ត្រវិមជ្ឈការនានា ដើម្បីគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព | | |
| **លទ្ធផលទី១** | **លទ្ធផលទី២** | **លទ្ធផលទី៣** |
| ស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ ត្រូវបានពង្រឹង ហើយប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព | សេវាកម្ម និងវិនិយោគប្រកបដោយប្រសិទ្ធភាព និងសមត្ថភាព ត្រូវបានផ្តល់សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន | រួមចំណែកកែលំអគោលនយោបាយ និងបទបញ្ញត្តិនានាសំរាប់វិមជ្ឈការ វិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ |
| **សកម្មភាព** | **សកម្មភាព** | **សកម្មភាព** |
| ១.១. ជួយកែសំរួលអោយល្អប្រសើរនូវ | ២.១ រដ្ឋាភិបាល ផ្នែកឯកជន និង NGOs | ៣.១ រៀបចំបង្កើត និងអនុវត្តប្រព័ន្ធ |

| | | |
|---|---|---|
| ប្រព័ន្ធកសាងផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រងបែបវិមជ្ឈការ រួមបញ្ចូលទាំងការកំណត់តួនាទី និងការទទួលខុសត្រូវ ការរៀបចំសេចក្តីណែនាំ ការពង្រឹងសមត្ថភាព និងការផ្តល់នូវធនធានទាំងឡាយ | បានផ្តល់សេវាកម្ម និងកសាងហេដ្ឋារចនាសម្ព័ន្ធស្របទៅតាមផែនការ និងការអនុវត្តការគ្រប់គ្រងបានល្អ | វាយតំលៃតំរង់ទិសគោលនយោបាយ |
| ១.២ រៀបចំបង្កើត និងពង្រឹង ស្ថាប័ន/ផ្នែក នៅថ្នាក់ជាតិ ខេត្ត និងឃុំ សង្កាត់ ដែលចាំ បាច់ សំរាប់អនុវត្តការកសាងផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រងតាមបែបវិមជ្ឈការ | ២.២ សេវាត្រួតពិនិត្យ និងតាមដានណែនាំ ត្រូវបានផ្តល់ដោយថ្នាក់ជាតិ ខេត្ត និងឃុំ ដើម្បីធានាអោយធនធានក្នុងស្រុក និងបរទេស (ហិរញ្ញវត្ថុ និង មនុស្ស) ដែលចំណាយលើសេវាកម្ម និងការវិនិយោគ ត្រូវបានប្រើប្រាស់ យ៉ាងល្អប្រសើរ (មានប្រសិទ្ធិភាព ហិរញ្ញវត្ថុ និងគណនេយ្យភាព) និង មានប្រសិទ្ធិភាពខ្ពស់ (សេវាកម្ម និង ការវិនិយោគប្រកបដោយគុណភាព) | ៣.២ ផ្សព្វផ្សាយមេរៀន បទពិសោធដែលទទួលបាន |
| ១.៣ បណ្តុះបណ្តាល និងផ្តល់ការលើកទឹកចិត្ត ចំពោះមន្ត្រីថ្នាក់ជាតិ ខេត្តនិងឃុំ សង្កាត់ ដើម្បី ជួយជំរុញ និងអនុវត្តប្រព័ន្ធវិមជ្ឈការសំរាប់ការវិនិយោគ និងការផ្តល់សេវាកម្ម | ២.៣ វាយតំលៃផលប៉ះពាល់របស់កម្មវិធីសិលា ទៅលើគណនេយ្យភាព លទ្ធភាពអាចរកបាន សមត្ថភាពអាចធ្វើបាន សមធម៌ និងចីរភាពរបស់សេវាកម្ម ព្រមទាំងការវិនិយោគទាំងឡាយ | ៣.៣ រួមចំណែកក្នុងការរៀបចំគោលនយោបាយជាតិស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ |
| ១.៤ ការអនុវត្តន៍គោលការណ៍ និងប្រព័ន្ធក្នុងផ្នែកកសាងផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រងបែបវិមជ្ឈការ សំរាប់ការវិនិយោគ និងសេវាកម្ម | | ៣.៤ រួមចំណែកជាមួយគោលនយោបាយជាតិដែលត្រូវអនុវត្តដោយក្រសួងនានា ក្នុងកម្មវិធីកាត់បន្ថយភាពក្រីក្រ បញ្ហាបរយេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ |
| ១.៥ រៀបចំបង្កើតយន្តការ សំរាប់អោយមានការពិភាក្សា និងភាពជាដៃគូរវាងរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន ស្តីពីអភិបាលកិច្ចតាមបែបវិមជ្ឈការនៅថ្នាក់ខេត្ត | | |
| ១.៦ រៀបចំបង្កើតយុទ្ធសាស្ត្រវិនិយោគសំរាប់ការកាត់បន្ថយភាពក្រីក្រ | | |

ជាការសំខាន់ត្រូវយល់ថា កម្មវិធីសិលា និងការកសាងផែនការសកម្មភាពរបស់កម្មវិធីសិលា គឺជាកម្មវិធីដែលត្រូវអនុវត្តនៅច្រើនថ្នាក់។ ឯកសាររបស់កម្មវិធីសិលាឆ្នាំ ២០០១-២០០៥ គឺជាមូលដ្ឋានគ្រឹះសំរាប់រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនៅថ្នាក់ជាតិ។ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនេះ គឺមានការបែងចែកថវិកា និងសកម្មភាពសង្ខេបដែលត្រូវអនុវត្តដោយកម្មវិធីសិលាទាំងមូល។ ជារៀងរាល់ឆ្នាំ ផែនការសកម្មភាពលំអិតដែលគេត្រូវអនុវត្ត ត្រូវបានបង្កើតឡើងដោយអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា(STFS) ក្រសួង និងដោយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (PRDC)។ ក្រសួង និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ត្រូវរៀបចំថវិកា និងចុះហត្ថលេខាលើកិច្ចសន្យាជាមួយគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា។ ផែនការសកម្មភាពនិងថវិកាទាំងនេះ គឺជាមូលដ្ឋានមួយសំរាប់ធ្វើការតាមដាន ជាទៀងទាត់។

នៅថ្នាក់ខេត្ត ក៏ត្រូវអនុវត្តដំណើរការដូចគ្នានេះដែរ។ គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ភ្នាក់ងារអនុវត្តន៍ និងមន្ទីរជំនាញ ត្រូវរៀបចំផែនការសកម្មភាព និងគំរោងយ៉ាងលំអិត និងត្រូវចុះហត្ថលេខាព្រមព្រៀងជាមួយ PRDC។

ថ្នាក់ឃុំក៏ត្រូវអនុវត្តគោលការណ៍ដូចគ្នានេះដែរ គឺ ក្រុមប្រឹក្សាឃុំ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ ផែនការវិនិយោគរយៈពេល ៣ឆ្នាំ និងរៀបចំថវិកាប្រចាំឆ្នាំរបស់ខ្លួន។ នៅពេលដែលថវិកាប្រចាំឆ្នាំទទួលបានសេចក្តីសំរេចហើយនោះ ក្រុមប្រឹក្សាឃុំត្រូវរៀបចំកិច្ចព្រមព្រៀងអោយកាន់តែបានលំអិត។ ទោះបីយ៉ាងណាក៏ដោយ ឃុំមានស្ថានភាពមួយខុសពីថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រង់ថា ឃុំទទួលបានមូលនិធិភាគច្រើនដោយផ្ទាល់ពីរដ្ឋាភិបាល គឺពីមូលនិធិឃុំ។ កន្លងមក ឃុំដែលស្ថិតក្នុងគំរោង របស់កម្មវិធីសិលា ទទួលបានមូលនិធិពីមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន (LDF) ដែលចាត់ចែងដោយកម្មវិធីសិលា។

ទោះបីយ៉ាងនេះក៏ដោយ កម្មវិធីសិលានៅតែផ្តល់ធនធានដល់មូលនិធិឃុំ ដែលធ្វើអោយកម្មវិធីសិលាអាចបញ្ចូលប្រព័ន្ធតាមដាននិងវាយតំលៃលើគំរោងអភិវឌ្ឍន៍ឃុំទៅក្នុងឯកសារនេះផងដែរ។

ដោយសារកម្មវិធីសិលា ត្រូវបានរៀបចំឡើងជាដំណាក់ៗតាមកំរិតនីមួយៗ ដូចនេះហើយ ទើបប្រព័ន្ធតាមដាន និងវាយតំលៃ ក៏ត្រូវធ្វើដូចគ្នានេះដែរ។ ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា នៅ

ថ្នាក់ជាតិ គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រព័ន្ធតាមដាននិងវាយតំលៃថ្នាក់ខេត្ត ហើយជាបន្តទៀត ថ្នាក់ខេត្តនេះឯង ក៏ត្រូវពឹងផ្អែកដោយផ្អែកៗទៅលើប្រព័ន្ធតាមដាននិងវាយតំលៃរបស់ថ្នាក់ឃុំ។

**ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ**

- កម្មវិធីសិលា ២០០១-២០០៥
- ផែនកាសកម្មភាព និងថវិកាប្រចាំឆ្នាំ
- កិច្ចសន្យាក្រសួងប្រចាំឆ្នាំ
- កិច្ចសន្យា គ.អ.ជ.ខ ប្រចាំឆ្នាំ
- ការសិក្សា និងវាយតំលៃជាពិសេស

**ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ខេត្ត-ក្រុង**

- ផែនការអភិវឌ្ឍន៍ខេត្ត ៥ ឆ្នាំ
- ផែនការវិនិយោគ និងអភិវឌ្ឍន៍ខេត្ត ៣ឆ្នាំ
- ផែនការសកម្មភាព និងថវិកាប្រចាំខេត្ត
- កិច្ចសន្យាប្រចាំឆ្នាំ ជាមួយភ្នាក់ងារអនុវត្តន៍

**ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ ឃុំ**

- ផែនការអភិវឌ្ឍន៍ឃុំ ៥ ឆ្នាំ
- ផែនការវិនិយោគឃុំ ៣ ឆ្នាំ
- ថវិកាប្រចាំឆ្នាំ
- កិច្ចសន្យាគំរោងអភិវឌ្ឍន៍របស់ឃុំ

សូចនាករសំរាប់ការអនុវត្តន៍កម្មវិធី និងមធ្យោបាយផ្ទៀងផ្ទាត់ (យន្តការតាមដានសំខាន់ៗ ) គឺជាផ្អែកមួយ សំរាប់រៀបចំកម្មវិធី/គំរោង។ សូចនាករនិងមធ្យោបាយផ្ទៀងផ្ទាត់នេះត្រូវបានសង្ខេបដាក់ក្នុងតារាងតក្កភាព ហើយវាបានក្លាយជាមូលដ្ឋានមួយសំរាប់ការងារតាមដាននិងវាយតំលៃ របស់កម្មវិធីសិលាទាំងមូល។ កាន់តែច្បាស់ជាងនេះទៅទៀត ដោយសារកម្មវិធីសិលាមានដំណើរការនៅកំរិតផ្សេងៗ(ជាតិ ខេត្ត និងឃុំ) និងគំរោងអភិវឌ្ឍន៍ឃុំ ស្ថិតនៅក្នុងក្របខ័ណ្ឌគំរោងថ្នាក់ខេត្ត ហើយគំរោងថ្នាក់ខេត្ត ស្ថិតក្នុងក្របខ័ណ្ឌកម្មវិធីថ្នាក់ជាតិទាំងមូលបែបនេះ បានធ្វើអោយកម្មវិធីសិលានិងប្រព័ន្ធតាមដាន និងវាយតំលៃរបស់វាមានលក្ខណៈ ស្មុគស្មាញបន្តិចបន្តួច។

ត្រូវចាំទុកថា តារាងតក្កភាពរបស់កម្មវិធីសិលាគ្រាន់តែបានបង្ហាញ នូវទិដ្ឋភាពមួយដ៏សាមញ្ញរបស់កម្មវិធីសិលាតែប៉ុណ្ណោះ ព្រោះថាកម្មវិធីសិលា គឺជាកម្មវិធីមួយដែលធំ ហើយមានទិសដៅច្រើន ព្រមទាំងត្រូវបានអនុវត្តនៅលើកំរិតពផ្សេងៗគ្នា (ថ្នាក់ជាតិ ខេត្ត និង ថ្នាក់ឃុំ )។ កម្មវិធីសិលាទាំងមូល ត្រូវបានសង្ខេបដាក់នៅក្នុងតារាងម៉ាទ្រិកមួយ ដែលមានតារាងតក្កភាព ៤ គុណនឹង ៤ ផ្ទប់។ ប៉ុន្តែតារាងម៉ាទ្រិកនេះ មិនបានផ្តល់ពត៌មានលំអិតគ្រប់គ្រាន់សំរាប់ធ្វើអោយការគ្រប់គ្រង ឬការតាមដាន និងវាយតំលៃមានប្រសិទ្ធភាពនោះទេ។ តារាងតក្កភាពកម្មវិធីសិលា បានផ្តល់ត្រឹមតែមូលដ្ឋាននិងទំរង់ក្រៅមួយសំរាប់ការងារតាមដាននិងវាយតំលៃតែប៉ុណ្ណោះ គឺវាមិនបានផ្តល់រាល់ពត៌មានលំអិតគ្រប់គ្រាន់នោះទេ។ ដើម្បីធ្វើអោយសកម្មភាពការតាមដាននិងវាយតំលៃ កាន់តែអាចគ្រប់គ្រងបាននោះ អ្វីដែលចាំបាច់ត្រូវធ្វើនៅ

ថ្នាក់ជាតិ និងថ្នាក់ខេត្តនោះ គឺត្រូវបានបំបែកដាច់ពីគ្នាយ៉ាងច្បាស់។ សកម្មភាពនិងលទ្ធផលនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត គឺនៅតែមានទំនាក់ទំនងនឹងតារាងតក្កភាពរួមរបស់កម្មវិធីសិលា ដូច្នេះវាក៏បានចូលរួមធ្វើអោយសំរេចបាននូវគោលដៅ និងទិសដៅរួមរបស់កម្មវិធីសិលាផងដែរ។

ឯកសារកម្មវិធីសិលា២០០១.២០០៥ ក៏បានផ្តល់នូវសូចនាករអនុវត្តន៍សំរាប់សកម្មភាពផងដែរ។ ការនេះជាធម្មតាមិនធ្លាប់មាននោះទេ ព្រោះថា តារាងតក្កភាពអាចផ្តល់ត្រឹមតែ សូចនាករសំរាប់ទិសដៅ និងលទ្ធផលរំពឹងទុក ហើយវាគ្រាន់តែបញ្ជាក់នូវធនធានចាំបាច់មួយចំនួន សំរាប់ការអនុវត្តន៍សកម្មភាពតែប៉ុណ្ណោះ។ ហេតុដូចនេះហើយ សូចនាករសំរាប់សកម្មភាពពុំត្រូវបានគេបញ្ជាក់ច្បាស់លាស់នោះទេ។

## ២.៤ ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា

### ២.៤.១. ទំនាក់ទំនងរវាងកម្មវិធីសិលា និងប្រព័ន្ធតាមដាន វាយតំលៃរបស់កម្មវិធីសិលា

តារាងតក្កភាព ដែលបានបង្ហាញពីយុទ្ធសាស្ត្រកម្មវិធី តាមលក្ខណៈជាប្រព័ន្ធ មិនត្រឹមតែជាមូលដ្ឋានមួយដែលជួយអោយយើងអាចបង្កើតផែនការសកម្មភាព និងគំរោងមួយយ៉ាងលំអិតនៅថ្នាក់ជាតិ និងថ្នាក់ខេត្តប៉ុណ្ណោះទេ តែវាក៏ជាមូលដ្ឋានចាំបាច់សំរាប់អោយយើងបង្កើតប្រព័ន្ធM&Eមួយដ៏មានប្រសិទ្ធភាពផងដែរ។ រូបភាពខាងក្រោមនេះ ដកស្រង់ចេញពីឯកសារតាមដាន និងវាយតំលៃរបស់ គំរោង IFAD[4] បានបង្ហាញពីទំនាក់ទំនងរបស់ប្រព័ន្ធM&Eជាមួយនឹងយុទ្ធសាស្ត្រ និងប្រតិបត្តិការរបស់កម្មវិធី។




[4] Source: IFAD, 2002, A Guide for Project M&E : Managing for Impact in Rural Development, International Fund for Agricultural Development, Rome, Italy.

តារាងតក្កភាពជាអ្នកចង្អុលបង្ហាញពីអ្វីដែលកម្មវិធីសិលា សង្ឃឹមថានឹងធ្វើអោយបានសំរេច និងពីរបៀបធ្វើផែនការដើម្បីសំរេចគោលបំណងនោះ។ យើងត្រូវធ្វើអោយយុទ្ធសាស្ត្រទូទៅរបស់កម្មវិធី ក្លាយទៅជាផែនការអនុវត្តន៍ជាក់លាក់មួយចំនួនដែលបង្ហាញថា គំរោងណាខ្លះដែលត្រូវអនុវត្តនៅកំរិតណា ឬថ្នាក់ណា ហើយតើគំរោងមានលទ្ធផលរំពឹងទុក និងសមិទ្ធិផល ព្រមទាំងផលប៉ះពាល់អ្វីខ្លះ។ គោលបំណងរបស់ប្រព័ន្ធតាមដាន និងវាយតំលៃ គឺត្រូវប្រមូលនិងផ្តល់ពត៌មាន ថាតើមានអ្វីខ្លះបានកើតឡើងជាក់ស្តែង ក្នុងការអនុវត្តន៍កម្មវិធី និងជួយកំណត់វិធីសាស្ត្រដើម្បីធ្វើអោយការអនុវត្តន៍ និងការគ្រប់គ្រងកម្មវិធីសិលាកាន់តែប្រសើរឡើង។

ក្នុងរូបភាពខាងលើ យើងឃើញថា ប្រព័ន្ធតាមដាន និងវាយតំលៃ មានភារកិច្ចចំបងៗចំនួន ៤ ដែលត្រូវអនុវត្តជាបន្តបន្ទាប់ ដែលរួមមាន "ការបង្កើតប្រព័ន្ធប្រព័ន្ធតាមដាននិងវាយតំលៃ ការប្រមូលនិងគ្រប់គ្រងពត៌មាន ការពិនិត្យកែតំរូវសកម្មភាព និងការទំនាក់ទំនងនិងរបាយការណ៍"។ ក្នុងកម្មវិធីសិលាក៏ដូចជាកម្មវិធីនិងគំរោងផ្សេងៗទៀត ដែលមានការវិវឌ្ឍន៍ជាបន្តបន្ទាប់ ភារកិច្ចទាំងនេះ ជួនកាលតែងតែត្រូវបានអនុវត្តស្ទួនគ្នា ហើយពីការអនុវត្តន៍មួយទៅការអនុវត្តន៍មួយ តែងតែលំបាក និងស៊ីជំរៅជាលំដាប់។ ឧទាហរណ៍ កម្មវិធីសិលា បានកសាងសមត្ថភាពយ៉ាងខ្លាំងដល់ថ្នាក់ខេត្ត ឃុំ និងភូមិ ហើយវាស្ថិតនៅត្រឹមក្នុងដំណាក់កាលបច្ចុប្បន្នដែលរចនាសម្ព័ន្ធគាំទ្ររបស់កម្មវិធីសិលានៅថ្នាក់ជាតិ ទទួលបានការយកចិត្តទុកដាក់ច្រើនជាងមុន។

### ២.៤.២. ចំណុចដែលត្រូវពិចារណាសំរាប់បង្កើតប្រព័ន្ធតាមដាននិងវាយតំលៃ

យោងទៅលើបទពិសោធន៍ ដែលទទួលបានពីដំណាក់កាលទីមួយរបស់កម្មវិធសិលា (១៩៩៦-២០០១) ចំណុចមួយចំនួនខាងក្រោមនេះ ត្រូវបានលើកយកមកពិចារណាសំរាប់រៀបចំប្រព័ន្ធតាមដាន និង វាយតំលៃសំរាប់រយៈពេល៥ឆ្នាំ (២០០១-២០០៥)។ ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធិសិលា ត្រូវតែ :

- ...សាមញ្ញហើយងាយយល់ : យកល្អត្រូវចាប់ផ្តើមពីអ្វីដែលមានទំហំតូច ហើយអាចអនុវត្តបាន ហើយធ្វើការអភិវឌ្ឍន៍វាជាបន្តបន្ទាប់ រហូតដល់ស្មុគស្មាញ ហើយលំបាកៗ
- ...បង្ហាញ ឬបង្កើតឡើងនូវទំនាក់ទំនងមួយច្បាស់លាស់ រវាងតារាងតក្កភាពរបស់កម្មវិធីសិលា និងសកម្មភាពនៅគ្រប់កំរិត
- ...កំណត់អោយបានច្បាស់ពីពត៌មានសំខាន់ៗ ដែលចាំបាច់នៅគ្រប់កំរិតទាំងអស់
- ...ពិចារណាពីតួនាទី ការទទួលខុសត្រូវ និងសមត្ថភាពរបស់មនុស្សផ្សេងៗគ្នា

- ...អាចបត់បែនបាន និងអាចផ្លាស់ប្តូរទៅតាមប្រព័ន្ធ និងគោលនយោបាយផ្សេងៗ

ប្រព័ន្ធតាមដាននិងវាយតំលៃ គឺត្រូវការជាចាំបាច់ ដើម្បីតាមដានការរីកចំរើនក្នុងការអនុវត្តន៍កម្មវិធី និងវាយតំលៃពីផលប៉ះពាល់ នៃលទ្ធផលរបស់គំរោង ព្រោះថាវាផ្តល់ពត៌មានមួយចំនួន ដើម្បី :

- គាំទ្រដល់ការវិភាជន៍មូលនិធិវិនិយោគ និងការរៀបចំផែនការវិនិយោគ
- តាមដានការរីកចំរើនលើការផ្តល់សេវាកម្ម និងវិនិយោគនៅថ្នាក់ខេត្ត និងឃុំ
- វាយតំលៃលើប្រសិទ្ធភាព និងសមត្ថភាពនៃប្រព័ន្ធ និងរចនាសម្ព័ន្ធនានា ដែលបានដាក់អោយប្រើប្រាស់ និងដែលគាំទ្រដោយកម្មវិធីសិលា
- វាយតំលៃផលប៉ះពាល់ (ស្តីពីភាពក្រីក្រ) នៃសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា ដែលបានផ្តល់អោយ និង
- ផ្តល់យោបល់ត្រលប់ ស្តីពីការប្រើប្រាស់គោលនយោបាយ ដែលបានបង្កើតឡើងដោយកម្មវិធីសិលានិងប្រសិទ្ធភាពរបស់វា

## ២.៤.៣. ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃក្នុងកម្មវិធីសិលា

តាមរយៈរូបភាពខាងលើ យើងឃើញថា ប្រព័ន្ធតាមដាន និងវាយតំលៃមានភារកិច្ចសំខាន់ៗ ចំនួន៤ គឺ :

១. **ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃ** : ដើម្បីធ្វើការតាមដាន និងវាយតំលៃលើកម្មវិធីសិលាទាំងមូល អោយស៊ីសង្វាក់គ្នា ចាំបាច់ត្រូវអោយមានសូចនាករ និងនីតិវិធីក្នុងការតាមដាន និងវាយតំលៃនេះរួមគ្នា នៅគ្រប់ខេត្តទាំងអស់ ដូចជា តើត្រូវប្រមូលពត៌មានអ្វីខ្លះ ដើម្បីគ្រប់គ្រងកម្មវិធីសិលាអោយបានល្អ និងតើត្រូវធ្វើការតាមដាន និងវាយតំលៃតាមរបៀបណា ព្រមទាំងនៅពេលណាខ្លះ។

២. **ការប្រមូលនិងគ្រប់គ្រងពត៌មាន** : ពាក់ព័ន្ធទៅនឹងការតាមដានពត៌មានលទ្ធផលរំពឹងទុក និងផលប៉ះពាល់របស់គំរោង ឬកម្មវិធីណាមួយ។ ការប្រមូលទិន្នន័យ គឺជាការងារស្នូលមួយរបស់ប្រព័ន្ធតាមដាន និងវាយតំលៃ ហេតុដូចនេះហើយ សំខាន់បំផុត យើងត្រូវកំណត់អោយបានច្បាស់ពីវិធីសាស្ត្រប្រមូល និងគ្រប់គ្រងទិន្នន័យ។

៣. **ការពិនិត្យកែតំរូវសកម្មភាព** : ជាទូទៅ ការប្រមូលនិងការគ្រប់គ្រងទិន្នន័យនិងពត៌មាន ទាមទារអោយមានពេលវេលា និងធនធានយ៉ាងច្រើនជាចាំបាច់ សំរាប់អោយអ្នកដែលទទួលខុសត្រូវ លើ

ការងារតាមដាននិងវាយតំលៃ មានពេលវេលាគ្រប់គ្រាន់ ដើម្បីវិភាគ និងសិក្សាលើពត៌មានដែលប្រមូលបានទាំងនោះ។ តើទិន្នន័យដែលប្រមូលបាន នឹងប្រាប់យើងពីអ្វីខ្លះ ដើម្បីធ្វើអោយប្រសើរឡើងដល់ការគ្រប់គ្រង និងប្រសិទ្ធភាពរបស់គំរោង ដែលបានអនុវត្តក្នុងកម្មវិធីសិលា?

៤. **ទំនាក់ទំនង និងរបាយការណ៍ស្តីពីលទ្ធផល** : ពត៌មានដែលទទួលបានពីការតាមដាននិងវាយតំលៃនេះ មិនត្រឹមតែផ្តល់អោយអ្នកដែលទទួលខុសត្រូវលើការងារតាមដាននិងវាយតំលៃ បានយល់ដឹងពីកម្មវិធី ថាមានដំណើរការ ឬគ្មានដំណើរការនោះទេ តែត្រូវតែចែករំលែកជាមួយអ្នកដែលពាក់ព័ន្ធនៅគ្រប់កំរិតទាំងអស់ក្នុងកម្មវិធីសិលា។ ដូចនេះ អ្នកទាំងនោះ នឹងអាចចាប់ផ្តើមផ្ទៀងផ្ទាត់ និងសំរបសំរួល និងធ្វើអោយកម្មវិធីសិលាបានល្អប្រសើរឡើង ស្របទៅតាមការទទួលខុសត្រូវរបស់ខ្លួន និងពត៌មានដែលទទួលបានពីការតាមដាននិងវាយតំលៃនោះ។ អង្គការនានា ដែលគាំទ្រ ឬដែលសហការជាមួយកម្មវិធីសិលា ក៏មានការចាប់អារម្មណ៍លើពត៌មានស្តីពីសមិទ្ធិផលរបស់កម្មវិធីសិលាដែរ។

## ២.៤.៤ ចំណុចសំខាន់ៗ ដើម្បីបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃក្នុងកម្មវិធីសិលា

ពិនិត្យលើលទ្ធផលរំពឹងទុក និងសកម្មភាពដែលមាននៅក្នុងតារាងតក្កភាពរបស់កម្មវិធីសិលា យើងអាចឃើញថា វាមានចំណុចសំខាន់ៗចំនួន៨ ដែលក្នុងនោះ ចំណុចនីមួយៗ មានសូចនាករមួយ ឬច្រើន ដែលអាចជួយអោយយើងដឹងពីអ្វីដែលកម្មវិធីសិលាសំរេចបាន។ ចំណុចទាំង៨នេះ គឺ :

១. ***ការកសាងផែនការ*** :ផ្តល់ពត៌មានពីការអនុវត្តន៍កម្មវិធីសិលា និងប្រព័ន្ធកសាងផែនការនិងថវិកាឃុំ។

២. ***ការអនុវត្តន៍ និងការរីកចំរើន*** : ផ្តោតលើការតាមដានការអនុវត្តន៍ផែនការសកម្មភាព និងកិច្ចសន្យា ព្រមទាំងបញ្ហានានាដែលទាក់ទងនឹងហិរញ្ញវត្ថុ។

៣. ***ផលប៉ះពាល់*** : វិភាគផលប៉ះពាល់ជាក់ស្តែង គឺវិភាគលើគោលដៅ និងទិសដៅរបស់គំរោងវិនិយោគផ្សេងៗ វិភាគលើគំរោងនិងសកម្មភាពដែលបានអនុវត្តនៅថ្នាក់ឃុំ និងខេត្ត ដោយផ្តោតជាសំខាន់ទៅលើបញ្ហាអន្តរវិស័យ (ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងការបញ្ជ្រាបយេនឌ័រ)។

៤. ***ការកសាងសមត្ថភាព*** : តាមដានលទ្ធផល និងផលប៉ះពាល់ ដែលមានចំពោះការកសាងសមត្ថភាព។

***៥. ការអនុវត្តន៍តាម*** : ពិនិត្យ និងវិភាគឡើងវិញលើការអនុវត្តន៍ និងការប្រើប្រាស់ជាក់ស្តែងនូវប្រព័ន្ធមួយចំនួន (ប្រព័ន្ធកសាងផែនការ ប្រព័ន្ធហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រង និងប្រព័ន្ធតាមដាន វាយតំលៃ និងពត៌មាន) ដែលបានដាក់អោយប្រើប្រាស់។ បន្ថែមលើនេះទៀតក៏ត្រូវពិនិត្យមើលលើប្រសិទ្ធភាព និង ភាពសមស្របរបស់ប្រព័ន្ធទាំងនោះ។

***៦. ការគ្រប់គ្រង:*** គ្រប់គ្រងបុគ្គលិក
ការគ្រប់គ្រងរដ្ឋបាលនិងថែរក្សាព្រទ្យសម្បត្តិនិងលទ្ធផលរបស់គំរោង។

***៧. ភាពជាដៃគូ /ការសំរបសំរួល*** : សំរបសំរួល និងសហប្រតិបត្តិការក្នុងការកសាងផែនការ ផ្តល់មូលនិធិ និងក្នុងការភ្ជាប់ជាបណ្តាញ។

***៨. គោលនយោបាយ និងយុទ្ធសាស្ត្រ*** : តាមមើលថាតើបទពិសោធ និងមេរៀនរបស់កម្មវិធីសិលា ខាងអភិបាលកិច្ចល្អ វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានវិភាគនិងបានប្រើប្រាស់ជាធនធានមួយ បែបណា សំរាប់បង្កើតគោលនយោបាយថ្នាក់ជាតិ។ ក្នុងចំណុចនេះ ក៏រួមបញ្ចូលនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងការបញ្ជ្រាបយេនឌ័ររបស់កម្មវិធីសិលា។

ថ្នាក់ជាតិ និងថ្នាក់ខេត្ត មានភាពខុសៗគ្នា ស្តីពីទំនាក់ទំនងលើចំណុចសំខាន់ៗទាំងនេះ។ ទន្ទឹមនឹងនេះ ក៏មានភាពខុសគ្នាផ្សេងទៀតផងដែរ ដូចជា តើប្រព័ន្ធ នីតិវិធី និងឧបករណ៍ សំរាប់តាមដានលើការអភិវឌ្ឍន៍ចំណុចសំខាន់ទាំងនេះ ត្រូវបានបង្កើតឡើងបានកំរិតណាហើយ។ តារាងខាងក្រោមនឹងបង្ហាញថាតើចំណុចនីមួយៗនេះ ត្រូវបានបង្កើតឡើងកំរិតណាហើយ នៅត្រឹមដើមឆ្នាំ ២០០៣នេះ។

| ចំណុចសំខាន់ៗ | ថ្នាក់ឃុំ[5] | ថ្នាក់ខេត្ត ក្រុង | ថ្នាក់ជាតិ |
|---|---|---|---|
| ការកសាងផែនការ | មូលដ្ឋាននៃប្រព័ន្ធតាមដាន ត្រូវបានបង្កើតឡើងហើយ តែត្រូវបកស្រាយអោយបានលំអិតថែមទៀត | មានល្អស្រាប់ហើយ | មានល្អស្រាប់ហើយ |
| ការអនុវត្តន៍ និងការរីកចំរើន | មិនទាន់មានទេ។ចាំបាច់ត្រូវបង្កើតឡើងដោយផ្អែកលើបទពិសោធ របស់កម្មវិធីសិលាជាមួយនឹង គំរោង LDF | មានល្អស្រាប់ហើយ ។ ប្រព័ន្ធទិន្នន័យមូលដ្ឋានត្រូវកែសំរួលអោយទៅជាប្រព័ន្ធទិន្នន័យមូលនិធិឃុំវិញ | មានខ្លះ ស្រាប់ហើយ |

[5] ហេតុផលដែលត្រូវដាក់ថ្នាក់ឃុំនៅក្នុងតារាងនេះ គឺដើម្បីបំពេញអោយបានគ្រប់ថ្នាក់នៅក្នុងតារាងនេះតែប៉ុណ្ណោះ ។ ត្រូវចងចាំថា ការតាមដាន និងវាយតំលៃ នៅថ្នាក់ឃុំ គឺមិនមែនជាការតាមដាន និងវាយតំលៃរបស់កម្មវិធីសិលាទៀតទេ តែវាជាការតាមដាន និងវាយតំលៃរបស់រដ្ឋបាលមូលដ្ឋាន ។

| | | | |
|---|---|---|---|
| ផលប៉ះពាល់ | មិនទាន់មាន ។ ចាំបាច់ត្រូវបង្កើតឡើង | ប្រព័ន្ធវាយតំលៃលើកិច្ចសន្យាបានបង្កើតឡើងហើយ តែប្រព័ន្ធវាយតំលៃលើផលប៉ះពាល់មិនទាន់មានទេ គឺចាំបាច់ត្រូវបង្កើតឡើង | ប្រព័ន្ធវាយតំលៃលើផលប៉ះពាល់ពីគោលដៅ មិនទាន់មានទេ ។ ចាំបាច់ត្រូវបង្កើតវាឡើង |
| ការកសាងសមត្ថភាព | មិនទាន់មានទេ ។ ត្រូវបង្កើតវិធីសាស្រ្តចាត់ប្រមាណដោយខ្លួនឯងសំរាប់ក្រុមប្រឹក្សាឃុំ | មានល្មមស្រាប់ហើយ តែគួរតែមានការកែប្រែខ្លះៗ និងត្រូវបង្កើតឯកសារបណ្តុះបណ្តាលដែលមានលក្ខណៈស្តង់ដា | មានផ្នែកខ្លះស្រាប់ហើយ |
| ការអនុវត្តដំណាក់/ប្រព័ន្ធ | មិនទាន់មានទេ ។ គឺចាំបាច់ត្រូវបង្កើតវាឡើង | មានស្រាប់ហើយ តែប្រព័ន្ធតាមដានឃុំសង្កាត់គួរតែមានការកែប្រែខ្លះៗ | មានស្រាប់ហើយ តែត្រូវបង្កើតបន្ថែមទៀត |
| ការគ្រប់គ្រង | មិនចាំបាច់ | មានល្មមស្រាប់ហើយ | មានស្រាប់ហើយ |
| ភាពជាដៃគូ/ការសំរបសំរួល | មិនទាន់មានទេ ។ ចាំបាច់ត្រូវបង្កើតវាឡើង | ផ្នែកខ្លះ ឬទិដ្ឋភាពខ្លះ ត្រូវបានតាមដាន និងត្រួតពិនិត្យ តែត្រូវអោយមានការបង្កើតបន្ថែមទៀត និងធ្វើអោយវាមានលក្ខណៈស្តង់ដា | មានស្រាប់ហើយ |
| គោលនយោបាយ | មិនចាំបាច់ | មិនចាំបាច់ | មិនទាន់មានទេ ។ គឺចាំបាច់ត្រូវបង្កើតវាឡើង |

## ២.៤.៥ សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់

យើងគួរយល់អោយបានច្បាស់លាស់ថា រាល់ប្រព័ន្ធតាមដាននិងវាយតំលៃ មានមូលដ្ឋានគ្រឹះ លើការប្រមូលពត៌មានគ្រប់ជ្រុងជ្រោយប្រទាក់ក្រឡាគ្នា ដោយប្រើមធ្យោបាយផ្ទៀងផ្ទាត់មួយចំនួន ក្នុងការប្រមូលពត៌មានដែលឆ្លើយតបទៅនឹងសូចនាករដែលបានកំណត់។ កម្មវិធីសិលា បានកំណត់ និយមន័យ និងចរិកលក្ខណៈរបស់សូចនាករ និងមធ្យោបាយផ្ទៀងផ្ទាត់ ដូចខាងក្រោម :

ឯកសារណែនាំ ស្តីពី

ការតាមដាន និងវាយតំលៃ

កម្មវិធីសិលា

# ផ្នែកទី៤

# ប្រព័ន្ធតាមដាន និងវាយតំលៃរបស់ កម្មវិធីសិលា ថ្នាក់ខេត្ត



# ៤.១ សេចក្តីផ្តើម

## ៤.១.១ រចនាសម្ព័ន្ធគ្រប់គ្រងរបស់កម្មវិធីសិលាថ្នាក់ខេត្ត

នៅថ្នាក់ខេត្ត កម្មវិធីសិលាត្រូវបានអនុវត្តដោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងគណៈកម្មាធិការប្រតិបត្តិ។ ដោយឡែកគណៈកម្មាធិការប្រតិបត្តិនេះ មានផ្នែកធំៗចំនួន៤ ដើម្បីជួយអនុវត្តកម្មវិធីសិលា។ ផ្នែកទាំង៤នោះ គឺ:

- ផ្នែកគ្រប់គ្រងកិច្ចសន្យា (CAU) ហើយប្រធានផ្នែកនេះ មកពីមន្ទីរផែនការខេត្ត
- ផ្នែករដ្ឋបាលមូលដ្ឋាន (LAU) ហើយប្រធានផ្នែកនេះ មកពីការិយាល័យរដ្ឋបាលមូលដ្ឋាន
- ផ្នែកគាំទ្របច្ចេកទេស (TSU) ហើយប្រធានផ្នែកនេះ មកពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- ផ្នែកហិរញ្ញវត្ថុ (FU) ហើយប្រធានផ្នែកនេះ មកពីមន្ទីរហិរញ្ញវត្ថុខេត្ត និងអនុប្រធាន មកពីរតនាគារខេត្ត

ខាងក្រោមនេះ គឺជារចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីសិលាថ្នាក់ខេត្ត



តារាងបរិយាយការងារលំអិតសំរាប់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត គណៈកម្មាធិការប្រតិបត្តិ និងផ្នែកទាំងអស់គឺមិនចាំបាច់លើកឡើងម្តងទៀតក្នុងផ្នែកនេះទេព្រោះវាមាននៅក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលាហើយ។ ដូចនេះ ឯកសារនេះផ្តោតជាពិសេស តែលើតួនាទីក្នុងការតាមដាន និងវាយតំលៃ របស់ ផ្នែកនីមួយៗរបស់ខេត្តតែប៉ុណ្ណោះ។

## ៤.១.២. ការអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ខេត្ត

គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (គ.ប្រ/គ.អ.ជ.ខ) ជាអ្នកចាត់ចែងការអនុវត្តន៍ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិលា។ ប៉ុន្តែការអនុវត្តន៍ជាក់ស្តែង គឺត្រូវបានធ្វើឡើងដោយស្ថាប័ន និងអង្គការនានាជាពិសេស មន្ទីរជំនាញនៅតាមខេត្ត ហើយក្នុងករណីខ្លះ អង្គការមិនមែន រដ្ឋាភិបាលនិងផ្នែកឯកជន ក៏ជាអ្នកអនុវត្តដងដែរ។ អ្នកអនុវត្តន៍គំរោងរបស់កម្មវិធីសិលា ត្រូវចុះហត្ថលេខាលើកិច្ចសន្យារបស់ខ្លួនជាមួយគ.ប្រ/គ.អ.ជ.ខ ហើយការអនុវត្តន៍កិច្ចសន្យាទាំងនេះ ទទួលបានការវិភាជន៍ថវិកាពីមូលនិធិវិនិយោគខេត្ត (PIF) ដែលគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (គ.ដ.ន.ស) ផ្តល់អោយខេត្តនីមួយៗរៀងរាល់ឆ្នាំ។ ជាងនេះទៅទៀត គ.ប្រ/គ.អ.ជ.ខ ក៏ទទួលបានថវិកាគាំទ្រកម្មវិធី ពីគ.ដ.ន.ស ផងដែរដើម្បីគាំទ្រដល់ការអនុវត្តន៍សកម្មភាពរបស់ខ្លួន។

ទំរង់បែបបទនៃកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ជាមួយគ.អ.ជ.ខ ត្រូវបានរៀបចំឡើងដោយលទ្ធផល និងសកម្មភាពរបស់វាទៅនឹងតារាងតក្កភាពរួមរបស់កម្មវិធីសិលា ដោយប្រើលេខកូដនិងប្រព័ន្ធរបាយការណ៍ដែលមានលក្ខណៈឯកភាពរួម។ លេខកូដលទ្ធផលនិងសកម្មភាពទាំងឡាយត្រូវបានប្រើ ដើម្បីភ្ជាប់ទៅនឹងប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យា (SCD) ដែលជាឧបករណ៍មួយដ៏សំខាន់ សំរាប់តាមដានការរីកចំរើនរបស់គំរោងដែលទទួលការវិភាជន៍ពីមូលនិធិវិនិយោគខេត្ត។ SCD ក៏អាចតាមដានការរីកចំរើនលើការអនុវត្តន៍សកម្មភាព និងកិច្ចសន្យា លទ្ធផល ព្រមទាំងពត៌មានហិរញ្ញវត្ថុផងដែរ។ តារាងគ្រប់គ្រងទិន្នន័យកិច្ចសន្យា (Contract Monitoring Spreadsheet) គឺជាឧបករណ៍ដ៏សំខាន់មួយសំរាប់តាមដានការរីកចំរើនរបស់គំរោងដែលមិនបាន ទទួលការវិភាជន៍ថវិកាពីមូលនិធិវិនិយោគខេត្ត (ដូចជាគំរោង ADDESS និងគំរោងរបស់ម្ចាស់ជំនួយផ្សេងៗទៀត)។

### ៤.១.៣ ប្រព័ន្ធនិងគោលការណ៍ណែនាំផ្សេងៗរបស់រដ្ឋាភិបាល និងរបស់កម្មវិធីសិលាដែលមានទំនាក់ទំនងជាមួយខេត្ត

អ្នកដែលចូលរួមក្នុងការអនុវត្តន៍កម្មវិធីសិលា ចាំបាច់ត្រូវតែយល់ដឹង និងអាចអនុវត្តបាននូវរាល់គោលនយោបាយប្រព័ន្ធគ្រប់គ្រង គោលការណ៍ណែនាំ និងទំរង់បែបបទផ្សេងៗទៀតជាច្រើន របស់កម្មវិធីសិលាក៏ដូចជារបស់រដ្ឋាភិបាល សំរាប់ការកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងតាមបែបវិមជ្ឈការនិងវិសហមជ្ឈការ។ សំរាប់ឯកសារណែនាំនេះ គឺត្រូវបានរៀបចំឡើងសំរាប់អ្នកដែលមានការយល់ដឹងខ្លះៗមកហើយលើប្រព័ន្ធទាំងនោះ។ ខាងក្រោមនេះ គឺជាប្រព័ន្ធគ្រប់គ្រងនិងគោលការណ៍ណែនាំសង្ខេបមួយចំនួនដែលបានដាក់អោយប្រើប្រាស់ ព្រមទាំងកន្លែងដែលលោកអ្នកអាចរកបាននូវការបកស្រាយលំអិតលើតួនាទី ការទទួលខុសត្រូវ ការកសាងផែនការ និងប្រព័ន្ធរបាយការណ៍ ជាដើម ។ល។ :-

- **ដំណើរការកសាងផែនការកម្មវិធីសិលាថ្នាក់ខេត្ត :** សូមមើលគោលការណ៍ណែនាំផ្សេងៗ របស់ក្រសួងផែនការនិងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា ដើម្បីយល់អោយបានស៊ីជំរៅទៅលើបែបបទឯកភាព និងទំរង់បែបបទនានា។
- **ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីសិលា :** សូមពិនិត្យមើលឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីសិលា។
- **ប្រព័ន្ធគ្រប់គ្រងទូទៅរបស់កម្មវិធីសិលារួមទាំងការគ្រប់គ្រងបុគ្គលិក:** សូមមើលក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា។
- **ប្រព័ន្ធរបាយការណ៍កម្មវិធីសិលា:** សូមមើលក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា។
- **យុទ្ធសាស្ត្ររបស់កម្មវិធីសិលាសំរាប់បញ្ហាអន្តរវិស័យ :** កម្មវិធីសិលាមាន ឬនឹងមានយុទ្ធសាស្ត្រជាក់លាក់មួយចំនួនសំរាប់ការងារអន្តរវិស័យ (ដូចជាការកាត់បន្ថយភាពក្រីក្រ ការបញ្ជ្រាបយេនឌ័រ និងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន)។
- **ប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា:** មើលក្នុងឯកសារណែនាំស្តីពីប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា ។
- **តារាងទិន្នន័យគ្រប់គ្រងកិច្ចសន្យា :** តារាងទិន្នន័យនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ត្រីមាសលើគ្រប់កិច្ចសន្យាទាំងអស់ដែលទាក់ទងនឹងកម្មវិធីសិលា ហើយដែលគ្រប់គ្រងដោយ គ.អ.ជ.ខ ទោះជាគំរោងនោះ ទទួលបានការវិភាជន៍ថវិកាពី PIF ឬមិនបានទទួលពី PIF ក៏ដោយ ។
- **ប្រព័ន្ធទិន្នន័យឃុំ :** សូមមើលឯកសារណែនាំស្តីពីប្រព័ន្ធទិន្នន័យឃុំ ។

- **ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ :** សូមមើលប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ។
- **ការគ្រប់គ្រងមូលនិធិឃុំ:** សូមមើលអនុក្រឹត្យ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ និងឯកសារណែនាំសំរាប់ការបណ្តុះបណ្តាលលើការគ្រប់គ្រងមូលនិធិឃុំ(ដែលនឹងមាន ចេញឆាប់ៗ)។
- **ដំណើរការអនុវត្តន៍មូលនិធិឃុំ:** ប្រព័ន្ធមួយនេះកំពុងតែបង្កើតឡើងហើយនឹងចេញអោយប្រើប្រាស់ក្នុងពេលឆាប់ៗខាងមុខនេះ។
- **ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៏មានរបស់គំរោង:** សូមមើលឯកសារណែនាំស្តីពីប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៏មានរបស់គំរោង ដែលនឹងចេញក្នុងពេលឆាប់ៗនេះ (បច្ចុប្បន្ន កំពុងបន្តប្រើប្រព័ន្ធទិន្នន័យ LDF រហូតដល់ពេលដែលប្រព័ន្ធទិន្នន័យថ្មីនេះត្រូវបានដាក់អោយប្រើ )។
- **តួនាទីនិងការទទួលខុសត្រូវរបស់ គ.អ.ជ.ខ:** សូមមើលក្នុងប្រកាសស្តីពីរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ គ.អ.ជ.ខ និងគ.ប្រ ព្រមទាំងមើលក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា។

## ៤.២ ការតាមដាន និងវាយតំលៃរបស់កម្មវិធីសិលាថ្នាក់ខេត្ត

ប្រព័ន្ធតាមដាន និងវាយតំលៃភាគច្រើនរបស់កម្មវិធីសិលានៅថ្នាក់ខេត្ត ត្រូវបានបង្កើតឡើងក្នុងដំណាក់កាលទី១ (១៩៩៦-២០០០)របស់កម្មវិធីសិលា។ តែទោះជាបែបនេះក៏ដោយ ចាំបាច់ត្រូវធ្វើការកែតំរូវផ្នែកខ្លះៗ នៃប្រព័ន្ធទាំងនេះ ព្រោះថា កន្លងមកមានការផ្លាស់ប្តូរមួយចំនួន ត្រូវបានធ្វើឡើងនៅថ្នាក់មូលដ្ឋានភូមិឃុំ។ អ្វីដែលយើងត្រូវធ្វើបន្ត ទៀតនោះ គឺត្រូវធ្វើយ៉ាងណាអោយប្រព័ន្ធ M&E របស់កម្មវិធីសិលានៅថ្នាក់ខេត្តមានលក្ខណៈសាមញ្ញ ដើម្បីធ្វើអោយការគ្រប់គ្រងកម្មវិធីសិលាប្រកបទៅដោយលក្ខណៈកាន់តែឯកភាពឡើង។ ក្នុងចំណុចនេះ ភារកិច្ចសំខាន់ៗចំនួន៤ របស់ប្រព័ន្ធ M&E ដូចដែលបានលើកឡើង ក្នុងផ្នែកទី២ ត្រូវបានបកស្រាយយ៉ាងលំអិតដូចខាងក្រោម :-

### ៤.២.១ ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃនៅថ្នាក់ខេត្ត

គោលបំណងរបស់ប្រព័ន្ធ M&E នៅថ្នាក់ខេត្ត គឺមិនខុសពីគោលបំណងរបស់ការតាមដាននិងវាយតំលៃរួមនោះទេ ព្រោះថាវាតាមដានការរីកចំរើនលើការអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ខេត្ត និងវាយតំលៃពីផលប៉ះពាល់របស់សកម្មភាព។ ប្រព័ន្ធ M&E របស់កម្មវិធីសិលានៅថ្នាក់ខេត្ត មិនគួរអោយមានលក្ខណៈលំបាក និង

ទាំងនេះ ដើម្បីអាចយកទៅអនុវត្តបានយ៉ាងត្រឹមត្រូវ។ សំរាប់ឯកសារនេះ សន្មត់ថា អ្នកអានបានយល់ដឹងខ្លះៗហើយ ហើយក៏អាចយកវាទៅអនុវត្តបានត្រឹមត្រូវដែរហើយ។ ខាងក្រោមនេះគឺជាគោលការណ៍ណែនាំនិងប្រព័ន្ធនានាដែលទាក់ទងនឹងកម្មវិធីសិលា និងទីកន្លែងដែលយើងអាចទទួលបានការបកស្រាយលំអិតពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីកម្មវិធី នីតិវិធីកសាងផែនការ និងទំរង់បែបបទរបាយការណ៍ ជាដើម ។ល។

- **ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីសិលា** : សូមពិនិត្យមើលក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីសិលា។
- **ប្រព័ន្ធគ្រប់គ្រងទូទៅរបស់កម្មវិធីសិលា** : សូមមើលក្នុងសៀវភៅណែនាំ ស្តីពីការគ្រប់គ្រងកម្មវិធីសិលា។
- **ប្រព័ន្ធរបាយការណ៍កម្មវិធីសិលា**:សូមមើលក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា ។
- **ប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា** : មើលក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា។
- **ប្រព័ន្ធទិន្នន័យឃុំ** : សូមមើលក្នុងសៀវភៅណែនាំស្តីពីប្រព័ន្ធទិន្នន័យឃុំ។ ប្រព័ន្ធទិន្នន័យនេះត្រូវបានថែរក្សា និងធ្វើបច្ចុប្បន្នភាពជាប្រចាំ នៅថ្នាក់ខេត្ត និងត្រូវបានគ្រប់គ្រង នៅថ្នាក់ជាតិដោយក្រសួងផែនការ រួមជាមួយការផ្តល់យោបល់ពីថ្នាក់ឃុំ។
- **ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ** : សូមមើលប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ និងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ។
- **ការគ្រប់គ្រងមូលនិធិឃុំ** : សូមមើលអនុក្រិត្យ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ និងសៀវភៅមគ្គុទេសសំរាប់ការបណ្តុះបណ្តាលលើការគ្រប់គ្រងមូលនិធិឃុំ (ដែលនឹងមាន ចេញឆាប់ៗ)។
- **ដំណើរការអនុវត្តន៍មូលនិធិឃុំ**: ប្រព័ន្ធមួយនេះកំពុងតែបង្កើតឡើង ហើយនឹងចេញអោយប្រើប្រាស់ក្នុងពេលឆាប់ៗខាងមុខនេះ ។
- **ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង** : សូមមើលសៀវភៅណែនាំស្តីពីប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង ដែលនឹងចេញក្នុងពេលឆាប់ៗនេះ (បច្ចុប្បន្ន កំពុងបន្តប្រើប្រព័ន្ធទិន្នន័យ LDF រហូតដល់ពេលដែលប្រព័ន្ធទិន្នន័យថ្មីនេះត្រូវបានដាក់អោយប្រើ )។

- **តួនាទី និងការទទួលខុសត្រូវរបស់ គ.អ.ជ.ខ:** សូមមើលក្នុងប្រកាសស្តីពីរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់ គ.អ.ជ.ខ និង គ.ប្រ ព្រមទាំងមើលក្នុងសៀវភៅណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា។
- **តារាងទិន្នន័យគ្រប់គ្រងកិច្ចសន្យា :** តារាងទិន្នន័យនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពរៀងរាល់ត្រីមាសលើគ្រប់កិច្ចសន្យាទាំងអស់ដែលទាក់ទងនឹងកម្មវិធីសិលា ហើយដែលគ្រប់គ្រងដោយ គ.អ.ជ.ខទោះជាគំរោងនោះ ទទួលបានវិភាជន៍ពី PIF ឬមិនបានទទួលពី PIF ក៏ដោយ។

## ៣.២ ការតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ

ប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ គឺទើបតែត្រូវបានបង្កើតឡើងថ្មីៗនេះប៉ុណ្ណោះ។ វាទើបតែបានបង្កើតឡើង ក្នុងដំណាក់កាលបច្ចុប្បន្នរបស់កម្មវិធី ហើយនៅមានផ្នែកខ្លះទៀតនៃប្រព័ន្ធនេះ នៅមិនទាន់បានបង្កើតឡើងចប់សព្វគ្រប់នៅឡើយ។ ក្នុងផ្នែកតូចនេះ ភារកិច្ចសំខាន់ៗចំនួន៤របស់ប្រព័ន្ធតាមដាននិងវាយតំលៃ ដូចដែលបានលើកឡើងក្នុងផ្នែកទី២ នៃឯកសារនេះ ត្រូវបានបកស្រាយលំអិតនៅទីនេះ។

### ៣.២.១. ការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃកម្មវិធីសិលា នៅថ្នាក់ជាតិ

**គោលបំណង**របស់ប្រព័ន្ធតាមដាននិងវាយតំលៃកម្មវិធីសិលានៅថ្នាក់ជាតិ គឺមិនខុសគ្នា ពីគោលបំណងរួមរបស់ប្រព័ន្ធតាមដាននិងវាយតំលៃនោះទេ។ **គោលបំណង**របស់វា គឺដើម្បីតាមដានការរីកចំរើន ការអនុវត្តន៍កម្មវិធីសិលា ពីទស្សនវិស័យថ្នាក់ជាតិ។ មានន័យថា គឺត្រូវគ្រប់ដណ្តប់ទាំងលើសកម្មភាព ថ្នាក់ជាតិ ដោយសង្ខេបពីអ្វីដែលបានកើតឡើងនៅថ្នាក់ខេត្ត និងវាយតំលៃពីផលប៉ះពាល់នៃសកម្មភាពទាំងនោះ។

តំរូវការពត៌មាននៅថ្នាក់ជាតិ គឺមានគ្រប់ប្រភេទទាំងអស់ ដូចដែលបានកំណត់នៅក្នុងផ្នែកទី២។ពត៌មានទាំងនោះ គឺស្តីពីការកសាងផែនការ និងការវិភាជន៍ធនធាន ការអនុវត្តន៍កិច្ចសន្យា ឬគំរោង ព្រមទាំងការរីកចំរើនរបស់វា ការកសាងសមត្ថភាព ផលប៉ះពាល់ ការអនុវត្តន៍តាមគោលការណ៍ណែនាំ និង

ប្រព័ន្ធនានា ព្រមទាំងដំណើរការរបស់វា ការគ្រប់គ្រង ភាពជាដៃគូនិងការសំរបសំរួល និងស្តីពីគោលនយោបាយ និងការវិភាគ។

ការរីកចំរើនលើការអនុវត្តន៍គំរោង និងសមិទ្ធិផលនានា ព្រមទាំងផលប៉ះពាល់ ត្រូវបានតាមដាន និងវាយតំលៃដោយប្រើសូចនាករមួយឈុត។ តារាងនៅលើទំព័របន្ទាប់នេះ បកស្រាយពីតំរូវការពត៌មានទាំងនេះ អោយទៅជា**សូចនាករសំខាន់ៗរបស់កម្មវិធីសិលាថ្នាក់ជាតិ** ព្រមទាំង**មធ្យោបាយផ្ទៀងផ្ទាត់**។

## ឋានានុក្រមទិសដៅ សូចនាករនិងមធ្យោបាយផ្ទៀងផ្ទាត់របស់កម្មវិធីសិលានៅថ្នាក់ជាតិ

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|
| **គោលដៅ: រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈអភិបាលកិច្ចល្អ** | | | |
| ១. ការកាត់បន្ថយលើកំរិតភាពក្រីក្រនៅថ្នាក់ជាតិ<br>២.ការកាត់បន្ថយភាពខុសគ្នានៃកំរិតក្រីក្ររវាងបុរស និងស្ត្រី | កម្មវិធី មិនមានគោលបំណងជាពិសេសក្នុងការតាមដាន និងវាយតំលៃលើការចូលរួមរបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រទេ។ ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា នឹងត្រូវបានតាមដាននិងវាយតំលៃដោយភាគីផ្សេងៗ។ | | |
| **ទិសដៅ: រៀបចំប្រព័ន្ធ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការនានា ដើម្បីគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព** | | | |
| ១. បទពិសោធន៍ខាងវិមជ្ឈការនិងវិសហមជ្ឈការរបស់កម្មវិធីសិលា ត្រូវបានលើកឡើងនៅក្នុងលិខិតបទដ្ឋានគតិយុត្តិនានា | ច្បាប់ ប្រកាស ក្រឹត្យ អនុក្រឹត្យ គោលការណ៍ណែនាំ ។ល។ | STFS | ប្រមូល និង រៀបចំឯកសារលើការចូលរួមរបស់កម្មវិធីសិលា |
| ២. ប្រព័ន្ធកសាងផែនការ រៀបចំថវិកា លទ្ធកម្ម និងការអនុវត្តន៍គំរោងនានាដែលទទួលការគាំទ្រពីមូលនិធិឃុំ និងរបាយការណ៍ តាមបែបវិមជ្ឈការ ត្រូវបានអនុវត្តនៅគ្រប់ឃុំ។ | តារាងទិន្នន័យតាមដានសង្ខេប ស្តីពីការអនុវត្តន៍របស់ឃុំ នៅថ្នាក់ជាតិ | DoLA (ផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិងដាក់បញ្ចូលទៅក្នុងតារាងតាមដាន។ថ្នាក់ជាតិត្រូវធ្វើការសង្ខេបដោយប្រើ តារាងទិន្នន័យទាំងនេះ។ |
| ៣.ប្រព័ន្ធ និងរចនាសម្ព័ន្ធគាំទ្រដល់ការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម និងការអនុវត្តន៍គំរោងមូលនិធិឃុំព្រមទាំងរបាយការណ៍តាមបែបវិមជ្ឈការ ពីត្រូវបានអនុវត្តនៅគ្រប់ខេត្ត | របាយការណ៍ពីក្រសួងស្តីពីការអនុវត្តន៍វិមជ្ឈការ | PMEU (ផ្អែកលើរបាយការណ៍ពី MoP, MEF, MoI, MRD, និង NCSC) | របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ម្តងម្កាល |
| ៤. ការឆ្លើយតបតាមតំរូវការនៃអាទិភាពដែលបានកំណត់នៅក្នុង ផែនការអភិវឌ្ឍន៍ឃុំ បានកើនឡើងប្រចាំឆ្នាំ តាមរយៈកិច្ចសន្យាបណ្តោះអាសន្ន | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | PMEU | ការចងក្រងនូវរាល់លទ្ធផលរបស់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក របស់គ្រប់ខេត្តក្រុង |

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
| --- | --- | --- | --- |
| ៥. ចំនួនកិច្ចសន្យាបណ្ដោះអាសន្ន ដែលបានចុះហត្ថលេខាដោយមន្ទីរ និងNGO ជាមួយឃុំនៅឯសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក មានការកើនឡើង | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | PMEU | ការចងក្រងនូវរាល់លទ្ធផលរបស់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក របស់គ្រប់ខេត្តទាំងអស់ |
| ៦. ចំនួនស្ត្រីដែលមានតំណែងជាអ្នកដឹកនាំ នៅថ្នាក់ឃុំនិងនៅថ្នាក់ខេត្ត មានការកើនឡើង | ចំនួនសរុបនៃស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ និងដែលជាសមាជិក PBC នៅថ្នាក់ជាតិ។ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ចងក្រងទិន្នន័យដែលបានប្រមូលនៅគ្រប់ខេត្ត |
| | ចំនួនស្ត្រីសង្ខេបសរុប ដែលមាននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ខេត្ត | POU | កំណត់ហេតុរបស់បុគ្គលិកកម្មវិធីសិលា |
| ៧. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយមូលនិធិឃុំ | MEF ធ្វើសេចក្ដីសំរេចចិត្តលើការចូលរួមរបស់រដ្ឋាភិបាលក្នុងមូលនិធិឃុំ | MEFនិងគណៈកម្មាធិការមូលនិធិឃុំ | ប្រកាសប្រចាំឆ្នាំស្ដីពីការចូលរួមរបស់រដ្ឋាភិបាលក្នុងមូលនិធិឃុំ |
| ៨. ចំណូលបុគ្គលជាមធ្យម ត្រូវបានផ្ទេរតាមរយៈមូលនិធិឃុំ | ការវិភាជន៍របស់មូលនិធិឃុំ និងតួលេខប្រជាពលរដ្ឋរបស់ឃុំ | MEF និង MoP | អត្រានៃការវិភាជន៍មូលនិធិឃុំ និង ចំនួនប្រជាពលរដ្ឋសរុប |
| ៩. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយខេត្តសំរាប់ជាទុនលើឡើយកទៅ អនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ | MEFធ្វើសេចក្ដីសំរេចចិត្តលើការចូលរួមរបស់រដ្ឋាភិបាលក្នុងការគាំទ្រដល់ការវិនិយោគខេត្តតាមរយៈវិសហមជ្ឈការ | MEF | ប្រកាសរបស់MEF |

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|
| ១០.ចំណូលបុគ្គលជាមធ្យមត្រូវបានផ្ទេរតាមរយៈ PIF ដោយខេត្តនីមួយៗ | ការវិភាជន៍របស់ PIF និងតួលេខសរុបនៃប្រជាពលរដ្ឋក្នុងខេត្ត | POU | អត្រា PIF និងចំនួនប្រជាពលរដ្ឋក្នុងខេត្តនីមួយៗ |
| ១១.ចំនួនធនធានដែលបានគ្រប់គ្រងប្រចាំឆ្នាំដោយរាជធានីខេត្តដែលប្រើប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ ដែលបានបង្កើតឡើងដោយកម្មវិធីសិលា | របាយការណ៍ពី MEF និងម្ចាស់ជំនួយ | MEF និងម្ចាស់ជំនួយ | ប្រកាស កំណត់ហេតុ និងការព្រមព្រៀងទាក់ទងគ្នា |
| ១២. ចំណូលផ្ទាល់ខ្លួនរបស់ឃុំ និងខេត្ត | កំណត់ហេតុរបស់ MEF និងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំរបស់ខេត្ត និងឃុំ នៅថ្នាក់ជាតិ | MEF និងរាជធានីខេត្ត | ប្រកាស កំណត់ហេតុ និងការព្រមព្រៀងទាក់ទងគ្នា |
| **លទ្ធផលទី១: ស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ ត្រូវបាន ពង្រឹង ហើយប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការត្រូវបានអនុវត្តន៍ ប្រកបដោយប្រសិទ្ធិភាព** | | | |
| ១. នៅត្រីមាសចុងក្រោយនៃឆ្នាំនីមួយៗ ឃុំទាំងអស់ត្រូវរៀបចំផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគឃុំ និង ថវិកាប្រចាំឆ្នាំ | តារាងទិន្នន័យតាមដានសង្ខេបរបស់ឃុំ នៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិងដាក់បញ្ចូលទៅក្នុងតារាងតាមដាន។ថ្នាក់ជាតិត្រូវធ្វើការសង្ខេបដោយប្រើ តារាងទិន្នន័យទាំងនេះ។ |
| ២. ភាគរយនៃផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ និង ថវិកាប្រចាំឆ្នាំ ដែលត្រូវបានពិនិត្យលើនីត្យានុកូលភាព ដោយអភិបាលខេត្ត | របាយការណ៍វាយតំលៃរបស់ខេត្តលើ CDP/CIP និងថវិកាឃុំ នៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ការវាយតំលៃលើ CDP/CIP និងថវិកាឃុំ |
| ៤. ចំនួនក្រុមប្រឹក្សាឃុំ/បុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនីតិវិធី ព្រមទាំងទំហំនៃវគ្គបណ្តុះបណ្តាល | លទ្ធផលសង្ខេបពីតារាងទិន្នន័យតាមដានរបស់ឃុំ នៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិងដាក់បញ្ចូលទៅក្នុងតារាងតាមដាន។ថ្នាក់ជាតិត្រូវធ្វើការសង្ខេបដោយប្រើ តារាងទិន្នន័យទាំងនេះ។ |

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|
| | របាយការណ៍បណ្តុះបណ្តាល | POU (ផ្អែកលើពត៌មានពី MEF, MoP, MoI, MRD, និង NCSC) | របាយការណ៍ |
| ៥. ចំនួនបុរស និងស្ត្រីនៅថ្នាក់ស្រុក និងថ្នាក់ខេត្តដែលបានទទួលការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនីតិវិធី ព្រមទាំងទំហំនៃការបណ្តុះបណ្តាល | SCD | POU | សូមមើលសៀវភៅណែនាំ SCD |
| | របាយការណ៍បណ្តុះបណ្តាល | POU (ផ្អែកលើពត៌មានពី MEF, MoP, MoI, MRD, និង NCSC) | របាយការណ៍ |
| ៦. ចំនួនបុរស និងស្ត្រីនៅថ្នាក់ខេត្ត និងស្រុក ដែលបានផ្តល់ការគាំទ្រដល់ឃុំ | ការសង្ខេបរបស់ថ្នាក់ជាតិស្តីពីកំរិតបុគ្គលិកគាំទ្រខេត្ត | POU | កំណត់ហេតុរបស់បុគ្គលិក |
| ៧. ភាពញឹកញាប់នៃការគាំទ្ររបស់ថ្នាក់ខេត្ត ទៅរោយថ្នាក់ឃុំ | របាយការណ៍សង្ខេប ប្រចាំឆ្នាំរបស់ POLA | DoLA (ដោយផ្អែកលើពត៌មានពី POLA) | របាយការណ៍ប្រចាំឆ្នាំរបស់ POLA |
| ៨. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ការបញ្ជ្រាបយេនឌ័រ | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិលា | POU | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធីសិលា ដែលបានរៀបចំ |
| | ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មាន របស់គំរោង (PID) | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| ៩. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិលា | POU | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធីសិលា ដែលបានរៀបចំ |

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|
| | ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មាន របស់គំរោង (PID) | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| ១០. ចំនួន និងស្ថានភាពនៃកិច្ចសន្យារបស់ក្រសួង ដែលកំពុងអនុវត្ត | SCD | POU | សូមមើលសៀវភៅណែនាំ SCD |
| **លទ្ធផលទី២ ៖ សេវាកម្ម និងការវិនិយោគប្រកប ដោយគុណភាព និងប្រសិទ្ធភាពត្រូវ បានផ្តល់ដើម្បីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន** | | | |
| ១. ចំនួន និងស្ថានភាពនៃកិច្ចសន្យា/គំរោងដែលប្រើប្រាស់មូលនិធិឃុំ ដែលកំពុងអនុវត្ត ស្របទៅតាម CDP | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| ២.ភាគរយនៃការទូទាត់ចុងក្រោយទៅអោយអ្នកម៉ៅការ ដែលធ្វើគំរោងក្រោមមូលនិធិឃុំ ក្នុងរយៈពេល១២ខែ នៃការអនុម័តលើថវិកាឃុំ | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| ៣. ការវាយតំលៃលើផលប៉ះពាល់របស់គំរោងធំៗ ដែលទទួលមូលនិធិឃុំ | ការអង្កេតលើទិន្នន័យបន្ទាត់ដ្ឋាន ស្តីពីសេដ្ឋកិច្ច សង្គម និងការតាមដានបន្ត | PMEU | របាយការណ៍អង្កេត |
| ៤. ការវាយតំលៃពីផលប៉ះពាល់របស់គោលនយោបាយវិមជ្ឈការលើជីវភាព យេនឌ័រ និងភាពងាយរងគ្រោះ | ការអង្កេតលើទិន្នន័យបន្ទាត់ដ្ឋាន ស្តីពីសេដ្ឋកិច្ច សង្គម និងការតាមដានបន្ត | PMEU | របាយការណ៍អង្កេត |
| ៥. ភាគរយនៃគំរោងដែលគាំទ្រដោយមូលនិធិឃុំ ដែលមានគុណភាពបច្ចេកទេសល្អតាមស្តង់ដា | សវនកម្មបច្ចេកទេស | STFS | សូមមើលសៀវភៅណែនាំ PID |

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|
| ៦.ការយល់ដឹងរបស់បុរសនិងស្ត្រីបានកើនឡើង លើភាពសមស្រប ទំនាក់ទំនងនិងគុណភាពនៃសេវាកម្មនិងវិនិយោគសំរាប់គំរោងដែលគាំទ្រដោយមូលនិធិឃុំ និង PIF | ការអង្កេតលើការពេញចិត្តរបស់អ្នកទទួលផល | PMEU | កំណត់តាមក្រោយ |
| ៧.ចំនួន និងស្ថានភាពនៃកិច្ចសន្យាខេត្តដែលកំពុងអនុវត្ត | SCD | POU | សូមមើលសៀវភៅណែនាំ SCD |
| **លទ្ធផលទី ៣: រួមចំណែកកែលំអគោលនយោបាយជាតិ និងបទបញ្ញត្តិនានាសំរាប់ វិមជ្ឈការ វិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ** | | | |
| ១.ប្រព័ន្ធ របនាសម្ព័ន្ធ និងនីតិវិធិ ត្រូវបានធ្វើការកែលំអប្រសិទ្ធភាពជាបន្តដោយការពិនិត្យសារឡើងវិញ និងការវាយតំលៃ | ការពិនិត្យពីពេលទៅពេលលើការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម ការអនុវត្តន៍ និងប្រព័ន្ធគ្រប់គ្រង | STFS | ការវាយតំលៃនិងវិភាគលើប្រព័ន្ធ |
| ២. សិក្ខាសាលាថ្នាក់ជាតិដោយផ្តោតទៅលើការត្រួតពិនិត្យជាទៀងទាត់លើប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការរបស់រដ្ឋាភិបាល និងកម្មវិធីសិលា | របាយការណ៍សិក្ខាសាលា | STFS | ការវិភាគលើរបាយការណ៍ |
| ៣. បទពិសោធន៍លើវិមជ្ឈការនិងវិសហមជ្ឈការ ដែលបានមកពីកម្មវិធីសិលានោះ បានយកទៅប្រើ សំរាប់បង្កើតគោលនយោបាយថ្នាក់ជាតិ | ការវិភាគលើរបាយការណ៍ ប្រកាស កំណត់ហេតុនិងគោលនយោបាយរបស់ក្រសួង និងសន្ទរកថា ជាផ្លូវការរបស់មន្ត្រីរដ្ឋាភិបាល | PMEU | ការវិភាគលើឯកសារ |
| ៤. បទពិសោធន៍របស់កម្មវិធីសិលាលើបញ្ហាអន្តរវិស័យ (ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងការបញ្ជ្រាបយេនឌ័រ) នឹងត្រូវបានលើកឡើងក្នុងគោលនយោបាយ និងការអនុវត្តន៍ | សេចក្តីថ្លែងការ របាយការណ៍ប្រជុំ ការសិក្សាវាយតំលៃ | PMEU | ការត្រួតពិនិត្យឡើងវិញ |

| | | | |
|---|---|---|---|
| ៥. ការសន្ទនាជាយុទ្ធសាស្ត្រលើវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានណែនាំ ដោយពិសោធន៍របស់កម្មវិធីសិលា | របាយការណ៍សិក្សាជាយុទ្ធសាស្ត្រ | PMEU | ការវិភាគលើរបាយការណ៍ |
| | របាយការណ៍វេទិកាកម្មវិធីសិលា | STFS | ការវិភាគលើរបាយការណ៍ |
| ៦. ចំណេះដឹង អាកប្បកិរិយា ការអនុវត្តណ៍ និងជំនឿ បានធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចមូលដ្ឋានល្អ | ការអង្កេតលើ KAP និងជំនឿ | PMEU | ការសិក្សា និងការអង្កេត |

## ៣.២.២. ការប្រមូលទិន្នន័យ និងគ្រប់គ្រងពត៌មាន

នៅពេលដែលសូចនាករ ត្រូវបានជ្រើសរើស និងមធ្យោបាយផ្ទៀងផ្ទាត់ ព្រមទាំងប្រភពទិន្នន័យត្រូវបានកំណត់ហើយនោះ បន្តមកទៀត ចាំបាច់ត្រូវកំណត់ថាតើ សកម្មភាពអ្វីខ្លះ ដែលត្រូវអនុវត្ត ដើម្បីប្រមូលទិន្នន័យដែលយើងចង់បាន។

តារាងខាងក្រោមនេះ បានប្រមូលផ្តុំ ឧបករណ៍និងវិធីសាស្ត្រតាមដាននិងវាយតំលៃដែលនឹងត្រូវ ប្រើប្រាស់ទៅតាមប្រភេទ។ ពត៌មាន និងការបកស្រាយបន្ថែម ស្តីពីឧបករណ៍និងវិធីសាស្ត្រផ្សេងៗទៀត គឺមាននៅក្នុងផ្នែកទី៦ និងផ្នែកទី៧។

| ប្រភេទ | ឧបករណ៍ និងវិធីសាស្ត្រតាមដាន និងវាយតំលៃរបស់កម្មវិធីសិលាថ្នាក់ជាតិ |
|---|---|
| **ប្រព័ន្ធទិន្នន័យ/ តារាងទិន្នន័យ** | ■ ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង<br>■ ប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា<br>■ ប្រព័ន្ធទិន្នន័យឃុំ<br>■ តារាងតាមដានសកម្មភាពសំខាន់ៗដែលកើតមានឡើងនៅក្នុងឃុំ |
| **ការប្រមូល និងការវិភាគទិន្នន័យទី២** | ■ ការអង្កេតពីសេដ្ឋកិច្ចសង្គមរបស់ក្រសួងផែនការ<br>■ របាយការណ៍តាមដានលើការកាត់បន្ថយភាពក្រីក្រ និងការគាំទ្រគំរោង (គំរោងដែលគាំទ្រដោយ UNDP ទៅដល់ក្រសួងផែនការ)<br>■ ប្រព័ន្ធតាមដានភាពក្រីក្រ របស់ថ្នាក់ជាតិ<br>■ ឯកសាររបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ (ថវិកា កិច្ចព្រមព្រៀង និងរបាយការណ៍ចំណាយ)<br>■ លេខកូដភូមិសាស្ត្ររបស់ប្រទេសកម្ពុជានៅថ្នាក់ជាតិ ប្រកាស ក្រិត្យ អនុក្រិត្យ កំណត់ហេតុរបស់ក្រសួង និងសេចក្តីថ្លែងគោលនយោបាយ និងសន្ទរកថារបស់មន្ត្រីរដ្ឋាភិបាល ។ល។ |

| | |
|---|---|
| **របាយការណ៍** | ■ របាយការណ៍ហិរញ្ញវត្ថុប្រចាំខែរបស់ភ្នាក់ងារអនុវត្តថ្នាក់ជាតិ (STFS )<br>■ របាយការណ៍ហិរញ្ញវត្ថុប្រចាំខែរបស់កម្មវិធីសិលា<br>■ របាយការណ៍ប្រចាំត្រីមាសរបស់ភ្នាក់ងារអនុវត្ត នៅថ្នាក់ជាតិ (រួមទាំងរបាយការណ៍ទស្សនកិច្ច សិក្ខាសាលា ការវិភាគ ឬឯកសារផ្សេងៗទៀត)<br>■ របាយការណ៍ប្រចាំត្រីមាសរបស់កម្មវិធីសិលា<br>■ របាយករណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសរបស់កម្មវិធីសិលា (ទៅ UNDP)<br>■ ការប្រជុំវេទិការសេរីរបស់កម្មវិធីសិលា<br>■ បទឧទ្ទេសនាម៦ខែម្តងរបស់កម្មវិធីសិលា ជូនក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី<br>■ របាយការណ៍ប្រចាំឆ្នាំរបស់កម្មវិធីសិលា និង<br>■ របាយការណ៍បញ្ចប់គំរោងរបស់ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ |
| **ការពិនិត្យឡើងវិញ** | ■ ពិនិត្យឡើងវិញលើប្រព័ន្ធកសាងផែនការ<br>■ ពិនិត្យឡើងវិញលើប្រព័ន្ធហិរញ្ញវត្ថុ<br>■ ពិនិត្យឡើងវិញលើប្រព័ន្ធ M&E និងរបាយការណ៍<br>■ ពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រង<br>■ ពិនិត្យលើការអនុវត្តន៍របស់ឃុំ |
| **ការអង្កេត និងការសិក្សា** | ■ ការអង្កេតលើ KAP និងជំនឿ<br>■ ការអង្កេតលើគំរោង និងអ្នកទទួលផលពីគំរោង<br>■ ការសិក្សាវាយតំលៃ<br>■ ការសិក្សាលើផលប៉ះពាល់ |
| **សវនកម្ម** | ■ សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ<br>■ សវនកម្មបច្ចេកទេស |

### ៣.២.៣. ពិនិត្យយ៉ាងហ្មត់ចត់ដើម្បីកែតម្រូវសកម្មភាព

ទិន្នន័យដែលបានប្រមូល គឺមានផ្ទុកទៅដោយពត៌មានជាច្រើន ដែលអាចជួយអោយយើងវាយតំលៃពីការអនុវត្តន៍គំរោងផ្សេងៗជាច្រើនរបស់កម្មវិធីសិលា។ ពត៌មាននេះ វាក៏អាចជួយអោយយើងកំណត់បាន ថាតើការអនុវត្តន៍គំរោង ស្របទៅតាមផែនការដែរឺទេ។ នៅពេលដែលបានដឹងបែបនេះហើយ អ្នកអនុវត្តន៍គំរោង (ភ្នាក់ងារអនុវត្តន៍នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ) នឹងអាចចាប់ផ្តើមចាត់វិធានការធ្វើអោយប្រសើរឡើងនូវអ្វីដែលអនុវត្តទៅហើយ តែមិនបានល្អ ឬខុសត្រង់ចំណុចណានោះ។

សំរាប់ថ្នាក់ជាតិ សកម្មភាព ឬព្រឹត្តិការណ៍សំខាន់ សំរាប់ការពិនិត្យនេះ គឺការរៀបចំរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆ្នាំ ការរៀបចំសិក្ខាសាលា វេទិកា និងការប្រជុំរបស់កម្មវិធីសិលា ឬ STF ។

### ៣.២.៤. ទំនាក់ទំនង និងការសរសេររបាយការណ៍លទ្ធផល

លទ្ធផលដែលទទួលបានពីការវិភាគទិន្នន័យ បទពិសោធ និងការយល់ដឹងស៊ីជំរៅទៅលើគំរោងដែលបានធ្វើការតាមដាន និងវាយតំលៃ ចាំបាច់ត្រូវធ្វើការផ្សព្វផ្សាយ និងចែករំលែកជាមួយអ្នកដែលត្រូវការ។ ការប្រាស្រ័យទាក់ទង និងការសរសេររបាយការណ៍ពីលទ្ធផល តែងតែត្រូវបានគេចាត់ទុកថាជាកាតព្វកិច្ចចំបងមួយរបស់អ្នកអនុវត្តន៍ ឬអ្នកគ្រប់គ្រងគំរោង ចំពោះមុខអាជ្ញាធរថ្នាក់លើ និង/ឬម្ចាស់ជំនួយ។ ការតាមដាននិងវាយតំលៃរបស់កម្មវិធីសិលានៅថ្នាក់ជាតិ ចាំបាច់ត្រូវផ្តល់យោបល់ត្រលប់ទៅអោយភ្នាក់ងារអនុវត្តន៍ថ្នាក់ខេត្តនិងថ្នាក់ជាតិ ពីការអនុវត្តន៍ការងាររបស់ពួកគេ ដែលធ្វើបែបនេះ ក្នុងករណីចាំបាច់ ពួកគេអាចចាត់វិធានការធ្វើអោយប្រសើរឡើងនូវចំណុចខ្វះខាតទាំងឡាយ និងអាចសំរេចបានលទ្ធផលកាន់តែប្រសើរជាងមុន ក្នុងពេលអនាគត។

## ៣.៣. តួនាទី និងការទទួលខុសត្រូវ លើការតាមដាននិងវាយតំលៃកម្មវិធីសិលាថ្នាក់ជាតិ

ក្រសួង និងស្ថាប័នមួយចំនួនដែលមានកិច្ចសន្យាជាមួយ STF លើការអនុវត្តន៍សកម្មភាពរបស់កម្មវិធី សិលា និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវចូលរួមក្នុងការតាមដាននិងវាយតំលៃនៅថ្នាក់ជាតិ។

### ៣.៣.១. ក្រសួង និងភ្នាក់ងារឬស្ថាប័នថ្នាក់ជាតិដទៃទៀត

មានក្រសួង និងភ្នាក់ងារ/ស្ថាប័នថ្នាក់ជាតិមួយចំនួន ដែលមានកិច្ចសន្យាជាមួយ STF ដើម្បីអនុវត្តសកម្មភាពរបស់កម្មវិធីសិលា។ ក្រសួង ឬស្ថាប័នទាំងនោះ គឺមានជនបង្គោលម្នាក់សំរាប់សំរបសំរួលការងារជាមួយ STF ដែលទទួលខុសត្រូវការតាមដានលើការអនុវត្តន៍កិច្ចសន្យា ព្រមទាំងត្រូវបញ្ជូនរបាយការណ៍រីកចំរើន និងរបាយការណ៍បញ្ចប់គំរោង/កិច្ចសន្យា អោយបានទាន់ពេលវេលាផងដែរ។

ពត៌មានតាមដានដែលជនបង្គោលបានប្រមូល ដំបូង ហើយសំខាន់បំផុត គឺសំរាប់អោយភ្នាក់ងារអនុវត្តន៍ប្រើប្រាស់សំរាប់ការងារផ្ទៃក្នុង ដើម្បីតាមដានការអនុវត្តន៍កិច្ចសន្យា និងដើម្បីវាយតំលៃការរីកចំរើន ធៀបនឹងផែនការសកម្មភាពរបស់ខ្លួន។ ដូចនេះ ជនបង្គោល គួរតែ :

- ជួយតាមដានការអនុវត្តន៍ប្រព័ន្ធ និងនីតិវិធី ដែលចេញដោយរដ្ឋាភិបាល និងកម្មវិធីសិលា របស់មន្ទីរ ស្ថាប័ន ឬភ្នាក់ងារ និងបុគ្គលិក និងត្រូវពិនិត្យមើលថាតើប្រព័ន្ធ និងនីតិវិធីទាំងនោះ មានលក្ខណៈងាយយល់ និងត្រូវបានប្រើប្រាស់ត្រឹមត្រូវដែរឺទេ។ ជនបង្គោលត្រូវ ត្រួតពិនិត្យលើគុណភាពរបស់លទ្ធផលរំពឹងទុករបស់គំរោងផងដែរ។
- ជួយ STFS ក្នុងការរៀបចំការពិនិត្យផ្ទៃក្នុងឡើងវិញលើប្រព័ន្ធ និងនីតិវិធីមួយចំនួន ដែលមានទំនាក់ទំនងជាមួយពួកគេ និងវាយតំលៃថាតើ ប្រព័ន្ធនិងនីតិវិធីទាំងនោះ មានប្រសិទ្ធភាព និងគុណភាពបែបណា ហើយតើគួរផ្តល់អនុសាសន៍អ្វីខ្លះ ដើម្បីធ្វើការកែប្រែ ឬផ្លាស់ប្តូរ។

ក្រសួងមហាផ្ទៃ គឺជាក្រសួងមួយដែលមានកិច្ចសន្យា ជាភ្នាក់ងារអនុវត្តន៍ របស់កម្មវិធីសិលា ហើយដែលកិច្ចសន្យានោះ មានទំហំខុសគ្នាបន្តិចបន្តួចពីកិច្ចសន្យារបស់ក្រសួង ដែលជាអ្នកចូលរួមក្នុងកម្មវិធីសិលានៅថ្នាក់ជាតិផ្សេងៗទៀត។ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) នៃក្រសួងមហាផ្ទៃ ត្រូវមានភារកិច្ច

ជាពិសេសក្នុងការតាមដាន និងគាំទ្រដល់ក្រុមប្រឹក្សាឃុំ។ ជាចំបង អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត (POLA) ជាអ្នកអនុវត្តការកិច្ចទាំងនេះ។ ក្រុមប្រឹក្សាឃុំ និងរបៀបអនុវត្តការងាររបស់ពួកគេ គឺមិនមែនស្ថិតនៅក្នុងក្របខ័ណ្ឌរបស់កម្មវិធីសិលាទៀតនោះទេ តែគឺជាផ្នែកមួយនៃនីតិកម្មថ្នាក់ជាតិ ហើយក្រុមប្រឹក្សាឃុំ ត្រូវអនុវត្តប្រព័ន្ធនិងគោលនយោបាយនានារបស់រដ្ឋាភិបាល។ ប៉ុន្តែសកម្មភាពមួយចំនួន ដែលត្រូវធ្វើនៅថ្នាក់ឃុំ គឺមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា ព្រោះកម្មវិធីសិលា ជាអ្នកផ្តល់ការគាំទ្រនិងជំនួយបច្ចេកទេសដល់ឃុំ ហើយវាយតំលៃលើភាពទំនាក់ទំនង និង ជោគជ័យនៃប្រព័ន្ធនិងគោលនយោបាយនានារបស់កម្មវិធីសិលានិងរបស់រដ្ឋាភិបាលដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការក្នុងប្រទេសកម្ពុជា។

### ៣.៣.២. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (STFS)

អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា មានតួនាទីផ្សេងគ្នាពីរ ក្នុងការតាមដាន និងវាយតំលៃ ក្នុងកម្មវិធីសិលា:

- STFS ទទួលពត៌មានតាមដាន (ជាសង្ខេប) ពីគ្រប់ គ.អ.ជ.ខ និងពី ភ្នាក់ងារ និងស្ថាប័នអនុវត្តថ្នាក់ជាតិទាំងអស់ដែលអនុវត្តសកម្មភាពរបស់កម្មវិធីសិលា។ ពត៌មានតាមដានទាំងនេះ ជាទូទៅគឺរបាយការណ៍ទៀងទាត់ និងប្រព័ន្ធទិន្នន័យដែលកម្មវិធីប្រើប្រាស់។ STFSត្រូវប្រមូលនិងរៀបចំពត៌មានទាំងនេះ ដើម្បីវាយតំលៃលើការរីកចំរើនទូទៅលើការអនុវត្តន៍ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិលា និងត្រូវលើកឡើងនូវបញ្ហានានា ដែលបាន លើកឡើងដោយអ្នកអនុវត្តកម្មវិធីនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។
- STFS ត្រូវតាមដាននិងវាយតំលៃលើសកម្មភាពរបស់ខ្លួន ដើម្បីទទួលបានពត៌មានបន្ថែមទៀត ដែលអាចជួយអោយ STFS ខ្លួនឯង គ្រប់គ្រងកម្មវិធីសិលា អោយកាន់តែល្អប្រសើរជាងមុន និងដើម្បីវាយតំលៃលើសមិទ្ធិផលនៃទិសដៅរួមរបស់កម្មវិធីសិលា។

នាយកដ្ឋានរបស់ STFS ត្រូវប្រមូលសរុបនូវរាល់ពត៌មាន និងរបាយការណ៍ទាំងអស់ ហើយបញ្ជូនរបាយការណ៍រីកចំរើនជាទៀងទាត់ទៅ STF ព្រមទាំងត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍ ដើម្បីដាក់ជូនទៅ STF ធ្វើការពិនិត្យនិងអនុម័ត ដើម្បីដាក់ជូនទៅរដ្ឋាភិបាលនិងម្ចាស់ជំនួយ។ របាយការណ៍ដែល ត្រូវដាក់ជូនទៅ

STF នោះ គឺរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ របាយការណ៍រីកចំរើនប្រចាំត្រីមាស និង របាយការណ៍ប្រចាំឆ្នាំ របស់កម្មវិធីសិលា។

ភារកិច្ចសំខាន់ៗបំផុតក្នុងការតាមដាននិងវាយតំលៃរបស់ អគ្គលេខាធិការនៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងមន្ត្រីផ្សេងៗទៀត មានដូចខាងក្រោម :

**អគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា :**

- ប្រព័ន្ធគ្រប់គ្រងទាំងអស់របស់កម្មវិធីសិលា ដូចជា ប្រព័ន្ធកសាងផែនការ ហិរញ្ញវត្ថុ កិច្ចសន្យា តាមដាននិងវាយតំលៃ និងរបាយការណ៍ ត្រូវបានរក្សាទុកជាឯកសារ ពិនិត្យជាប្រចាំ កែសំរួលស្របទៅតាមគោលនយោបាយរបស់ថ្នាក់ជាតិ ស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងត្រូវបានអនុវត្ត។
- យុទ្ធសាស្ត្រទាំងអស់របស់កម្មវិធីសិលា ទាក់ទងទៅនឹងវិមជ្ឈការ វិសហមជ្ឈការ អភិបាលកិច្ចល្អ ការកាត់បន្ថយភាពក្រីក្រ ការបញ្ជ្រាបយេនឌ័រ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងសហប្រតិបត្តិការបច្ចេកទេស ត្រូវបានបង្កើតឡើង ត្រូវបានរៀបចំផែនការ និងអនុវត្តប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពខ្ពស់។
- ប្រព័ន្ធតាមដាននិងវាយតំលៃ បានផ្តល់នូវពត៌មានសមស្រប សំរាប់ការគ្រប់គ្រង ការវាយតំលៃ ការសំរេចចិត្ត និងសំរាប់ការគាំទ្រលើគោលនយោបាយ។
- រាយការណ៍ជូនទៅក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី និងម្ចាស់ជំនួយ អោយបានទាន់ពេលវេលា

**ប្រធាននាយកដ្ឋានប្រតិបត្តិ**

- កិច្ចសន្យា និងការព្រមព្រៀងទាំងអស់ ត្រូវបានអនុវត្ត ស្របទៅតាមប្រព័ន្ធ និងនីតិវិធីនានា របស់កម្មវិធីសិលា ដែលបានអនុម័តដោយ STF។
- ប្រព័ន្ធគ្រប់គ្រងពត៌មានរបស់កម្មវិធីសិលា ផ្តល់ពត៌មានគ្រប់គ្រាន់ ដើម្បីធ្វើអោយការគ្រប់គ្រង ការធ្វើសេចក្តីសំរេចចិត្តលើការអនុវត្តន៍កម្មវិធីសិលា (រួមមាន បុគ្គលិក និងសារពើភ័ណ្ឌ) ប្រកបដោយប្រសិទ្ធភាព។

- រៀបចំរបាយការណ៍ ស្របទៅនឹងកិច្ចព្រមព្រៀងហិរញ្ញវត្ថុរបស់កម្មវិធីសិលា ដើម្បីដាក់ជូន សុំអនុម័តភាពពីអគ្គលេខាធិការនៃ STF និង/ឬ STF។
- របាយការណ៍រីកចំរើន ធៀបទៅនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀង ដែលបានធ្វើពី គ.អ.ជ.ខ និង ពីក្រសួង ដែលត្រូវបានរៀបចំតាមនីតិវិធីរបាយការណ៍ត្រូវបានវិភាគ ហើយយោបល់ត្រលប់ ត្រូវបានផ្តល់ទៅអោយខេត្ត និង/ឬ ថ្នាក់ជាតិវិញ ទៅតាមពេលវេលាកំណត់។
- សំរបសំរួលជាប្រចាំ ជាមួយស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ទាក់ទងទៅនឹងបញ្ហាទាំងឡាយក្នុងការអនុវត្តន៍កម្មវិធី។
- រៀបចំផែនការសកម្មភាព និងរបាយការណ៍ តាមតំរូវការ។

## មន្ត្រីគ្រប់គ្រងកិច្ចសន្យា

- រក្សាប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យារបស់កម្មវិធីសិលា (SCD) និងសរសេររបាយការណ៍ ជាប្រចាំដាក់ជូនទៅ STF និងថ្នាក់ខេត្ត។
- ធានាថា SCD របស់ខេត្ត ត្រូវបានដំឡើង និងថែរក្សាយ៉ាងត្រឹមត្រូវ នៅក្នុងខេត្តទាំងអស់ និងធ្វើដំណើរដើម្បីទៅជួយដល់ខេត្តតាមការចាំបាច់។
- ពិនិត្យឡើងវិញលើរបាយការណ៍រីកចំរើន ស្តីពីការអនុវត្តន៍កិច្ចសន្យា ដែលខេត្ត និងថ្នាក់ជាតិ ធ្វើមក និងត្រូវធានាថា ទិន្នន័យ និងពត៌មាន ត្រូវបានបញ្ចូលយ៉ាងត្រឹមត្រូវក្នុង SCD ។
- ធានាថា ការពិនិត្យឡើងវិញលើប្រព័ន្ធគ្រប់គ្រងកិច្ចសន្យា រួមមាន ទំរង់បែបបទ គោលការណ៍ណែនាំ និងនីតិវិធីនានា ត្រូវបានធ្វើឡើង និងផ្តល់អនុសាសន៍ ដើម្បីធ្វើអោយប្រសើរឡើងដល់ការអនុវត្តន៍ប្រព័ន្ធ និងនីតិវិធីទាំងនោះ។

## មន្ត្រីហិរញ្ញវត្ថុ

- ថែរក្សាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់ STFS រួមមាន ការតាមដាន និងរបាយការណ៍
- ចុះទស្សនកិច្ចតាមដានទៅដល់ខេត្តជាប្រចាំ ដើម្បីធានាថានីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ មានលក្ខណៈងាយស្រួលយល់ និងត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ និងដើម្បីកំណត់តំរូវការ សំរាប់ការបណ្តុះបណ្តាល បន្ថែម។

- រៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដើម្បីផ្សព្វផ្សាយ ក្រោមអាជ្ញាប័ណ្ណរបស់ STF ហើយដាក់ជូនទៅអគ្គលេខាធិការ នៃ គ.ជ.ន.ស តាមរយៈប្រធាននាយកដ្ឋានប្រតិបត្តិ។

## មន្ត្រីបណ្តុះបណ្តាល និងផ្សព្វផ្សាយ

- ត្រូវបង្កើត ផ្តល់ការបណ្តុះបណ្តាល ពិនិត្យឡើងវិញ លើមេរៀនបណ្តុះបណ្តាលស្តីពី រចនាសម្ព័ន្ធប្រព័ន្ធ និងនីតិវិធីរបស់កម្មវិធីសិលា ដោយសហការយ៉ាងជិតស្និតជាមួយភាគីពាក់ព័ន្ធ។
- ជួយគ.ប្រ នៃ គ.អ.ជ.ខ ក្នុងការវាយតំលៃពីតំរូវការបណ្តុះបណ្តាលសំរាប់មន្ត្រីរដ្ឋាភិបាលរបស់កម្មវិធីសិលាថ្នាក់ខេត្ត តាមការស្នើសុំ។
- ផ្តល់វគ្គបណ្តុះបណ្តាលលើប្រព័ន្ធ និងនីតិវិធីនានារបស់កម្មវិធីសិលា ដល់ភ្នាក់ងារអនុវត្តកម្មវិធីសិលានៅថ្នាក់ជាតិ តាមការស្នើសុំ។
- ធានាថា ពត៌មានស្តីពីការបណ្តុះបណ្តាលដែលត្រូវបញ្ចូលក្នុងSCD ត្រូវបានថែរក្សានៅថ្នាក់ជាតិ
- រៀបចំរបាយការណ៍ស្តីពីការរីកចំរើននិងបញ្ហានានា ជុំវិញការអនុវត្តន៍យុទ្ធសាស្ត្រកសាងសមត្ថភាពរបស់កម្មវិធីសិលា ដើម្បីដាក់ជូនទៅ STF។
- ធានាថា ពត៌មានស្តីពីការបណ្តុះបណ្តាល ដែលខេត្តបញ្ជូនមក ត្រូវបានបញ្ចូលក្នុង SCD។

## ប្រធាននាយកដ្ឋានគោលនយោបាយ តាមដាន និងវាយតំលៃ

- ធានាថា កម្មវិធីជាប្រព័ន្ធសំរាប់ការវាយតំលៃលើគោលនយោបាយ ការស្រាវជ្រាវ និងការវិភាគត្រូវបានរៀបចំឡើង មានថវិកាគ្រប់គ្រាន់ និងត្រូវបានអនុវត្តដោយនាយកដ្ឋានគោលយោបាយតាមដាននិងវាយតំលៃ ហើយត្រូវធានាថា អនុសាសន៍លើការសិក្សា របាយការណ៍ និងគោលនយោបាយ ត្រូវបានរៀបចំដាក់ជូនទៅស្ថាប័នធ្វើសេចក្តីសំរេចចិត្ត ក្នុងជួររដ្ឋាភិបាលតាមរយៈ STF។
- ចូលរួមក្នុងការប្រជុំ សិក្ខាសាលានានា ដែលរៀបចំដោយគណៈកម្មាធិការជាតិគាំទ្រឃុំ ដើម្បីរៀបចំក្របខ័ណ្ឌច្បាប់វិមជ្ឈការ និងរៀបចំការតាមដានលើការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ។
- ជួយ STFS ក្នុងការរៀបចំសិក្ខាសាលា ដើម្បីពិនិត្យមើលឡើងវិញលើការអនុវត្តន៍កម្មវិធី ដោយផ្អែកលើឯកសារកម្មវិធីសិលា ឆ្នាំ២០០១-២០០៥ ព្រមទាំងជួយព្រាងឯកសារនេះឡើងវិញ ទៅតាមការចាំបាច់។

- ចូលរួមក្នុងសិក្ខាសាលាដែលរៀបចំដោយភ្នាក់ងារ ឬស្ថាប័ននានា តាមការស្នើសុំ ដើម្បីធានាថា កម្មវិធីសិលា ត្រូវបានបង្ហាញយ៉ាងត្រឹមត្រូវក្នុងការសន្ទនាពីគោលនយោបាយ ហើយអាចផ្សព្វផ្សាយពីបទពិសោធន៍នានារបស់កម្មវិធីសិលាទាក់ទងទៅនឹងអភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ។
- ជួយអគ្គលេខាធិការនៃ គ.ជ.ន.ស ក្នុងការផ្តល់ដំណឹងថ្មីៗស្តីពីការរីកចំរើនរបស់កម្មវិធីសិលាដល់ម្ចាស់ជំនួយ។
- សំរបសំរួលការសិក្សាស្រាវជ្រាវ និងសកម្មភាពពិគ្រោះយោបល់នានា ដែលធ្វើឡើងដោយវេទិកាម្ចាស់ជំនួយ (Donor Forum) និងដែលត្រូវបានផ្តល់ហិរញ្ញទានបន្ថែមទៀត តាមរយៈក្របខ័ណ្ឌផ្តល់ជំនួយរបស់កម្មវិធីសិលា។
- រក្សាទំនាក់ទំនងជាមួយអាជ្ញាធរខេត្ត ដើម្បីធានាថាការផ្តួចផ្តើមជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ របស់កម្មវិធីសិលា ត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវនៅថ្នាក់ខេត្ត។
- រៀបចំរបាយការណ៍ទៀងទាត់ និងរបាយការណ៍ពិសេសមួយចំនួន ស្តីពីបទពិសោធន៍លើ គោលនយោបាយរបស់កម្មវិធីសិលា តាមការស្នើរបស់អគ្គលេខាធិការ STF ។

## មន្ត្រីគោលនយោបាយ និងប្រព័ន្ធ

- រៀបចំ និងអនុវត្តកម្មវិធីជាប្រព័ន្ធ សំរាប់ការវិភាគ ការវាយតំលៃ និងការស្រាវជ្រាវលើគោលនយោបាយដែលទាក់ទងនឹងអភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រតាមបែបវិមជ្ឈការរបស់កម្មវិធីសិលា។
- សំរបសំរួលសិក្ខាសាលា ដើម្បីផ្សព្វផ្សាយបទពិសោធន៍ និងដើម្បីជំរុញនិងគាំទ្រអោយមានការសន្ទនាស្តីពីការអនុវត្តន៍គោលនយោបាយ របស់កម្មវិធីសិលារវាងរាជរដ្ឋាភិបាល សង្គមស៊ីវិល និងម្ចាស់ជំនួយ។
- សំរបសំរួលការសិក្សាស្រាវជ្រាវ និងសកម្មភាពពិគ្រោះយោបល់នានា ដែលធ្វើឡើងដោយវេទិកាម្ចាស់ជំនួយ (Donor Forum) និងដែលត្រូវបានផ្តល់ហិរញ្ញទានបន្ថែមទៀត តាមរយៈក្របខ័ណ្ឌផ្តល់ជំនួយរបស់កម្មវិធីសិលា។
- រៀបចំរបាយការណ៍ និងការឆ្លើយឆ្លងលើកម្មវិធី
- ធានាថា ខេត្តទាំងអស់ បានជ្រាបពីការផ្លាស់ប្តូរប្រព័ន្ធ និងនីតិវិធីនានារបស់កម្មវិធីសិលា។

- ជួយដល់ខេត្ត ក្នុងការអនុវត្តន៍ការទទួលខុសត្រូវលើការសរសេររបាយការណ៍។

## មន្ត្រីតាមដាននិងវាយតំលៃ

- ធានាថា ផែនការសកម្មភាពតាមដាននិងវាយតំលៃ ព្រមទាំងថវិកាថ្នាក់ជាតិ ត្រូវបានរៀបចំឡើងស្របទៅតាមឯកសារ និងប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា។
- ធានាថា ភ្នាក់ងារអនុវត្តន៍ ក្រសួងដែលជាសមាជិករបស់ STF ព្រមទាំងខេត្តទាំងអស់ បានយល់និងបានអនុវត្តប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា។
- សំរបសំរួលដំណើរការតាមដានលើការអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ខេត្ត។
- ធានាថា ប្រព័ន្ធរបាយការណ៍កម្មវិធីសិលា គឺមានដំណើរការ ហើយថា របាយការណ៍ដែលត្រូវផ្ញើពីខេត្ត និងក្រសួង ត្រូវបានទទួលនិងសង្ខេប។
- ជួយរៀបចំ និងសំរបសំរួលការសិក្សាវាយតំលៃ ដែលធ្វើឡើងដោយអ្នកខាងក្នុង និងអ្នកខាងក្រៅ។
- ទំនាក់ទំនងយ៉ាងជិតស្និតជាមួយមន្ត្រីគោលនយោបាយ និងប្រព័ន្ធ ដើម្បីធានាថា បទពិសោធន៍លើគោលនយោបាយ ត្រូវបានចងក្រង និងផ្សព្វផ្សាយ តាមរយៈប្រព័ន្ធតាមដាននិងវាយតំលៃ និងប្រព័ន្ធរបាយការណ៍។
- ធានាថា ប្រព័ន្ធទិន្នន័យនានារបស់កម្មវិធីសិលា ត្រូវបានថែរក្សាយ៉ាងត្រឹមត្រូវនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ហើយទិន្នន័យ ឬរបាយការណ៍ដែលស្រង់ចេញពីប្រព័ន្ធទិន្នន័យទាំងនោះ ត្រូវបានផ្សព្វផ្សាយដល់ស្ថាប័ន ដែលពាក់ព័ន្ធនៅថ្នាក់ជាតិ។
- ជួយរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល (រួមទាំងបង្កើតសំភារៈ និងមេរៀនបណ្តុះបណ្តាល) ស្តីពីនីតិវិធី និងឧបករណ៍តាមដានវាយតំលៃ ដល់មន្ត្រីថ្នាក់ក្រសួង និងថ្នាក់ខេត្តដែលមានការពាក់ព័ន្ធ។
- ចុះធ្វើដំណើរទស្សកិច្ចជាប្រចាំនៅតាមខេត្ត ដើម្បីតាមដានបន្ត ទាំងលើបញ្ហាទូទៅ និងបញ្ហាជាក់លាក់មួយចំនួន ស្តីពីប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា។
- រៀបចំផែនការសកម្មភាព និងរបាយការណ៍ប្រចាំខែ និងប្រចាំត្រីមាស តាមការចាំបាច់ ដើម្បីដាក់ជូនទៅអគ្គលេខាធិការនៃគ.ជ.ន.ស តាមរយៈប្រធាននាយកដ្ឋានគោលនយោបាយតាមដាន និងវាយតំលៃ។

**មន្ត្រីពត៌មាននិងទំនាក់ទំនងសាធារណៈ**

- ធានាថា យុទ្ធសាស្ត្រពត៌មាន និងទំនាក់ទំនងរបស់កម្មវិធីសិលា ត្រូវបានពិនិត្យឡើងវិញ និងកែលំអជាប្រចាំ។
- ចុះទៅខេត្តជាប្រចាំ ដើម្បីវាយតំលៃលើការអនុវត្តន៍យុទ្ធសាស្ត្រពត៌មាន និងទំនាក់ទំនងរបស់កម្មវិធីសិលា និងដើម្បីផ្តល់ការណែនាំសំរាប់កែលំអ។
- រៀបចំផែនការសកម្មភាព និងរបាយការណ៍ តាមការស្នើ ហើយដាក់ជូនទៅប្រធាននាយកដ្ឋានគោលនយោបាយតាមដាននិងវាយតំលៃ។

## ៣.៤. ការកសាងសមត្ថភាព សំរាប់ការតាមដាននិងវាយតំលៃ នៅថ្នាក់ជាតិ

ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពរបស់បុគ្គលិក គឺជាផ្នែកមួយដ៏សំខាន់របស់កម្មវិធីសិលា។ ទិសដៅមួយ ក្នុងចំណោមទិសដៅផ្សេងទៀតរបស់វា គឺការកសាងសមត្ថភាព ដល់មន្ត្រីរដ្ឋាភិបាល លើជំនាញផ្សេងៗគ្នាជាច្រើន ដូចជា ជំនាញក្នុងការតាមដាននិងវាយតំលៃ។ មន្ត្រីកម្មវិធីសិលា គួរតែមានឱកាសទទួលបាន និងអាចអនុវត្តជំនាញ និងចំណេះដឹងដែលមានការពាក់ព័ន្ធដល់ការងាររបស់ពួកគេ។ ការកសាងសមត្ថភាពរបស់កម្មវិធីសិលា អាចធ្វើបានតាមរយៈការរៀនផងអនុវត្តផង និងតាមរយៈវគ្គបណ្តុះបណ្តាល អន្តរសកម្មភាពជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ និងទស្សនកិច្ច សិក្សាជាដើម។ល។

ដើម្បីធ្វើអោយប្រព័ន្ធតាមដាននិងវាយតំលៃមួយប្រកបដោយប្រសិទ្ធភាព ចាំបាច់ទាមទារអោយមានមនុស្សដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់ ដែលអាចអនុវត្តតួនាទី និងភារកិច្ចលើការតាមដាននិងវាយតំលៃ។ មានវិធីសាស្ត្រជាច្រើន ក្នុងការកសាងសមត្ថភាព គឺ :

**ដើម្បីទទួលបានមនុស្សដែលមានជំនាញត្រឹមត្រូវ**

- ជួល ឬផ្ទេរបុគ្គលិកដែលមានជំនាញ
- បណ្តុះបណ្តាលបុគ្គលិក (នៅខាងក្នុង និងខាងក្រៅ)

- ជួលមនុស្សពីខាងក្រៅ (ទីប្រឹក្សា ឬវិទ្យាស្ថានណាមួយ ជាដើម ។ល។ ) ដើម្បីផ្តល់ជាជំនាញពិសេសណាមួយដល់បុគ្គលិក។

កម្មវិធីសិលា មានគោលការណ៍ណែនាំយ៉ាងច្បាស់ សំរាប់ការជ្រើសរើសបុគ្គលិក និងសំរាប់ការគ្រប់គ្រងបុគ្គលិក។ គោលការណ៍នៃទាំងនោះ មានបកស្រាយនៅក្នុងឯកសារណែនាំ ស្តីពីការគ្រប់គ្រងកម្មវិធីសិលា ហើយមិនមានលើកឡើងនៅក្នុងផ្នែកនេះទេ។ ក្នុងឯកសារណែនាំស្តីពីការគ្រប់គ្រងកម្មវិធីសិលា មាននិយាយផងដែរ ពីនីតិវិធីក្នុងការជ្រើសរើសបុគ្គលិក និងការរៀបចំកិច្ចសន្យាសំរាប់បុគ្គលិកនិងទីប្រឹក្សា។ មន្ត្រីកម្មវិធីសិលាទាំងអស់ ត្រូវតែអនុវត្តតាមនីតិវិធីទាំងនេះ។ គណៈកម្មាធិការជ្រើសរើសបុគ្គលិក ចាំបាច់ត្រូវតែធានាក្នុងការជ្រើសរើសបេក្ខជនដែលមានសមត្ថភាពល្អជាងគេ ដោយត្រូវធានាថា បេក្ខជនដែលត្រូវបានជ្រើសរើសនោះ ត្រូវមានជំនាញនិងសមត្ថភាពច្បាស់លាស់ ដើម្បីអនុវត្តភារកិច្ចតាមដាននិងវាយតំលៃ ឬយ៉ាងហោចណាស់ ក៏មានសមត្ថភាពអាចចាប់បានការយល់ដឹង ឆាប់រហ័ស។ មន្ត្រីតាមដាននិងវាយតំលៃត្រូវផ្តល់យោបល់ខ្លះៗ ក្នុងការរៀបចំសំនួរសំភាសន៍ ហើយមន្ត្រីរូបនេះ ក៏គួរតែចូលរួមក្នុងគណៈកម្មាធិការជ្រើសរើសបុគ្គលិក ដែលត្រូវពាក់ព័ន្ធនឹងភារកិច្ចតាមដាននិងវាយតំលៃសំខាន់ៗមួយចំនួន។

**ដើម្បីធានាអោយសមត្ថភាពរបស់បុគ្គលិក មានគុណភាពល្អ គឺត្រូវ :**

- យល់ច្បាស់ពីអ្វីដែលអកចង់បាន
- វាយតំលៃជាប្រចាំលើការអនុវត្តន៍របស់បុគ្គលិក
- គ្រឿងលើកទឹកចិត្ត ក្នុងការរៀនសូត្រ
- កំណត់អត្រាផ្លាស់ប្តូរបុគ្គលិក
- ត្រូវមានមនុស្សដែលមានសមត្ថភាព ដើម្បីសំរបសំរួលការងារតាមដាន និងវាយតំលៃ

គ្រប់លក្ខខ័ណ្ឌការងារទាំងអស់របស់មន្ត្រីអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវមានភារកិច្ចតាមដាននិងវាយតំលៃនៅក្នុងនោះ។ ប្រធាន និងសហការី ចាំបាច់ត្រូវជួយបុគ្គលិកថ្មី ឬបុគ្គលិកដែលទើបទទួលបានភារកិច្ចថ្មី អោយបានយល់ដឹងពីការងារប្រចាំថ្ងៃ គំរូបទដ្ឋាន កាលវិភាគ និង

លទ្ធផលរំពឹងទុករបស់សកម្មភាពតាមដាននិងវាយតំលៃ។ ទន្ទឹមនឹងនេះ បុគ្គលិកទាំងអស់ គឺមានភារកិច្ច ធ្វើអោយបុគ្គលិកថ្មីនោះ យល់បានច្បាស់ពីអ្វីដែលគាត់ត្រូវធ្វើ និងអ្វីដែលគាត់ត្រូវអនុវត្ត។

ឯកសារណែនាំ ស្តីពីការគ្រប់គ្រងកម្មវិធីសិលា មានផ្នែកមួយ និយាយពី នីតិវិធីវាយតំលៃការអនុវត្តន៍របស់បុគ្គលិក ដែលបង្ហាញពីដំណាក់កាលនានា ក្នុងការវាយតំលៃនេះ។ ដំណាក់កាលទាំងនោះ រួមមានការវាយតំលៃដោយខ្លួនឯង និងការពិនិត្យឡើងវិញដោយ គណៈកម្មាធិការវាយតំលៃ។ ក្នុងឯកសារ នោះក៏មានលើកឡើងនូវជំហានមួយចំនួនដែលត្រូវអនុវត្តនៅពេលដែលបុគ្គលិកណាម្នាក់មិនបានបំពេញការងារផងដែរ។ ក្នុងឯកសារនោះ ក៏មានចំណុចមួយ ស្តីពីលក្ខខ័ណ្ឌកិច្ចសន្យាផ្តល់សេវាកម្ម សំរាប់មន្ត្រីកម្មវិធីសិលា រួមមានផលប្រយោជន៍និងប្រាក់ឧបត្ថម្ភផ្សេងៗផងដែរ។

## ការបណ្តុះបណ្តាលការងារតាមដាន និងវាយតំលៃ

ការបណ្តុះបណ្តាល គឺជាផ្នែកមួយដ៏សំខាន់ ក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព។ ការបណ្តុះបណ្តាលនេះ គួរតែធ្វើឡើងដោយផ្អែកលើផែនការបណ្តុះបណ្តាលសំរាប់អ្នកដែលពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ។ យើងអាចធ្វើផែនការបណ្តុះបណ្តាលបាន ដោយផ្អែកលើការវាយតំលៃពីជំនាញ និងលក្ខខ័ណ្ឌផ្សេងៗទៀតទាក់ទងនឹងលក្ខខ័ណ្ឌការងារ និងភារកិច្ចទាំងអស់របស់បុគ្គលិក។ វគ្គបណ្តុះបណ្តាល អាចធ្វើទៅបាន ដោយរួមបញ្ចូលនូវវិធីសាស្ត្របញ្ចូលគ្នាមួយចំនួន ដូចខាងក្រោម :

- វគ្គបណ្តុះបណ្តាល ធ្វើដោយអ្នកខាងក្នុង សំរាប់បំពេញដល់ក្រុមជនគោលដៅ
- វគ្គបណ្តុះបណ្តាល ធ្វើដោយអ្នកខាងក្រៅ
- រៀនផង និងអនុវត្តការងារផង
- សិក្ខាសាលា
- ដំណើរទស្សនកិច្ចសិក្សា

កំរិតផ្សេងៗគ្នានៃសមត្ថភាព និងជំនាញរបស់បុគ្គលិក គឺអាស្រ័យលើរយៈពេលដែលពួកគេបានបំរើការងារក្នុងកម្មវិធីសិលា និង/ឬ ក្នុងការងារតាមដានវាយតំលៃ និងវគ្គបណ្តុះបណ្តាលដែលបានទទួលកន្លងមក។

នាយកដ្ឋានគោលនយោបាយតាមដាននិងវាយតំលៃ (PMEU) របស់ STFS ចាំបាច់ត្រូវរៀបចំ គ្រោងថវិកា និងអនុវត្តការវាយតំលៃពីតំរូវការការកសាងសមត្ថភាព និងបណ្តុះបណ្តាល។ បន្ទាប់មកទៀត នាយកដ្ឋាននេះ ត្រូវរៀបចំ និងអនុវត្តកម្មវិធីកសាងសមត្ថភាពប្រចាំឆ្នាំ ដោយលើកឡើងនូវតំរូវការជាក់លាក់មួយចំនួនរបស់អ្នកគ្រប់គ្នា ដែលពាក់ព័ន្ធក្នុងប្រព័ន្ធការងារតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា។ ជាទូទៅ បើសិនជាមានបុគ្គលិកណាម្នាក់ ចាប់អារម្មណ៍ចង់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលណាមួយ បុគ្គលិកនោះគួរតែសួរនាំជាមួយអ្នកគ្រប់គ្រងរបស់ខ្លួន ជាពិសេស បើសិនជាវគ្គបណ្តុះបណ្តាល នោះពាក់ព័ន្ធនឹងការងាររបស់ខ្លួន។

វិធីសាស្ត្រជាដំណាក់កាលៗ សំរាប់ការបណ្តុះបណ្តាល គួរតែត្រូវបានបង្កើតឡើង ដើម្បីផ្សព្វផ្សាយចំនុចមួយចំនួន ដូចខាងក្រោម (ប៉ុន្តែត្រូវតែអោយស្របទៅតាមកំរិត និងទំនាក់ទំនងនៃការយល់ដឹងរបស់ក្រុមគោលដៅ)

- ចំណេះដឹងជាមូលដ្ឋានលើការតាមដាន និងវាយតំលៃ ផលប្រយោជន៍ និងសារៈសំខាន់របស់វា
- តារាងតក្កភាពរបស់កម្មវិធីសិលា
- គោលនយោបាយសំខាន់ៗ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល និងបញ្ហាអន្តរវិស័យរបស់កម្មវិធីសិលា (ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងការបញ្ជ្រាបយេនឌ័រ)
- ប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលាដែលបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវសំខាន់ៗរបស់មនុស្សផ្សេងៗគ្នា
- បង្ហាញ និងអនុវត្តប្រព័ន្ធតាមដាន និងវាយតំលៃរបស់កម្មវិធីសិលា

ដើម្បីអោយស្របទៅនឹងប្រព័ន្ធតាមដាននិងវាយតំលៃរបស់កម្មវិធីសិលា ការយកចិត្តទុកដាក់សំរាប់ ការកសាងសមត្ថភាពនៅថ្នាក់ជាតិ គួរតែផ្តោតទៅលើការតាមដាន និងការពង្រឹងការប្រើប្រាស់ពត៌មាន ដែលទទួលបានពីការតាមដាន សំរាប់ការគ្រប់គ្រងការសំរេចចិត្ត និងសំរាប់ពិនិត្យឡើងវិញលើប្រព័ន្ធនានា ការវិភាគគោលនយោបាយ និងការប៉ាន់ប្រមាណលើផលប៉ះពាល់លើកំរិតគោលដៅនិងទិសដៅរបស់កម្មវិធី។

ឯកសារណែនាំ ស្តីពី

ការតាមដាន និងវាយតំលៃ

កម្មវិធីសិលា

# ផ្នែកទី៥

# ប្រព័ន្ធតាមដាន និងវាយតំលៃឃុំ



# ប្រព័ន្ធតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ

## ៥.១. សេចក្តីផ្តើមពីរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ឃុំ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ ដែលត្រូវបានប្រកាសអោយប្រើកាលពីឆ្នាំ២០០១ បានដាក់កំរិតដល់ការគ្រប់គ្រងរដ្ឋបាលឃុំ។ ច្បាប់នេះ បញ្ជាក់ថា ឃុំនីមួយៗត្រូវគ្រប់គ្រង និងចាត់ចែងដោយក្រុមប្រឹក្សា ឃុំដែលមានសមាជិកជាប់ឆ្នោតទាំងអស់ពី៥នាក់ដល់១១នាក់។ ក្រសួងមហាផ្ទៃបានតែងតាំងស្មៀនឃុំ មួយរូបដើម្បីជួយសំរួលការងាររដ្ឋបាលដល់ក្រុមប្រឹក្សាឃុំនីមួយៗ។

ក្រុមប្រឹក្សាឃុំ មានសិទ្ធិក្នុងការបង្កើតគណៈកម្មាធិការនានា ដើម្បីជួយសំរួលការងារគ្រប់គ្រង និងការងាររដ្ឋបាលរបស់ខ្លួន។ គណៈកម្មាធិការមួយក្នុងចំណោមគណៈកម្មាធិការទាំងនោះ គឺគណៈកម្មាធិការកសាងផែនការនិងថវិកា (PBC) ដែលត្រូវជួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំបង្កើតផែនការអភិវឌ្ឍន៍ឃុំ ផែនការវិនិយោគឃុំ និងថវិកាប្រចាំឆ្នាំ។

អំណាច តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ និងមានបញ្ជាក់ផងដែរនៅក្នុងអនុក្រិត្យ និងគោលការណ៍ណែនាំមួយចំនួន របស់ក្រសួង នានា (ដូចជាក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការ)។ ទោះបីយ៉ាងណាក៏ដោយ ការបង្កើតបញ្ញាតិសំរាប់ការអនុវត្តន៍ នៅតែជាភារកិច្ចមួយដែលមិនទាន់បានបញ្ចប់នៅឡើយ ហើយសូម្បីតែបញ្ញាតិសំរាប់អនុវត្តមួយចំនួនដែលបានបង្កើតកន្លងមក ក៏ចាំបាច់ត្រូវធ្វើការវាយតំលៃ និងអាចត្រូវធ្វើការកែលំអជាបន្តផងដែរ។ ដូច្នេះ ប្រព័ន្ធM&Eថ្នាក់ឃុំ ពេលខ្លះគ្មានទីបញ្ចប់នោះទេ គឺវាទាមទារអោយមានការកែសំរួលជាប្រចាំ អោយស្របទៅនឹងគោលការណ៍ណែនាំថ្មីៗ របស់រដ្ឋាភិបាល សំរាប់ការអនុវត្តន៍។

ជាការចាំបាច់ដែលត្រូវចងចាំថា ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្នុងខែកុម្ភៈ ឆ្នាំ ២០០២មក ទាំងក្រុមប្រឹក្សាឃុំ ទាំងប្រព័ន្ធកសាងផែនការ ហិរញ្ញវត្ថុ និងគ្រប់គ្រង ដែលបាននិងកំពុង

ប្រើប្រាស់ទូទាំងប្រទេស គឺជា**<u>របនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាល</u>** ទាំងស្រុង។ រចនាសម្ព័ន្ធ និងប្រព័ន្ធដែលបានប្រើប្រាស់ក្នុងឃុំដែលអនុវត្តកម្មវិធីសិលា មុនឆ្នាំ២០០២ គឺស្ថិតក្នុងក្របខ័ណ្ឌរបស់**<u>គំរោង ឬកម្មវិធី</u>** មិនមែនរបស់រដ្ឋាភិបាលទេ។ ដោយហេតុនេះហើយ ផ្នែកទី៥នេះ ត្រូវមានចំណង ជើងថា " ប្រព័ន្ធតាមដាននិងវាយតំលៃថ្នាក់ឃុំ Commune M&E System " មិនមែន " ប្រព័ន្ធតាមដាន និង វាយតំលៃថ្នាក់ឃុំ ***របស់កម្មវិធីសិលា*** Seila Commune M&E System " នោះទេ។ ប្រព័ន្ធ M&E ថ្នាក់ឃុំនេះ គឺមិនមែនត្រូវបានប្រើសំរាប់តែកម្មវិធីសិលាតែឯងប៉ុណ្ណោះទេ គឺសំរាប់ការងារតាមដាន និង វាយតំលៃលើការងារទូទៅរបស់ឃុំ។

## ៥.២. ការតាមដាននិងវាយតំលៃថ្នាក់ឃុំ

ចំណុចដែលខុសគ្នាយ៉ាងសំខាន់មួយរវាង M&Eថ្នាក់ឃុំ នឹង M&E របស់កម្មវិធីសិលាថ្នាក់ខេត្ត និង ថ្នាក់ជាតិ ត្រង់ថា នៅថ្នាក់ឃុំ វាមានភាពដាច់ពីគ្នាយ៉ាងស្រឡះរវាងការតាមដាន និងវាយតំលៃ ដែល ធ្វើឡើងដោយឃុំផ្ទាល់ (មានន័យថាធ្វើឡើងដោយក្រុមប្រឹក្សាឃុំ គណៈកម្មាធិការកសាងផែនការ និងថវិកា និងផ្នែកខ្លះត្រូវបានអនុវត្តដោយប្រជាជនក្នុងឃុំ) និងការតាមដាននិងវាយតំលៃ ដែលធ្វើឡើងដោយមន្ត្រី ថ្នាក់ស្រុក និងថ្នាក់ខេត្ត។ ការតាមដាននិងវាយតំលៃបែបនេះ អាចហៅបានថា ជាការតាមដាន និង វាយតំលៃដោយអ្នកខាងក្នុង -Internal M&E- ហើយការតាមដាននិងវាយតំលៃ ដែលធ្វើឡើងដោយមនុស្ស ឬភ្នាក់ងារដែលមិនមែនឃុំ គឺហៅថា ការតាដាននិងវាយតំលៃដោយអ្នកខាងក្រៅ – External M&E។ ការតាមដាននិងវាយតំលៃទាំងពីរប្រភេទនេះ មិនគួរត្រូវបានចាត់ទុកថាជាប្រព័ន្ធដាច់ដោយឡែកពីគ្នានោះ ទេ វាគួរតែត្រូវបានដាក់បញ្ចូលគ្នា ហើយបំពេញអោយគ្នាទៅវិញទៅមក។

### ៥.២.១. ការតាមដាននិងវាយតំលៃថ្នាក់ឃុំដោយអ្នកខាងក្នុង

ភារកិច្ចមួយក្នុងចំណោមភារកិច្ចទាំងឡាយរបស់ក្រុមប្រឹក្សាឃុំ ដែលមានចែងក្នុងច្បាប់គ្រប់គ្រងរដ្ឋបាល ឃុំ គឺថាក្រុមប្រឹក្សាឃុំត្រូវធ្វើការតាមដាន តាមដានបន្ត និងវាយតំលៃលើការអនុវត្តន៍ផែនការអភិវឌ្ឍន៍ របស់ខ្លួនប្រកបដោយតម្លាភាព។ ក្រុមប្រឹក្សាឃុំ អាចអនុវត្តការងារនេះប្រកបដោយការទទួលខុសត្រូវ ខ្ពស់

ដោយមានជំនួយពីមនុស្សផ្សេងៗទៀត ដូចជា គណៈកម្មាធិការកសាងផែនការនិងថវិកាជាដើម។ ប៉ុន្តែ ក្រុមប្រឹក្សាឃុំជាអ្នកទទួលខុសត្រូវរួមទាំងមូល។

ផែនការអភិវឌ្ឍន៍ឃុំ និងថវិកាប្រចាំឆ្នាំ គឺជាមូលដ្ឋានគ្រឹះសំរាប់ធ្វើការតាមដាននិងវាយតំលៃថ្នាក់ឃុំ ដោយអ្នកខាងក្នុងប្រភេទនេះ។ មេឃុំ ចៅសង្កាត់ ជាអ្នកទទួលខុសត្រូវ រាយការណ៍ជារៀងរាល់ខែ ពីការអនុវត្តន៍ការងារនិងការរីកចំរើន ជូនក្រុមប្រឹក្សាឃុំទាំងមូល។ កាលពីខែកុម្ភៈ ឆ្នាំ២០០៣ ក្រសួងមហាផ្ទៃបានចេញប្រកាសមួយ ស្តីពីគំរូរបាយការណ៍ប្រចាំខែនិងប្រចាំត្រីមាសរបស់ឃុំ។ ពត៌មានដែល បានរាយការណ៍ដោយមេឃុំ ចៅសង្កាត់ និងរបាយការណ៍ប្រចាំខែ ធ្វើអោយក្រុមប្រឹក្សាអាចវាយតំលៃពីការរីកចំរើន ដោយផ្ទៀងផ្ទាត់ជាមួយផែនការសកម្មភាព និងថវិកាដែលបានអនុម័ត និងជាមួយកិច្ចព្រមព្រៀងទាំងឡាយដែលឃុំបានធ្វើជាមួយភាគីផ្សេងៗទៀត។

ការគ្រប់គ្រង និងរដ្ឋបាលហិរញ្ញវត្ថុឃុំ និងM&E គឺជាកិច្ចការពីរផ្សេងគ្នា តែមានទំនាក់ទំនងគ្នា ហើយមកដល់ពេលនេះ កិច្ចការទាំងពីរនៅតែជាការទទួលខុសត្រូវរួមរបស់ក្រុមប្រឹក្សាឃុំ។ ឃុំមានសិទ្ធិចាយវាយបន្តិចបន្តួច ដោយប្រើគណនីបេឡាសាច់ប្រាក់របស់ខ្លួន ប៉ុន្តែរតនាគារខេត្ត ជាអ្នកចាត់ចែងនិងគ្រប់គ្រងគណនីឃុំ។

មកទល់នឹងពេលនេះ នៅមិនទាន់មានប្រព័ន្ធច្បាស់លាស់ណាមួយ សំរាប់ការតាមដាននិងវាយតំលៃថ្នាក់ឃុំដោយអ្នកខាងក្នុង ត្រូវបានអនុម័តនោះទេ។

## ៥.២.២. ការតាមដាននិងវាយតំលៃថ្នាក់ឃុំ ដោយអ្នកខាងក្រៅ

ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំបានបញ្ជាក់ថា ត្រូវតែមានការតាមដាននិងត្រួតពិនិត្យលើសកម្មភាពទូទៅរបស់ ឃុំ ដើម្បី :

- ពិនិត្យនីត្យានុកូលភាពលើការងារដែលឃុំបានអនុវត្ត លើការងារដែលឃុំ នឹង ត្រូវអនុវត្ត និង របៀបដែលត្រូវអនុវត្តដូចដែលមានចែងនៅក្នុងច្បាប់នេះនិងក្នុងបទបញ្ញត្តិផ្សេងៗទៀត សំរាប់ការអនុវត្តន៍។ ភ្នាក់ងារដែលទទួលខុសត្រូវលើការត្រួតពិនិត្យនីត្យានុកូលភាពរបស់ឃុំ ត្រូវតែធ្វើការតាមដានមើលថាតើ ឃុំបានអនុវត្តស្របទៅតាមច្បាប់ និងបទបញ្ញត្តិទាំងនោះដែរឬទេ។
- ពិនិត្យមើលការកសាងសមត្ថភាពរបស់ឃុំ ថាតើមានសមត្ថភាពគ្រប់គ្រាន់ដែរឬទេ ក្នុងអនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួននោះ? តើសមត្ថភាពរបស់ឃុំត្រូវបាន និងកំពុងអភិវឌ្ឍបែបណា ?
- វាយតំលៃលើការគាំទ្រទាំងឡាយ ដែលជួយពង្រឹងសមត្ថភាពដល់ឃុំ លើការចាត់ចែងការងារ ការប្រើអំណាច និងក្នុងការអនុវត្តន៍តួនាទី និងភារកិច្ចរបស់ពួកគេ។

នាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ (DoLA) និងអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត (POLA) មានភារកិច្ចចំបង ក្នុងការតាមដាននិងវាយតំលៃលើការអនុវត្តន៍របស់ឃុំ។ សំរាប់ខេត្តដែលស្ថិតក្នុងកម្មវិធីសិលាផ្នែករដ្ឋបាលមូលដ្ឋាន (LAU) របស់គ.ប្រ នៃគ.អ.ជ.ខ ក៏ជាអ្នកជួយ POLA ក្នុងការ អនុវត្តន៍ការតាមដាន និងវាយតំលៃនេះផងដែរ។

រតនាគារខេត្ត គឺជាអ្នកគ្រប់គ្រងយ៉ាងសំខាន់លើហិរញ្ញវត្ថុឃុំ ទាំងផ្នែករដ្ឋបាល ទូទៅរបស់មូលនិធិឃុំ ក៏ដូចជាផ្នែកអភិវឌ្ឍន៍ផងដែរ។ រតនាគារខេត្ត ត្រូវការប្រព័ន្ធមួយជាចាំបាច់ ដែលអាចជាប្រព័ន្ធទិន្នន័យដើរដោយកំព្យូទ័រ ដើម្បីធ្វើការតាមដានលើការរីកចំរើននៃសកម្មភាពអភិវឌ្ឍន៍របស់ឃុំ។ ប្រព័ន្ធទិន្នន័យ នេះនឹងតាមដានរាល់ការរីកចំរើនរបស់សកម្មភាពនិងការអនុវត្តន៍កិច្ចសន្យា លទ្ធផល ព្រមទាំងពត៌មានហិរញ្ញវត្ថុផងដែរ។

## ៥.៣. សូចនាករសំរាប់ប្រព័ន្ធតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ

សូចនាករមួយចំនួនត្រូវតែបង្កើតឡើង ដើម្បីបង្កើតប្រព័ន្ធតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ ដែលនឹងជួយក្រុមប្រឹក្សាឃុំ និងភ្នាក់ងារនៅថ្នាក់ខេត្ត និងថ្នាក់ជាតិដែលមានតួនាទី ក្នុងការត្រួតត្រាមើលការប្រព្រឹត្ត ទៅរបស់ឃុំ។ តារាងខាងក្រោមបង្ហាញពីសូចនាករ ដែលត្រូវធ្វើការតាមដាន និងមធ្យោបាយប្រមូលទិន្នន័យ។ ជូនកាល គួរតែមានការពិភាក្សាបែបចូលរួម ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីកំណត់សូចនាកររួមមួយ

ចំនួនតូច សំរាប់អោយឃុំទាំងអស់ប្រើប្រាស់។ ធ្វើដូចនេះយើងអាចបន្តអភិវឌ្ឍប្រព័ន្ធតាមដាននិងវាយតំលៃរបស់ឃុំបន្ថែមទៀត។

| សូចនាករសំខាន់ៗ | មធ្យោបាយផ្ទៀងផ្ទាត់ | M&E ដោយអ្នកខាងក្នុង | M&E ដោយអ្នកខាងក្រៅ |
|---|---|---|---|
| ប្រព័ន្ធវិមជ្ឈការផែនការ ហិរញ្ញវត្ថុ និងការគ្រប់គ្រង ដែលបានអនុវត្តនៅ ថ្នាក់ឃុំ | កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាឃុំ | ✔ | ✔ |
| | របាយការណ៍ប្រចាំខែរបស់ឃុំ | ✔ | ✔ |
| | គណនីហិរញ្ញវត្ថុឃុំ សង្កាត់ | | ✔ |
| | អចលនទ្រព្យដែលបានចុះបញ្ជីរបស់ឃុំ | ✔ | ✔ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✔ | ✔ |
| | ផែនការអភិវឌ្ឍន៍របស់ឃុំ | | ✔ |
| | ថវិកាប្រចាំឆ្នាំរបស់ឃុំ | | ✔ |
| ប្រព័ន្ធគាំទ្រការកសាងផែនការ ហិរញ្ញវត្ថុ និងការគ្រប់គ្រង ដែលបាន អនុវត្តនៅថ្នាក់ខេត្ត | របាយការណ៍ប្រចាំខែរបស់ POLA | | ✔ |
| | របាយការណ៍ប្រចាំខែរបស់រតនាគារខេត្ត | | ✔ |
| | របាយការណ៍ប្រចាំខែរបស់ PFT និង DFT | | ✔ |
| គណនេយ្យភាព និងតម្លាភាពនៃការ សំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ ចំពោះ ប្រជាពលរដ្ឋមូលដ្ឋាន | បណ្តាញពត៌មានសាធារណៈនៅថ្នាក់ឃុំ និងភូមិ (ក្នុងអង្គប្រជុំ ក្តាបិទផ្សាយពត៌មាន ព្រឹត្តិប័ត្រ..) | ✔ | ✔ |
| | ការវាយតំលៃប្រមាណក្រោយផ្លូវការធ្វើឡើងដោយឃុំ សង្កាត់ | ✔ | |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✔ | ✔ |
| | សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ | ✔ | ✔ |
| ការចូលរួមរបស់សហគមន៍ក្នុង ការគ្រប់គ្រង និងអភិវឌ្ឍន៍ឃុំ | ផែនការអភិវឌ្ឍន៍ឃុំ | ✔ | ✔ |
| | ការស្ទាបស្ទង់ពីក្រុមអ្នកទទួលផលពីគំរោង | ✔ | ✔ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✔ | ✔ |
| ការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ ដើម្បីជំរុញអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមនិងធ្វើអោយស្ថានភាព រស់នៅរបស់ប្រជាជនបាន ប្រសើរឡើង ដោយថែរក្សាបរិស្ថាន និងធនធានធម្មជាតិរបស់ឃុំ | ប្រព័ន្ធទិន្នន័យឃុំ | ✔ | ✔ |
| | ផែនការអភិវឌ្ឍន៍ឃុំ | ✔ | ✔ |
| | ផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ | ✔ | ✔ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✔ | ✔ |
| **សូចនាករសំខាន់ៗ** | **មធ្យោបាយផ្ទៀងផ្ទាត់** | **M&E ដោយអ្នកខាងក្នុង** | **M&E ដោយអ្នកខាងក្រៅ** |
| | ការវាយតំលៃប្រមាណក្រោយផ្លូវការក្នុងឃុំ | | ✔ |

| | | | |
|---|---|---|---|
| ភាពញឹកញាប់ ប្រសិទ្ធភាព និងពេលវេលានៃការគាំទ្រសំរាប់ឃុំ | ការចាត់ប្រមាណក្រៅផ្លូវការក្នុងឃុំ | | ✓ |
| [illegible] ឃុំនីតិវិធី និង ប្រព័ន្ធគ្រប់គ្រងឃុំ | [illegible] DET | | ✓ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✓ | ✓ |
| | របាយការណ៍ប្រចាំខែរបស់ POLA | | ✓ |
| ការប្រើប្រាស់ផ្នែកអភិវឌ្ឍន៍របស់មូលនិធិឃុំ | ប្រព័ន្ធទិន្នន័យឃុំ | ✓ | ✓ |
| | ផែនការអភិវឌ្ឍន៍ឃុំ | ✓ | ✓ |
| | ថវិកាប្រចាំឆ្នាំរបស់ឃុំ | ✓ | ✓ |
| | ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង | | ✓ |
| | ប្រព័ន្ធទិន្នន័យមូលនិធិឃុំ | | ✓ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✓ | ✓ |
| ការគ្រប់គ្រងគំរោងអភិវឌ្ឍន៍ឃុំ (ដូចជា ពេលវេលានៃការអនុវត្តន៍ ការត្រួតពិនិត្យចំណាយ ... ) | ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង | | ✓ |
| គុណភាព ទំនាក់ទំនង និងផលប៉ះពាល់នៃការបញ្ជូនសេវារបស់ឃុំ និងគំរោងអភិវឌ្ឍន៍ វិនិយោគ ឃុំ | ប្រព័ន្ធទិន្នន័យឃុំ | ✓ | ✓ |
| | របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ✓ | ✓ |
| | ការស្ទាបស្ទង់ពីក្រុមអ្នកទទួលផលពីគំរោង | ✓ | ✓ |
| | ការស្ទាបស្ទង់ពីការថែរក្សាអចលនទ្រព្យឃុំ | ✓ | ✓ |
| | ពិនិត្យមើលប្រព័ន្ធកសាងផែនការ | | ✓ |
| | ពិនិត្យមើលប្រព័ន្ធហិរញ្ញវត្ថុ | | ✓ |
| | ពិនិត្យមើលប្រព័ន្ធអនុវត្តន៍គំរោង | | ✓ |
| | ពិនិត្យមើលប្រព័ន្ធ M&E | | ✓ |
| ការប្រមូលចំណូលពីធនធានផ្ទាល់របស់ឃុំ | ថវិកាឃុំប្រចាំឆ្នាំ | ✓ | ✓ |

## ៥.៤. តួនាទី និងការទទួលខុសត្រូវលើការតាមដាននិងវាយតំលៃនៅថ្នាក់ឃុំ

តួនាទី និងការទទួលខុសត្រូវខាងក្រោមនេះ ត្រូវបានដកចេញពីច្បាប់ និងនីយតកម្មនានារបស់ រដ្ឋាភិបាល ដែលទាក់ទងទៅនឹងក្រុមប្រឹក្សាឃុំ :

**ក្រុមប្រឹក្សាឃុំ**

- ត្រូវពិនិត្យ និងអនុម័តលើផែនការសកម្មភាពនៃដំណើរការកសាងផែនការនិងថវិកាប្រចាំឆ្នាំ ដើម្បីអនុវត្តផែនការអភិវឌ្ឍន៍ឃុំ។
- ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតំលៃរាល់ការអនុវត្តន៍ លទ្ធផល និងផលប៉ះពាល់ របស់ ផែនការ (អភិវឌ្ឍន៍)កម្មវិធី គំរោង និងការផ្តល់សេវានានា ដោយរួមបញ្ចូលទាំងសកម្មភាព ដែលធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាល មិនមែនរដ្ឋាភិបាល ភ្នាក់ងារអន្តរជាតិ និងផ្នែកឯកជន ក្នុងឃុំរបស់ខ្លួនប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់។
- ត្រូវអនុម័តលើថវិកា វិសោធនកម្មថវិកា និងតាមដានការអនុវត្តន៍ថវិកា។
- ត្រូវរៀបចំ ពិនិត្យមើលឡើងវិញ អនុម័ត និងត្រូវបញ្ជូនរបាយការណ៍ប្រចាំឆ្នាំ ក្រោយពេលដែលគំរោងត្រូវបានបញ្ចប់រយៈពេល៤៥ថ្ងៃ នៅរៀងរាល់ចុងឆ្នាំសារពើពន្ធ។
- ត្រូវពិនិត្យមើលឡើងវិញ អនុម័ត ចែកចាយ និងផ្សព្វផ្សាយរាល់ដីកា (បទបញ្ជា សេចក្តីសំរេច ) ទាំងឡាយរបស់ក្រុមប្រឹក្សាឃុំ ដល់ប្រជាជនក្នុងឃុំ ជាសាធារណៈ។
- ត្រូវសំរបសំរួលជាមួយមនុស្សគ្រប់គ្នា និងរាយការណ៍ពីលទ្ធផលនៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍ ឃុំ ដល់ប្រជាជនក្នុងឃុំ អោយបានដឹង។

**មេឃុំ ចៅសង្កាត់**

- ត្រូវរៀបចំ និងដាក់ជូននូវសេចក្តីព្រាងផែនការសកម្មភាពនិងថវិកាដល់ក្រុមប្រឹក្សាឃុំ អនុម័ត ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ឃុំ។
- ត្រូវរាយការណ៍ប្រចាំខែពីការអនុវត្តន៍ការងារ និងដាក់ជូនសេចក្តីព្រាងរបាយការណ៍ហិរញ្ញវត្ថុ (ប្រចាំខែ និងពាក់កណ្តាលឆ្នាំ )ទៅអោយក្រុមប្រឹក្សាឃុំ។
- ដោយមានជំនួយបច្ចេកទេសពីគណៈកម្មាធិការកសាងផែនការនិងថវិកា ត្រូវរៀបចំនិងដាក់ជូនរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំទៅក្រុមប្រឹក្សាឃុំ នៅរៀងរាល់ចុងឆ្នាំសារពើពន្ធ។

**គណៈកម្មាធិការកសាងផែនការនិងថវិកា**

- គួរតែតាមដានដំណើរការកសាងផែនការនិងការអនុវត្តន៍ដំណើរការកសាងផែនការសកម្មភាព។
- ត្រូវធ្វើរបាយការណ៍រីកចំរើននៃសកម្មភាពរបស់ខ្លួនជារៀងរាល់ខែ
- ជួយមេឃុំ ចៅសង្កាត់រៀបចំ និងដាក់ជូនរបាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាឃុំ នៅរៀងរាល់ចុងឆ្នាំសារពើពន្ធ។
- ត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំអំពីបញ្ហានានា ដែលត្រូវអនុវត្ត។

## មេភូមិ

- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ ពីបញ្ហានានាដែលទាក់ទងនឹងផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន។
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ ឬមេឃុំ ចៅសង្កាត់ ដើម្បីចាត់ចែងនិងសំរបសំរួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

## ប្រជាពលរដ្ឋ

- ប្រជាពលរដ្ឋត្រូវ (បានលើកទឹកចិត្តអោយ )ចូលរួមផ្តល់យោបល់ និងទស្សនៈរបស់ខ្លួនពីដំណើរការកសាងផែនការ និងសកម្មភាពកសាងផែនការ។
- ប្រជាពលរដ្ឋត្រូវ(បានលើកទឹកចិត្តអោយ) ធ្វើការតាមដានលើការអនុវត្តន៍ថវិកា។

## ៥.៥. ការប្រមូលទិន្នន័យ និងមធ្យោបាយផ្ទៀងផ្ទាត់

ដោយផ្អែកលើសូចនាករនិងមធ្យោបាយផ្ទៀងផ្ទាត់ដែលយើងបានជ្រើសរើស យើងអាចកំណត់សកម្មភាពមួយចំនួនដែលត្រូវអនុវត្តដើម្បីប្រមូល បង្ហាញ និងវិភាគទិន្នន័យ។ ក្នុងការចុះប្រមូល ទិន្នន័យនៅថ្នាក់ឃុំ យើងអាចប្រើវិធីសាស្ត្រសាមញ្ញៗមួយចំនួនដូចជា: ការចុះទស្សនកិច្ចសិក្សាដល់មូលដ្ឋាន ការអង្កេត ការសំភាសន៍ (ក្រៅផ្លូវការ/ជាក្រុម )ប្រជុំ និងការប៉ាន់ប្រមាណ (ក្រៅផ្លូវការ ) ជាដើម ។ល។ ទិន្នន័យដែលប្រមូលបាន យើងអាចសង្ខេបវាដាក់នៅក្នុងរបាយការណ៍រីកចំរើននិងរបាយការណ៍ប្រចាំឆ្នាំ ដោយប្រើបែបបទឯកភាពមួយ (standard formats)។

ការប្រមូលទិន្នន័យគឺជាការងារប្រចាំថ្ងៃមួយដែលត្រូវធ្វើសំរាប់ការតាមដាន។ ការតាមដាន នៅថ្នាក់ឃុំ គឺមានលក្ខណៈសាមញ្ញហើយងាយស្រួល ចំណែកឯវិធីសាស្ត្រដែលសមស្របក៏គួរតែត្រូវបានជ្រើសរើស។ ទំរង់បែបបទ និងគោលការណែនាំសំរាប់ការតាមដាន គឺមានសារសំខាន់ខ្លាំងណាស់ ដើម្បីធានាថា ទិន្នន័យសមស្របត្រូវបានប្រមូល និងដើម្បីងាយស្រួលដល់ការវិភាគ។

ទាក់ទងនឹងទិសដៅដែលបានលើកឡើងក្នុងផែនការអភិវឌ្ឍន៍ឃុំ ការវាយតំលៃលើផលប៉ះពាល់នៃគំរោងវិនិយោគអភិវឌ្ឍន៍ គឺមិនបានបកស្រាយពិស្តារនៅក្នុងឯកសារនេះទេ ព្រោះថា គោលការណ៍លំអិតនៃការវាយតំលៃមិនទាន់មាននៅឡើយ។ ជាងនេះទៅទៀត វាក៏សំខាន់ផងដែរ ដែលត្រូវជ្រើសរើសមធ្យោបាយសមស្របមួយចំនួន ដើម្បីប្រមូលទិន្នន័យចាំបាច់សំរាប់គោលបំណង ដែលបានលើកឡើងអោយស្របទៅនឹងសមត្ថភាព ពេលវេលា និងថវិកាដែលឃុំមាន។

តារាងខាងក្រោម សង្ខេបពីឧបករណ៍សំរាប់ធ្វើការតាមដាននិងវាយតំលៃនៅថ្នាក់ឃុំ និងវិធីសាស្ត្រប្រមូលទិន្នន័យមួយចំនួន ដោយមានការពន្យល់បញ្ជាក់ពីអ្វីដែលត្រូវធ្វើនៅថ្នាក់ឃុំ និងអ្វីដែលឃុំខ្លួនឯង ត្រូវធ្វើព្រមទាំងរបៀបវិភាគ សរសេរ និងប្រើប្រាស់របាយការណ៍។ មធ្យោបាយផ្ទៀងផ្ទាត់ និងឧបករណ៍មួយចំនួនដែលបានលើកឡើងខ្លះៗនៅក្នុងតារាងនេះ គឺមិនទាន់បានបង្កើតឡើងនៅឡើយទេ។ ពត៌មាន ការអធិប្បាយ និងគោលការណ៍ណែនាំជាច្រើនទៀត សំរាប់ប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រទាំងនេះ ដែលអាចជួយបំភ្លឺការអនុវត្តន៍ការតាមដាននិងវាយតំលៃនៅថ្នាក់ឃុំ គឺមាននៅក្នុងផ្នែកផ្សេងទៀតនៃឯកសារនេះ។

| ប្រភេទ | ឧបករណ៍ និងវិធីសាស្ត្រ M&E នៅថ្នាក់ឃុំ |
|---|---|
| ប្រព័ន្ធទិន្នន័យ/តារាងកិច្ចការ | ▪ ប្រព័ន្ធទិន្នន័យឃុំ<br>▪ ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង<br>▪ តារាងកិច្ចការតាមដានសកម្មភាពសំខាន់ៗ ដែលកើតមានឡើងនៅក្នុងឃុំ<br>▪ ប្រព័ន្ធទិន្នន័យកិច្ចសន្យាកម្មវិធីសិលា<br>(ពត៌មានស្តីពីការកសាងសមត្ថភាពប៉ុណ្ណោះ) |
| របាយការណ៍ | ▪ របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ<br>▪ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់មូលនិធិឃុំ<br>▪ របាយការណ៍ហិរញ្ញវត្ថុពាក់កណ្តាលឆ្នាំរបស់មូលនិធិឃុំ<br>▪ របាយការណ៍ប្រចាំខែរបស់ឃុំ |
| ការពិនិត្យ | ▪ ពិនិត្យមើលប្រព័ន្ធកសាងផែនការ និងថវិកាឃុំឡើងវិញ<br>▪ ពិនិត្យមើលប្រព័ន្ធហិរញ្ញវត្ថុឃុំឡើងវិញ<br>▪ ពិនិត្យមើលប្រព័ន្ធអនុវត្តន៍គំរោង និងប្រព័ន្ធផ្តល់សេវារបស់ឃុំឡើងវិញ<br>▪ ពិនិត្យមើលប្រព័ន្ធតាមដាន និងវាយតំលៃនៅថ្នាក់ឃុំឡើងវិញ |
| ការចាត់ប្រមាណ/ ស្ទាបស្ទង់/និង ការសិក្សា | ▪ ការស្ទាបស្ទង់លើគំរោង និងក្រុមអ្នកទទួលផលពីគំរោង<br>▪ ការចាត់ប្រមាណលើសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ<br>▪ ការសិក្សាពីផលប៉ះពាល់ |
| សវនកម្ម | ▪ សវនកម្មហិរញ្ញវត្ថុប្រចាំឆ្នាំ (ត្រូវអនុវត្តដោយថ្នាក់ខេត្ត ក្រុង) |

## ៥.៦. ការប្រមូលនិងការវិភាគទិន្នន័យ ការប្រើប្រាស់ពត៌មាននិងការសរសេររបាយការណ៍

ក្នុងផ្នែកនេះបានធ្វើការបកស្រាយដោយសង្ខេប ពីឧបករណ៍ និងវិធីសាស្ត្រប្រមូលទិន្នន័យមួយចំនួន ដែលបានលើកឡើង ព្រមទាំងគោលបំណងរបស់វា និងអ្វីដែលឧបករណ៍ត្រូវធ្វើការតាមដាន។ ផ្នែកនេះក៏បានបកស្រាយផងដែរពីការងារអ្វីខ្លះដែលត្រូវអនុវត្ត សំរាប់ការតាមដាននិងវាយតំលៃលើការប្រើ ពត៌មាន និងការសរសេររបាយការណ៍លើពត៌មានដែលទទួលបាន។

### ៥.៦.១. ប្រព័ន្ធទិន្នន័យឃុំ (CDB)

ក្រុមប្រឹក្សាឃុំ មានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលទិន្នន័យឃុំ និងទិន្នន័យភូមិ ព្រមទាំងក្នុងការធ្វើ សុពលភាពនិងប្រើប្រាស់ទិន្នន័យទាំងនោះ។ ប្រព័ន្ធទិន្នន័យឃុំដែលអនុវត្តនៅលើកម្មវិធីកំព្យូទ័រ គឺត្រូវ

បានចាត់ចែង និងគ្រប់គ្រងដោយមន្ទីរផែនការខេត្ត (PDoP)។ ប្រព័ន្ធទិន្នន័យឃុំ ត្រូវបានទទួលស្គាល់ថាមានប្រយោជន៍និងមានទំនាក់ទំនងយ៉ាងខ្លាំង ហើយមិនតែប៉ុណ្ណោះ ពត៌មានដែលទទួលបានពីប្រព័ន្ធទិន្នន័យនេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ មិនត្រឹមតែនៅថ្នាក់ឃុំប៉ុណ្ណោះទេ។ ដើម្បីដឹងអោយបានលំអិតពីការអធិប្បាយ ការថែរក្សា និងការប្រើប្រាស់ CDB សូមមើលនៅក្នុងឯកសារណែនាំCDB។ ពត៌មានខាងក្រោមនេះ គឺសំរាប់ថ្នាក់ឃុំ តែប៉ុណ្ណោះ។

*គោលបំណង*

ប្រព័ន្ធទិន្នន័យឃុំត្រូវបានប្រើដើម្បីផ្តល់ទិន្នន័យភូមិ និងឃុំបច្ចុប្បន្នភាពប្រចាំឆ្នាំ ស្តីពីសូចនាករដែលអាចសំរេចបាន និងដែលមានទំនាក់ទំនងមួយចំនួន។ ទិន្នន័យនេះត្រូវបានប្រើសំរាប់ការកសាងផែនការ ការវិភាជន៍ធនធានដែលមាន និងសំរាប់តាមដានការប្រែប្រួលទាំងឡាយ។

*ការងារដែលត្រូវអនុវត្ត*

ទិន្នន័យរបស់ប្រព័ន្ធទិន្នន័យឃុំ ត្រូវបានប្រមូលដោយប្រើតារាងទិន្នន័យ ដែលមន្ទីរផែនការខេត្តផ្តល់អោយ។ ក្នុងកំឡុងពេលដំណើរការកសាងផែនការ អ្នកភូមិត្រូវពិនិត្យមើលប្រព័ន្ធទិន្នន័យឃុំដើម្បីត្រួតពិនិត្យ និងធ្វើសុពលភាពទិន្នន័យភូមិរបស់ខ្លួន។ ដើម្បីអោយអ្នកភូមិ អាចបញ្ចេញយោបល់កែលំអទិន្នន័យភូមិរបស់ខ្លួនបាន ក្នុងជំហានទី២ នៃដំណើរការកសាងផែនការនិងថវិកាអភិវឌ្ឍន៍ឃុំ គណៈកម្មាធិការកសាងផែនការ និងថវិកាត្រូវរៀបចំដំណើរការដូចខាងក្រោម :

- បង្ហាញទិន្នន័យភូមិដល់អ្នកភូមិ
- អ្នកភូមិត្រូវផ្តល់យោបល់កែលំអទិន្នន័យភូមិរបស់ខ្លួន
- អ្នកដំណាងភូមិត្រូវធ្វើសុពលភាពទិន្នន័យភូមិរបស់ខ្លួន ដោយត្រូវសរសេរបំពេញក្នុងសៀវភៅទិន្នន័យ។

***ការសរសេររបាយការណ៍***

ទិន្នន័យទាំងអស់ត្រូវបានប្រមូលផ្តុំនៅក្នុងតារាងទិន្នន័យឃុំ និងសៀវភៅទិន្នន័យភូមិ ដែលត្រូវបញ្ជូនទៅមន្ទីរផែនការខេត្ត។

*ការប្រើប្រាស់*

តារាងទិន្នន័យឃុំត្រូវបានប្រើកំឡុងពេលដំណើរការកសាងផែនការនិងថវិកាអភិវឌ្ឍន៍ឃុំ។ មន្ទីរផែនការខេត្ត គឺជាអ្នកធ្វើបច្ចុប្បន្នភាពលើប្រព័ន្ធទិន្នន័យឃុំ ក្រោយពេលទទួលបានទិន្នន័យភូមិ ដែលបានធ្វើសុពភាពពីឃុំនីមួយៗ។

## ៥.៦.២. ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID)

ទិន្នន័យទាក់ទងទៅនឹងកិច្ចសន្យាគំរោងអភិវឌ្ឍន៍ឃុំដែលប្រមូលដោយក្រុមប្រឹក្សាឃុំ និងដែលផ្តល់ថវិកាដោយមូលនិធិឃុំ និងធនធានផ្សេងៗទៀតរបស់ឃុំ នឹងអាចជួយអោយក្រុមប្រឹក្សាឃុំ កាន់តែងាយស្រួលក្នុងការតាមដានលើស្ថានភាពនៃការអនុវត្តន៍កិច្ចសន្យានិងការទូទាត់។ PID ដែលអនុវត្តនៅលើកម្មវិធីកំព្យូទ័រ គឺត្រូវបានចាត់ចែង និងគ្រប់គ្រងដោយ គ.ប្រ នៃ គ.អ.ជ.ខ។ ពត៌មាន ដែលមាននៅក្នុង PID មិនត្រឹមតែមានប្រយោជន៍សំរាប់ឃុំប៉ុណ្ណោះទេ តែថែមទាំងសំរាប់ថ្នាក់ខេត្ត និងថ្នាក់ជាតិផងដែរ។ ដើម្បីដឹងលំអិតពីការអធិប្បាយ ការថែរក្សា និងការប្រើប្រាស់ PID សូមមើលនៅក្នុងឯកសារណែនាំ PID។ ពត៌មានខាងក្រោមនេះ គឺសំរាប់ថ្នាក់ឃុំ តែប៉ុណ្ណោះ។

*គោលបំណង*

ទិន្នន័យស្តីពីការអនុវត្តន៍គំរោង ដែលមាននៅក្នុង PID បានធ្វើអោយក្រុមប្រឹក្សាឃុំ អាចធ្វើកាតាមដានលើការរីកចំរើននៃការអនុវត្តន៍គំរោង និងការទូទាត់។

*ការងារដែលត្រូវអនុវត្ត*

រៀបចំគំរោង និងកិច្ចសន្យា (បើចាំបាច់ត្រូវមានជំនួយពីអ្នកសំរបសំរួល)។ ត្រូវចុះទស្សនកិច្ចសិក្សាជាទៀងទាត់ និងត្រួតពិនិត្យដោយកន្លែងៗ (spot checks) ដើម្បីថ្លឹងប្រមាណពីការរីកចំរើនក្នុងការអនុវត្តន៍គំរោង ព្រមទាំងធ្វើការតាមដានលើគុណភាពផងដែរ (អាចត្រូវធ្វើដោយ PBC និងប្រជាពលរដ្ឋ)។ ជាងនេះទៅទៀត ត្រូវតាមដានរាល់ការទូទាត់សំរាប់ការអនុវត្តន៍គំរោង។

*ការសរសេររបាយការណ៍*

ត្រូវបញ្ចប់របាយការណ៍ចាំបាច់មួយចំនួន ដូចជារបាយការណ៍លើកគំរោង កិច្ចសន្យា ការរីកចំរើន និងរបាយការណ៍បញ្ចប់គំរោង ដោយប្រើបែបបទឯកភាពមួយ (មានក្នុងពេលខាងមុខ)។ របាយការណ៍ទាំងនេះ ត្រូវបញ្ជូនទៅ គ.ប្រ នៃ គ.អ.ជ.ខ (សំរាប់ជាប្រយោជន៍ដល់ LAU និង TSU)។

*ការប្រើប្រាស់*

ក្រុមប្រឹក្សាឃុំអាចប្រើពត៌មានដែលមាននៅក្នុង PID ដើម្បីពិនិត្យមើលការរីកចំរើន របស់កិច្ចសន្យា គំរោង និងថវិកា ព្រមទាំងថ្លឹងប្រមាណ និងពិភាក្សាពីបញ្ហាទាំងឡាយដែលកើតឡើងក្នុងការអនុវត្តន៍កិច្ចសន្យា និងដើម្បីធ្វើសេចក្តីសំរេចចិត្តលើបញ្ហាទាំងនោះ។

## ៥.៦.៣. តារាងកិច្ចការតាមដានសកម្មភាពសំខាន់ៗ ដែលកើតមាននៅក្នុងឃុំ និងប្រព័ន្ធរបាយការណ៍ឃុំ

ប្រព័ន្ធទាំងពីរនេះបានជួយអោយក្រុមប្រឹក្សាឃុំ ធ្វើការតាមដានរាល់ការអនុវត្តន៍ផែនការសកម្មភាពកសាងផែនការ និងការអនុវត្តន៍ថវិកាឃុំ។

*គោលបំណង*

ធ្វើអោយក្រុមប្រឹក្សាឃុំអាចប៉ាន់ប្រមាណ និងពិភាក្សាលើការរីកចំរើននៃការអនុវត្តន៍ផែនការសកម្មភាពអភិវឌ្ឍន៍ និងស្ថានភាពគណនេយ្យរបស់មូលនិធិឃុំ។ បើសិនណាមានបញ្ហាណាមួយត្រូវបានរកឃើញ ក្រុមប្រឹក្សាឃុំ ត្រូវសំរេចចិត្តធ្វើការដោះស្រាយភ្លាមៗ។

*ការងារដែលត្រូវអនុវត្ត*

ត្រូវធ្វើការពិភាក្សាជាប្រចាំ នៅពេលរៀបចំរបាយការណ៍ ដាក់ជូនទៅថ្នាក់ខេត្ត តាមពេលវេលាកំណត់ និងបែបបទឯកភាពមួយ។

*ការសរសេររបាយការណ៍*

- របាយការណ៍ប្រចាំខែរបស់ឃុំ
- របាយការណ៍ចំណូល ចំណាយប្រចាំខែរបស់ឃុំ
- របាយការណ៍ចំណូល ចំណាយពាក់កណ្តាលឆ្នាំរបស់ឃុំ
- របាយការណ៍ប្រចាំឆ្នាំរបស់ឃុំ

*ការប្រើប្រាស់*

ក្រុមប្រឹក្សាឃុំ ប្រើរបាយការណ៍ទាំងនេះដើម្បីពិនិត្យមើលការរីកចំរើនលើការអនុវត្តន៍ ធៀបទៅនឹងផែនការសកម្មភាព និងថវិកា ដែលបានអនុម័ត។

## ៥.៦.៤. ការអនុវត្តន៍តាមប្រព័ន្ធនានា និងការពិនិត្យឡើងវិញលើប្រព័ន្ធទាំងនោះ

គោលបំណងនៃការពិនិត្យមើលការអនុវត្តន៍តាមរបស់ក្រុមប្រឹក្សាឃុំលើប្រព័ន្ធ និង គោលនយោបាយ វិមជ្ឈការ គឺដើម្បីផែកមើល ថាតើក្រុមប្រឹក្សាឃុំបានអនុវត្តប្រព័ន្ធទាំងនេះ ក្នុងក្របខណ្ឌអាណត្តិច្បាប់របស់

ខ្លួនដែរឺទេ។ អវត្តមានរបស់សូចនាករដែលបានកំណត់ (ទាំងសូចនាករ បែបបរិមាណ និងបែប គុណភាព) និងមធ្យោបាយផ្ទៀងផ្ទាត់របស់វា គឺជាឧបសគ្គមួយ ដែលធ្វើអោយយើងមិនអាចធ្វើអោយ នីតិវិធីអនុវត្តការតាមដាន និងវាយតំលៃនេះបានកាន់តែល្អិត។

ចាំបាច់ត្រូវធ្វើការពិនិត្យមើលប្រព័ន្ធទាំងនេះឡើងវិញជាទៀងទាត់ ដើម្បីធានាពីប្រសិទ្ធភាព សមត្ថភាព និងភាពសមហេតុផលរបស់វា ដែលជាទូទៅ ត្រូវបានចាត់ចែង និងអនុវត្តដោយអ្នកនៅខាងក្រៅ ដូចជាPOLA និងថ្នាក់ជាតិជាដើម។ តែទោះបីជាយ៉ាងនេះក៏ដោយ ក្រុមប្រឹក្សាឃុំ គួរតែពិនិត្យលើការអនុវត្តន៍ប្រព័ន្ធនានារបស់ខ្លួន ដោយខ្លួនឯងផង។

## ១. ប្រព័ន្ធកសាងផែនការនិងថវិកាអភិវឌ្ឍន៍ឃុំ

ប្រព័ន្ធមួយនេះ ត្រូវបានអនុវត្តជាលើកទីមួយ ក្នុងឆ្នាំ ២០០២។ ការត្រួតពិនិត្យជាទៀងទាត់ មួយត្រូវបានធ្វើឡើង ដើម្បីពិនិត្យមើលថាតើ ក្រុមប្រឹក្សាឃុំអនុវត្តតាមគោលការណ៍ណែនាំ នានាសំរាប់ការកសាងផែនការនិងថវិកាបានត្រឹមត្រូវដែរឺទេ។ កំណត់សំគាល់ដាច់ដោយឡែកមួយផ្សេងទៀត លើកឡើងនូវវិធីសាស្រ្តមួយចំនួន ដែលក្រុមប្រឹក្សាឃុំ អាចប្រើវាជាទៀងទាត់ ដើម្បីរៀបចំការពិនិត្យមើលដំណើរការកសាងផែនការឡើងវិញ មាននៅក្នុងឧបសម្ព័ន្ធទី៤ ក្នុង ឯកសារនេះ។

## ២. ប្រព័ន្ធហិរញ្ញវត្ថុឃុំ

ឯកសារណែនាំ និងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឃុំ ដល់ក្រុមប្រឹក្សាឃុំ គួរតែបញ្ចូលការត្រួតពិនិត្យសាមញ្ញៗមួយចំនួន ថាតើក្រុមប្រឹក្សាឃុំ អាចអនុវត្តប្រព័ន្ធហិរញ្ញវត្ថុនេះបានត្រឹមត្រូវហើយឺនៅ។

## ៣. ប្រព័ន្ធអនុវត្តគំរោងអភិវឌ្ឍន៍របស់ឃុំ

ប្រព័ន្ធនេះ ក៏កំពុងត្រូវបានបង្កើតឡើង។ ផ្នែកមួយដែលបកស្រាយពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ ព្រមទាំងវិធីសាស្ត្រដែលពួកគេត្រូវប្រើ គួរតែត្រូវបានដាក់បញ្ចូលក្នុងដំណាក់កាលលើកគំរោង និងក្នុងប្រព័ន្ធអនុវត្តគំរោងអភិវឌ្ឍន៍របស់ឃុំ ដែលអាចអោយឃុំអនុវត្តតាម និងអាចធ្វើការពិនិត្យមើលប្រព័ន្ធនេះឡើងវិញ ដើម្បីធានាអោយមានលទ្ធផលប្រកបដោយគុណភាពខ្ពស់ និងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព។

## ៤. ប្រព័ន្ធ M&E និងប្រព័ន្ធរបាយការណ៍របស់ឃុំ

ផ្នែកនេះផ្តល់នូវសំណើមួយចំនួនសំរាប់ការបង្កើតប្រព័ន្ធ M&E។ ដំបូងថ្នាក់ជាតិ និងថ្នាក់ខេត្តត្រូវបង្កើតប្រព័ន្ធនេះ បន្ទាប់មកទៀតត្រូវផ្តល់វគ្គបណ្តុះបណ្តាល និងធ្វើអោយមានប្រព័ន្ធនេះនៅថ្នាក់ឃុំ។ តួនាទីរបស់ក្រុមប្រឹក្សាឃុំក្នុងការត្រួតពិនិត្យប្រព័ន្ធនេះ នឹងត្រូវកំណត់នៅពេលក្រោយ។

ប្រព័ន្ធរបាយការណ៍របស់ក្រុមប្រឹក្សាឃុំ ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ ២០០៣។ ប្រព័ន្ធរបាយការណ៍នេះត្រូវបានរៀបចំឡើងជាលក្ខណៈបែបបទឯកភាពមួយ ជាពីរប្រភេទ គឺរបាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រចាំឆ្នាំ។ សង្ឃឹមថា គំរូរបាយការណ៍នេះ នឹងត្រូវបានធ្វើការវាយតំលៃ និងកែលំអបន្ថែមទៀត ក្នុងពេលខាងមុខ ដើម្បីអោយស្របទៅតាមសមត្ថភាពដែលកាន់តែប្រសើរឡើង របស់ក្រុមប្រឹក្សាឃុំ និងមន្ត្រី POLA ដែលជាអ្នកទទួលខុសត្រូវ និងរៀបចំរបាយការណ៍ទាំងនេះ។ ជាការសំខាន់ដែលឃុំ ត្រូវតែអនុវត្តតាមគំរូការប្រព័ន្ធរបាយការណ៍ផ្សេងៗបានប្រសើរឡើង។ ជាងនេះទៅទៀត ឃុំគួររៀបចំតែរបាយការណ៍ប្រចាំឆ្នាំមួយសំរាប់ប្រព័ន្ធកសាងផែនការនិងហិរញ្ញវត្ថុ។

## ៥.៦.៥. ការជាវប្រមាណ និងការស្ទាបស្ទង់

មានប្រធានបទជាច្រើនដែលក្រុមប្រឹក្សាឃុំចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ ដូចខាងក្រោមនេះ:

- គុណភាពរបស់លទ្ធផលគំរោង
- ការប្រើប្រាស់ និងថែរក្សាលទ្ធផល និងឧបករណ៍
- ការចូលរួម
- ការផ្តល់សេវាកម្ម
- ទស្សនៈរបស់ប្រជាពលរដ្ឋ ស្តីពីភាពសមហេតុផល ទំនាក់ទំនង តំលៃ និងគុណភាពសេវាកម្ម និងវិនិយោគ។

ការថ្លឹងប្រមាណ និងការស្ទាបស្ទង់តូចៗ គឺជាវិធីសាស្ត្រដ៏ល្អបំផុតដែលក្រុមប្រឹក្សាឃុំត្រូវប្រើ។ វាមានប្រយោជន៍បំផុតដែលក្រុមប្រឹក្សាឃុំ អាចរៀនពីរបៀបធ្វើផែនការ របៀបអនុវត្ត និងរបៀបប្រើប្រាស់ប្រភេទថ្លឹងប្រមាណ និងស្ទាបស្ទង់សាមញ្ញៗ សំរាប់អនុវត្តទៅតាមស្ថានភាពចាំបាច់មួយចំនួន។ ទោះបីយ៉ាងណាក៏ដោយ ជាអាទិភាពត្រូវធ្វើអោយបទដ្ឋាន និយមន័យ និងសូចនាករ ទាំងឡាយកាន់តែមានលក្ខណៈច្បាស់លាស់នៅថ្នាក់ឃុំ សំរាប់បញ្ហាសំខាន់ៗមួយចំនួននោះ យើងអាចចាប់ផ្តើមធ្វើផែនការសកម្មភាពសំខាន់ៗសំរាប់ការតាមដាននិងវាយតំលៃ។

## ៥.៧. ការគ្រប់គ្រង កាលវិធីផែនការ និងហិរញ្ញវត្ថុសំរាប់ការងារ M&E នៅថ្នាក់ឃុំ

### ៥.៧.១.ការរៀបចំផែនការតាមដាន និងវាយតំលៃនៅថ្នាក់ឃុំ

ការធ្វើផែនការតាមដាននិងវាយតំលៃសំរាប់ក្រុមប្រឹក្សាឃុំ ត្រូវតែមានទំរង់មួយដែលសាមញ្ញ និងងាយស្រួល។ ដើម្បីធ្វើផែនការ M&E សំរាប់ថ្នាក់ឃុំ ចាំបាច់មានត្រឹមតែតារាងកិច្ចការដ៏សាមញ្ញមួយ ដែលបង្ហាញពីអ្នកទទួលខុសត្រូវ ពេលវេលា ទីកន្លែង និងរបៀបអនុវត្តកិច្ចការទាំងនោះ ជាការគ្រប់គ្រាន់ ។ យើងអាចបំបែកតារាងកិច្ចការនោះអោយទៅជាប្រភេទផ្សេងៗគ្នា ឧទាហរណ៍ យើងអាចបំបែកវា ទៅជា <u>*ការប្រជុំ*</u> <u>*ដំណើរការកសាងផែនការ*</u> <u>*ដំណាក់កាលអនុវត្តគំរោង*</u> <u>*របាយការណ៍*</u> *និង* <u>*សកម្មភាពសំខាន់ៗសំរាប់ការតាមដាននិងវាយតំលៃ*</u> ជាដើម។ល។ សំរាប់ប្រភេទនីមួយៗនេះ ក្រុមប្រឹក្សាឃុំត្រូវ លើកឡើង និងធ្វើការពិភាក្សា បន្ទាប់មកទៀតត្រូវផ្តល់ការយល់ព្រមលើសកម្មភាពចាំបាច់ និងភាពញឹកញាប់ដែលត្រូវ

អនុវត្ត។ តារាងកិច្ចការ អាចត្រូវបានប្រើក្នុងកំឡុងពេលនៃការប្រជុំប្រចាំខែ ដើម្បីពិនិត្យមើលថាតើសកម្មភាពណាខ្លះបានអនុវត្តហើយ និងតើមានលទ្ធផលអ្វីខ្លះ។

កាលវិភាគសកម្មភាពមួយអាចត្រូវបានរៀបចំនៅរៀងរាល់ដើមឆ្នាំ ហើយយើងអាចធ្វើបច្ចុប្បន្នភាព និងសំរបសំរួលវានៅពេលដែលកាលវិភាគដំណើរការកសាងផែនការ និងផែនការសកម្មភាពសំរាប់អនុវត្តគំរោង ត្រូវបានរៀបចំរួចរាល់ហើយ។

### ៥.៧.២. ហិរញ្ញវត្ថុ និងធនធានសំរាប់តាមដាន និងវាយតំលៃថ្នាក់ឃុំ

ក្រុមប្រឹក្សាឃុំអាចពិនិត្យមើលថាតើមានធនធានគ្រប់គ្រាន់សំរាប់សកម្មភាព M&E ថ្នាក់ឃុំដែររឺទេ នៅក្នុងថវិកាដែលបានស្នើឡើង ដោយប្រើតារាងកិច្ចការ។ ចំណាយ សំរាប់សកម្មភាពដែលត្រូវបានធ្វើឡើងជាប្រចាំ ដូចជា ទស្សនៈកិច្ចសិក្សា ការតាមដានដំណើរការ កសាងផែនការ ឬប្រជុំ ជាទូទៅ គឺមិនច្រើននោះទេ។ ហើយការចំណាយទាំងនោះ ត្រូវតែជាផ្នែកមួយ នៃថវិកាដែលបានស្នើឡើង។ ក្រុមប្រឹក្សាឃុំគួរតែអោយច្បាស់ថាសកម្មភាព M&E ឬសកម្មភាពបន្ថែមពិសេសណាមួយ ត្រូវបានបញ្ចូលក្នុងថវិការបស់ខ្លួន ឧទាហរណ៍ ដូចជា ថវិកាសំរាប់ការចាត់ប្រមាណ ឬការស្ទាបស្ទង់។

## ៥.៨. ការកសាងសមត្ថភាពសំរាប់ការងារ M&E នៅថ្នាក់ឃុំ

### ៥.៨.១. ការជ្រើសរើសមន្ត្រីបង្គោល M&E

ក្រុមប្រឹក្សាឃុំទាំងមូលជាអ្នកទទួលខុសត្រូវលើការងារតាមដាននិងវាយតំលៃ ដូច្នេះ សមាជិកក្រុមប្រឹក្សាឃុំចាំបាច់ត្រូវតែមានការយល់ដឹងខ្លះៗ លើគោលការណ៍ជាមូលដ្ឋាន សំរាប់ការងារតាមដាននិងវាយតំលៃ។ ទោះបីយ៉ាងណាក៏ដោយ បន្ទាប់ពីវគ្គតំរង់ទិស និងការបង្កើតផែនការសកម្មភាព M&E រួមគ្នារួចមក ក្រុមប្រឹក្សាឃុំ គួរតែងតាំងមនុស្សចំនួនពីរនាក់ ដែលម្នាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី អោយទទួលខុសត្រូវលើការអនុវត្តន៍ផែនការសកម្មភាពតាមដាននិងវាយតំលៃ និងរាយការណ៍ពីការរីកចំរើនជូនក្រុមប្រឹក្សាឃុំ។ ម្នាក់ក្នុងចំណោមអ្នកទាំងពីរនេះ គួរតែជាសមាជិកក្រុមប្រឹក្សាឃុំ ហើយម្នាក់ទៀត គួរតែត្រូវបានស្នើ

ឡើងដោយគណៈកម្មាធិការកសាងផែនការនិងថវិកា ហើយដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ។ អ្នកទាំងពីរនេះ មានតួនាទីជាជនបង្គោលរបស់ឃុំ សំរាប់ការងារតាមដាន ត្រួតពិនិត្យ និងវាយតំលៃ។ ហើយអ្នកទាំងពីរនេះ ក៏អាចជាជនបង្គោលផងដែរសំរាប់ការបណ្តុះបណ្តាល និងសកម្មភាពកសាងសមត្ថភាពផ្សេងៗទៀត ស្តីពីការងារតាមដាននិងវាយតំលៃ។

### ៥.៨.២. ការកសាងសមត្ថភាព

មានប្រធានបទជាច្រើន រួមមាន M&E សំរាប់ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ។ ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ គឺជាការទទួលខុសត្រូវរបស់មន្ត្រី POLA ដោយមានជំនួយពីក្រុមផ្សេងៗ ដូចជា NGO រតនាគារខេត្ត/មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មន្ទីរផែនការ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។ល។ ភាគីនីមួយៗមានទំនួលខុសត្រូវ ក្នុងការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំពីតួនាទី M&E និងភារកិច្ចផ្សេងៗរបស់ក្រុមប្រឹក្សាឃុំស្តីពីការកសាងផែនការ ការរៀបចំហិរញ្ញវត្ថុ ការអនុវត្តន៍និងការគ្រប់គ្រង។

អណត្តិ៥ឆ្នាំរបស់ក្រុមប្រឹក្សាឃុំ គឺជារយៈពេលមួយដ៏សមស្រប ដែលអាចអោយយើងប្រើវិធីសាស្ត្រ ដែលមានលក្ខណៈលំបាកបន្តិចម្តងៗ ពីដំណាក់កាលមួយទៅដំណាក់កាលមួយ (step-wise approach) ដើម្បីបង្កើនសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ លើគ្រប់ចំណុចទាំងអស់ រួមទាំងលើជំនាញតាមដាន និងវាយតំលៃផងដែរ ។ វិធីសាស្ត្រនេះ គឺ :

#### *ឆ្នាំទី១ ~ ការបង្កើតគោលការណ៍ណែនាំជាមូលដ្ឋាន និងផែនការសកម្មភាព M&E*

- <u>ជំហានទី១</u> : កំណត់ពីភារកិច្ច M&E របស់ក្រុមប្រឹក្សាឃុំ និងកំណត់សមាជិកនីមួយៗ ដែលត្រូវអនុវត្តការងារ M&E និងរបាយការណ៍។
- <u>ជំហានទី២</u> : ផ្តោតលើការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ អំពីវដ្តនៃការកសាងផែនការ និងការអនុវត្តន៍គំរោង ទស្សនទានជាមូលដ្ឋានស្តីពីការតាមដាន និងការតាមដានការអនុវត្តន៍ គំរោង រួមទាំងការប្រើប្រាស់របាយការណ៍ និងគំរូរបាយការណ៍។
- <u>ជំហានទី៣</u> : រៀបចំកាលវិភាគសកម្មភាពតាមដានដ៏សាមញ្ញមួយសំរាប់ក្រុមប្រឹក្សាឃុំ។

### ឆ្នាំទី២-៤ ៖ ការបង្រួមបញ្ចូលគ្នា ៖ ការតាមដានលើការវិនិយោគប្រចាំឆ្នាំ និងវិធីសាស្ត្រផ្សេងៗគ្នា

- <u>ជំហានទី៤</u> ៖ ការតាមដានរបស់ឃុំកាន់តែផ្តោតស៊ីជំរៅទៅលើការអនុវត្តន៍ផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំមួយ ដែលមានគំរោងអភិវឌ្ឍន៍ជាច្រើន (មិនមែនផ្តោតទៅលើតែគំរោងណាតែមួយនោះទេ) ដែលរួមមានគំរោងទាំងឡាយដែលផ្តល់មូលនិធិដោយឃុំខ្លួនឯង និង/ឬ ដោយធនធានផ្សេងៗទៀត ហើយដែលអនុវត្តដោយអ្នកម៉ៅការឯកជន និងត្រួតពិនិត្យផ្ទាល់ដោយក្រុមប្រឹក្សាឃុំ ព្រមទាំងអនុវត្តដោយអង្គការ និងភ្នាក់ងារផ្សេងៗទៀត។
- វិធីសាស្ត្របែបគុណភាព ដែលមានលក្ខណៈកាន់តែលំបាកទៅៗ ត្រូវបានបញ្ចូលក្នុងការកសាងសមត្ថភាពលើការតាមដាន។

### ឆ្នាំទី៥ ៖ កំរិតខ្ពស់ ៖ ផលប៉ះពាល់ និងការវាយតំលៃ

- <u>ជំហានទី៥</u>៖ ឃុំត្រូវរៀនពីរបៀបវាយតំលៃផែនការអភិវឌ្ឍន៍ឃុំ របៀបថ៉ាន់ប្រមាណពី ផលប៉ះពាល់របស់សកម្មភាពអភិវឌ្ឍន៍ ដែលបានអនុវត្តច្រើនឆ្នាំកន្លងមក ហើយវាយតំលៃពីសមិទ្ធិផល របស់គោលដៅអភិវឌ្ឍន៍ឃុំ ដើម្បីទុកជាមូលដ្ឋានគ្រឹះ សំរាប់ការកសាងផែនការអភិវឌ្ឍន៍ឃុំនៅឆ្នាំខាងមុខទៀត។ រដ្ឋាភិបាលនឹងផ្តល់គោលការណ៍ណែនាំស្តីពីការងារនេះ។

### កំណត់សំគាល់ ៖

- ការវាយតំលៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ អាចអោយយើងដឹងពីកំរិតសមត្ថភាពរបស់ពួកគេ លើការងារ M&E ហើយការកសាងសមត្ថភាព ត្រូវធ្វើឡើងតាមវិធីសាស្ត្រច្រើនបែបច្រើន យ៉ាងដោយផ្អែកលើលទ្ធផលវាយតំលៃនេះ។
- បង្កើតឯកសារបណ្តុះបណ្តាលសំរាប់ការតាមដាន និងវាយតំលៃថ្នាក់ឃុំដោយផ្ទៀងផ្ទាត់ជាមួយកំរិតសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំដែលបានកំណត់នៅខាងលើ។ គួរតែត្រូវផ្តោតលើពត៌មានអ្វី ដែលចាំបាច់ ហើយត្រូវប្រើពត៌មានទាំងនោះបែបណា។ ការងារតាមដាននិងវាយតំលៃបច្ចុប្បន្ន គឺតូចងាយយល់ មិនសាំញ៉ាំ និងមានទំនាក់ទំនងទៅនឹងដំណាក់កាល និងសកម្មភាពទាំងឡាយ របស់

ក្រុមប្រឹក្សាឃុំ ដូចជាដំណើរការកសាងផែនការ ការអនុវត្តន៍ ការគ្រប់គ្រងហិរញ្ញវត្ថុ និងតំរូវការផ្សេងៗសំរាប់របាយការណ៍។ល។

- បង្កើតមេរៀនសំរាប់ការបណ្តុះបណ្តាល និងឯកសារនានាដែលសមស្របសំរាប់ក្រុមប្រឹក្សាឃុំ។

# សៀវភៅណែនាំ ស្តីពី
# ការតាមដាន និងវាយតម្លៃរបស់
# កម្មវិធីសិលា

## ផ្នែកទី ៦

## ការប្រមូល និង វិភាគទិន្នន័យ



## ៦.១ ការប្រមូលទិន្នន័យ

### ៦.១.១. ទិន្នន័យ និងការប្រមូលទិន្នន័យ

ការតាមដាន និងវាយតំលៃ គឺជាប្រព័ន្ធមូលដ្ឋានមួយសំរាប់ប្រមូល និងវិភាគទិន្នន័យ ដើម្បីទទួលបានពត៌មាន។ ទិន្នន័យ មានពីរប្រភេទ គឺ :

- **ទិន្នន័យបរិមាណ** : ជាចំនួន ។
- **ទិន្នន័យគុណភាព** : ជាពាក្យពេចន៍ ការរៀបរាប់ សកម្មភាព អារម្មណ៍ ឬជាជំនឿ ។ល។

ការតាមដាន និងវាយតំលៃដែលល្អ ជានិច្ចជាកាល ត្រូវប្រើទិន្នន័យទាំងពីរប្រភេទនេះបញ្ចូលគ្នា។ **ទិន្នន័យបរិមាណ** មានសារៈប្រយោជន៍ក្នុងការផ្តល់ពត៌មានស្តីពីចរិកលក្ខណៈរបស់ភូមិ ស្រុក ខេត្ត និងរហូតដល់ចរិកលក្ខណៈរបស់ប្រទេសទាំងមូលផងដែរ។ ហើយវិធីសាស្រ្តសំរាប់ប្រមូលទិន្នន័យបរិមាណនេះ អាចមានតាំងពីការរាប់ចំនួនតាមរបៀបងាយៗអំពីធនធាន លទ្ធផល ឬអ្នកទទួលផលពីគំរោង រហូតដល់វិធីសាស្រ្តដែលកាន់តែមានលក្ខណៈស្មុគស្មាញ ដូចជាការសង្កេតជាផ្លូវការលើក្រុមគ្រួសារ និងការចុះធ្វើជំរឿនជាដើម ។ ល។

ម្យ៉ាងទៀត **ទិន្នន័យគុណភាព** គឺមានតួនាទីយ៉ាងប្រសើរក្នុងការពណ៌នា និងពន្យល់ពីអ្វីដែលបានកើតឡើង ប៉ុន្តែការវិភាគលើទិន្នន័យគុណភាពនេះ វាលំបាកជាងការវិភាគលើទិន្នន័យបរិមាណ។ នេះគឺជាឧទាហរណ៍ពីវិធីសាស្រ្តមួយចំនួន សំរាប់ប្រមូលទិន្នន័យគុណភាពៈ ការសំភាសន៍ស៊ីជំរៅជាមួយអ្នកផ្តល់ពត៌មានសំខាន់ ការពិភាក្សាជាក្រុមចំណាប់អារម្មណ៍ ករណីសិក្សា គំនូរផែនទី ការសង្កេត ការអោយចំណាត់ថ្នាក់លើស្ថានភាពសុខភាព។ល។

ក្នុងនាមជាអ្នកចូលរួមនៅក្នុងការតាមដាននិងវាយតំលៃ ជាការសំខាន់ ត្រូវយល់ដឹងពីវិធីសាស្រ្តផ្សេងៗគ្នាសំរាប់ប្រមូលទិន្នន័យ និងយល់ពីគុណសម្បត្តិ និងគុណវិបត្តិរបស់វាអោយបានច្បាស់។ ដូចនេះ នៅពេល

ដែលអ្នកបានយល់ដឹងច្បាស់ហើយនោះ អ្នកអាចជ្រើសរើសវិធីសាស្ត្រ ដែលសមស្របទៅតាមប្រភេទនៃសកម្មភាព ឬគំរោង ដែលអ្នកត្រូវធ្វើការតាមដាននិងវាយតំលៃ។

ជាទូទៅ ដំណើរការប្រមូលទិន្នន័យនេះ មានជំហានមួយចំនួន ដូចខាងក្រោម :

១. ជ្រើសរើសវិធីសាស្ត្រដែលសមស្របសំរាប់ប្រមូលទិន្នន័យ
២. រៀបចំទំរង់បែបបទប្រមូលទិន្នន័យ
៣. បណ្តុះបណ្តាលបុគ្គលិកលើការប្រើប្រាស់ឧបករណ៍
៤. អនុវត្តការប្រមូលទិន្នន័យ

នៅក្នុងការតាមដាន យើងត្រូវសំរេចចិត្តពីពេលវេលាសំរាប់ប្រមូលទិន្នន័យដែលចាំបាច់ ( ឧទាហរណ៍ដូចជា ១ដងក្នុង ១សប្តាហ៍ ១ដងក្នុង១ខែ ឬ ១ដងក្នុង រយៈពេល៣ខែ...។ល។ ) ។ ដោយឡែកសំរាប់ការវាយតំលៃ យើងត្រូវធ្វើការសំរេចចិត្តលើការកំណត់សំណាក។

### ៦.១.២. ឧទាហរណ៍ នៃវិធីសាស្ត្រប្រមូលទិន្នន័យមួយចំនួន

នៅខាងក្រោមនេះ គឺការពិពណ៌នាដោយសង្ខេប ពីវិធីសាស្ត្រប្រមូលទិន្នន័យដែលធ្លាប់បានប្រើ :

១. **ពិនិត្យឡើងវិញលើឯកសារដែលមានស្រាប់** : វិធីសាស្ត្រនេះ ក៏អាចត្រូវបានហៅថាជាការពិនិត្យលើឯកសារដែលមានស្រាប់។ វិធីសាស្ត្រនេះ អាចអោយយើងយល់បានច្បាស់ពីពត៌មានជាមូលដ្ឋាន ស្តីពី គំរោង និងអាចសន្សំពេលវេលាបានច្រើន។

២. **ការសង្កេតផ្ទាល់ :** ការសង្កេតផ្ទាល់នេះ មានន័យថា ជាការសង្កេតជាប្រព័ន្ធលើវត្ថុ ហេតុការណ៍ ប្រជាពលរដ្ឋ ។ល។ និងជាការកត់ត្រានូវអ្វីដែលអ្នកបានឃើញ។ ជាវិធីសាស្ត្រមួយដ៏ល្អ ដែលយើងត្រូវ ត្រួតពិនិត្យលើចំលើយទាំងឡាយ ដែលអ្នកបានមកពីការសំភាសន៍ជាមួយប្រជាពលរដ្ឋ ឬបានមកពីការពិភាក្សាជាក្រុម ឬពីវិធីសាស្ត្រស្រដៀង១គ្នានេះ។ ការសង្កេតផ្ទាល់នេះ ជានិច្ចកាល

តែងតែត្រូវការជា ចាំបាច់ សំរាប់ការវាយតំលៃ។ តាមរយៈវិធីសាស្ត្រនេះ បញ្ជីត្រួតពិនិត្យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការ សង្កេតជាលក្ខណៈប្រព័ន្ធ និងតាមបែបបទគំរូ (ធ្វើដូចនេះ យើងអាចប្រៀបធៀបលទ្ធផលជាមួយគ្នា ទៅវិញទៅមក ក្នុងករណីដែលការប្រមូលទិន្នន័យ ត្រូវបានធ្វើឡើងដោយមនុស្សផ្សេងៗគ្នា ដោយឯករាជ្យនោះ)។ ការចុះទស្សនកិច្ចមូលដ្ឋាន ក៏ជាឱកាសមួយក្នុងការសង្កេតក្រៅផ្លូវការ ដែលបានអនុវត្តជាញឹកញាប់។ ដូចនេះ អ្នកគ្រប់គ្រងគំរោង ឬមន្ត្រីចុះមូលដ្ឋានត្រូវចងចាំ " នៅក្នុងគំនិត របស់គាត់ " ពីអ្វីដែលគាត់ចង់សង្កេត។ ក្រោយពីត្រលប់មកពីទស្សនកិច្ចវិញ អ្នកត្រូវរំលឹកឡើងវិញ និងកត់ត្រានូវអ្វីដែលអ្នកបានសង្កេតឃើញ កំឡុងពេលទស្សនកិច្ចរបស់អ្នក ឬអ្នកអាចពិភាក្សាជាមួយ បុគ្គលិកផ្សេងៗទៀតរបស់គំរោង។

៣. **ការសំភាសន៍ :** ការសំភាសន៍ គឺជាឧបករណ៍មួយយ៉ាងសំខាន់ ដែលត្រូវបានប្រើ ក្នុងការប្រមូលទិន្នន័យ (ដូចជាការសង្កេតដែរ)។ ការសំភាសន៍ អាចមានលក្ខណៈជារចនាសម្ព័ន្ធ (មានន័យថាជាការ សំភាសន៍ដោយប្រើកំរងសំនួរ ដែលសំនួរទាំងនេះ ត្រូវបានសួរតាមលំដាប់លំដោយ ហើយចំលើយក៏ ត្រូវបានសរសេរសំរាប់សំនួរនីមួយៗ នៅក្នុងកំរងសំនួរនោះផងដែរ)។ ការសំភាសន៍ក៏អាចគ្មានរចនាសម្ព័ន្ធផងដែរ (ការសំភាសន៍ប្រភេទនេះ គឺត្រូវប្រើសំនួរបើក ហើយសំនួរបន្ទាប់មកទៀត គឺផ្អែកលើចំលើយ ដែលឆ្លើយទៅនឹងសំនួរដែលបានសួរ)។ សំរាប់ការសំភាសន៍ដែលគ្មានរចនាសម្ព័ន្ធបែបនេះ ភាគច្រើនគឺត្រូវប្រើសំរាប់ការសំភាសន៍ក្រៅផ្លូវការ។ ជាទូទៅមានការសំភាសន៍ចំនួន៤ប្រភេទផ្សេងៗគ្នា សំរាប់ជ្រើសរើស។ ប្រភេទទាំង៤នោះ គឺ :

- **ការសំភាសន៍ជាបុគ្គល**

  ការសំភាសន៍ជាបុគ្គល គឺត្រូវបានប្រើប្រាស់ ដើម្បីប្រមូលទិន្នន័យជាក់លាក់។ ការសំភាសន៍ប្រភេទនេះ គឺត្រូវបានធ្វើឡើងជាមួយនឹងមនុស្សមួយចំនួន ដែលត្រូវបានជ្រើសរើសដោយផ្អែកលើគោលបំណងនៃការសំភាសន៍។ ការសំភាសន៍ជាបុគ្គល គឺសមស្របសំរាប់ការប្រមូលទិន្នន័យលើប្រធានបទដែលមានលក្ខណៈជារំញោត ឬលើប្រធាបបទស្តីពីជំលោះ ឬការមិនព្រមព្រៀងដែលកើតមានឡើងនៅក្នុងសហគមន៍។

- **ការសំភាសន៍ជាមួយអ្នកផ្តល់ពត៌មានសំខាន់ៗ**

  អ្នកផ្តល់ពត៌មានសំខាន់ គឺជាមនុស្សម្នាក់ ដែលមានចំណេះដឹងពិសេស អំពីប្រធានបទអ្វីមួយ ហើយអ្នកសំភាសជាមួយពួកគេ ដើម្បីប្រមូលយកចំណេះដឹងពិសេសៗទាំងនោះ។ ឧទាហរណ៍ អ្នកអាចសំភាសជាមួយពេទ្យឆ្មប ដើម្បីស្វែងយល់ពីការអនុវត្តន៍ក្នុងការបង្កើតកូន ឬ ជាមួយប្រធានភូមិ ពីព្រោះជាធម្មតា គាត់មានការយល់ដឹងច្រើនពីអ្វីដែលទាក់ទងទៅនឹងភូមិរបស់គាត់។ ជាធម្មតា អ្នកផ្តល់ពត៌មានសំខាន់ គឺអាចឆ្លើយទៅនឹងសំនួរអំពីចំណេះដឹង និងឥរិយាបទ របស់អ្នកផ្សេងទៀតបាន។

- **ការសំភាសន៍ជាក្រុម**

  ការសំភាសន៍ជាក្រុម គឺត្រូវបានរៀបចំឡើង ដើម្បីប្រមូលទិន្នន័យនៅថ្នាក់ភូមិនិងសហគមន៍។ ការសំភាសន៍បែបនេះ ជានិច្ចកាល អាចធ្វើអោយយើងទទួលបានទិន្នន័យ ជាច្រើន ហើយក្នុងការសំភាសន៍បែបនេះ អ្នកចូលរួមទាំងអស់ក៏បានធ្វើការពិនិត្យផ្ទៀងផ្ទាត់ចំលើយគ្នាទៅវិញទៅមក ព្រោះពួកគេត្រូវតែពាក្យសំដីគ្នាទៅវិញទៅមក កំឡុងពេលសំភាសន៍។ ការសំភាសន៍បែបនេះ មិនអាចប្រើដើម្បីប្រមូលទិន្នន័យបែបរំញោចបានទេ ហើយវាក៏តំរូវអោយមានពេលវេលា និងការខិតខំយ៉ាងច្រើន ដើម្បីរៀបចំការសំភាសន៍ប្រភេទនេះ។ ការសំភាសន៍ប្រភេទនេះ ចាំបាច់ត្រូវអោយមានអ្នកសំរបសំរួលម្នាក់ ដើម្បីដឹកនាំការពិភាក្សា។ នៅពេល ដែលមានអ្នកចូលរួមលើសពី២០នាក់ឡើងទៅ យកល្អគួរតែបំបែកអ្នកចូលរួមទាំងនេះ អោយទៅជាក្រុមតូចៗ។

ជាងនេះទៅទៀត ការបែងចែកអ្នកចូលរួមអោយទៅជាក្រុមតូចៗ ក៏អាចជួយអោយយើងទទួលបានទិន្នន័យកាន់តែមានគុណភាពថែមទៀត។ ទិន្នន័យដែលយើងទទួលបានពីក្រុមអ្នកចូលរួមជាបុរស អាចខុសគ្នាពីទិន្នន័យដែលយើងទទួលបានពីក្រុមអ្នកចូលរួមជាស្ត្រី។ ឧទាហរណ៍ ផ្សេងទៀតពីការចែកក្រុម ដែលធ្វើអោយយើងទទួលបានចំលើយខុសគ្នាៗ គឺរវាងក្រុមអ្នកចូលរួមដែលមានវ័យចំណាស់ ជាមួយក្រុមដែលមានវ័យក្មេង ឬរវាងក្រុមអ្នកពិការ ជាមួយក្រុមមិនពិការ ។ល។

- **ការពិភាក្សាជាក្រុមចំណាប់អារម្មណ៍**

  ការពិភាក្សាជាក្រុមចំណាប់អារម្មណ៍ ត្រូវបានធ្វើឡើងដើម្បីពិភាក្សាលំអិតលើប្រធានបទជាក់លាក់មួយចំនួន ជាមួយក្រុមអ្នកដែលមានការយល់ដឹង ឬដែលមានចំណាប់អារម្មណ៍។ សំរាប់ការពិភាក្សាជាក្រុមចំណាប់អារម្មណ៍ ចាំបាច់ត្រូវមានអ្នកសំរបសំរួលម្នាក់។ ដើម្បីអោយយើងអាចចាត់ចែងបានល្អ ក្រុមអ្នកចូលរួមក្នុងការពិភាក្សានេះ គួរតែតូចៗបានហើយដែលមានគ្នា ចន្លោះពី៦ ដល់១២នាក់។

៤. **ការអង្កេត :** ជាវិធីសាស្ត្រមួយ ដែលជាទូទៅត្រូវបានប្រើដើម្បីប្រមូលទិន្នន័យបរិមាណ ដែលមានទំហំធំ។ ការប្រមូលទិន្នន័យ ដោយប្រើវិធីសាស្ត្រនេះ ជានិច្ចកាលត្រូវប្រើពេលវេលាច្រើន ហើយការវិភាគទិន្នន័យដែលប្រមូលបាន គឺត្រូវធ្វើឡើងដោយកុំព្យូទ័រ។ ឧទាហរណ៍ សំរាប់វិធីសាស្ត្រនេះ ដូចជា ការអង្កេតតាមគ្រួសារ ឬការជំរឿនជាដើម។ល។ វិធីសាស្ត្រជាផ្លូវការ ដូចជា ការអង្កេតនេះ គឺមានគុណសម្បត្តិយ៉ាងច្រើនក្នុងការបង្កើតទិន្នន័យបរិមាណ ដែលមានភាពត្រឹមត្រូវច្រើន និងដែលមានភាពជឿជាក់និងសុពលភាពខ្ពស់។ វិធីសាស្ត្រជាផ្លូវការ គឺមានលក្ខណៈជារចនាសម្ព័ន្ធ ដែលត្រូវអនុវត្តតាមនីតិវិធីដែលបានបង្កើតឡើងដ៏ត្រឹមត្រូវ ដែលអាចធ្វើអោយកំហុស ឬភាពលំអៀងរបស់វាមានតិចតួចបំផុត។ វិធីសាស្ត្រនេះ អាចបង្កើតឡើងនូវពត៌មាន ដែលមានលក្ខណៈជាប្រព័ន្ធ និងដែលអាចផ្ទៀងផ្ទាត់បាន។ តែវាក៏មានគុណវិបត្តិដែរ ដោយសារជានិច្ចកាលវាត្រូវចំណាយច្រើន ហើយទាមទារអោយអ្នកដែលទទួលខុសត្រូវលើការងារនេះ មានជំនាញនិងសមត្ថភាពខ្ពស់។

៥. **ពាក់កណ្តាលអង្កេត :** វិធីសាស្ត្រនេះ រួមបញ្ចូលការសំភាសន៍ជាបុគ្គលជាមួយមនុស្សចំនួនប្រហែលពី២៥ទៅ៥០នាក់ ដែលអ្នកទាំងនេះត្រូវបានជ្រើសរើសដោយប្រើបច្ចេកទេស កំណត់សំណាក។ កំរងសំនួររចនាសម្ព័ន្ធដែលមានសំនួរមួយចំនួនតូច ត្រូវបានប្រើសំរាប់វិធីសាស្ត្រប្រមូលទិន្នន័យប្រភេទនេះ។ វិធីសាស្ត្រពាក់កណ្តាលអង្កេតនេះ គឺមានប្រយោជន៍ ដើម្បីបង្កើតទិន្នន័យបរិមាណដែលយើងអាចប្រមូល និងវិភាគទិន្នន័យបានឆាប់រហ័ស។ តែទោះជាយ៉ាង

ណាក៏ដោយលទ្ធផលរបស់វិធីសាស្ត្រនេះ គឺមិនសូវមានលក្ខណៈទូទៅជាងលទ្ធផលរបស់វិធីសាស្ត្រអង្កេតជាផ្លូវការលើសំណាកឡើយ។

៦. **ករណីសិក្សា :** គឺជាការពិនិត្យប្រៀបធៀបយ៉ាងលំអិត លើមនុស្ស ឬលើរឿងរ៉ាវអ្វីមួយ។ ក្នុងករណីភាគច្រើន ប្រធានបទដែលយើងត្រូវធ្វើការសិក្សានេះ គឺមិនត្រូវបានជ្រើសរើសតាមដំណើរការកំណត់សំណាកជាផ្លូវការនោះទេ គឺជាញឹកញាប់ វាត្រូវបានជ្រើសរើសដោយខ្លួនឯង ឬត្រូវបានជ្រើសរើស ដោយផ្អែកលើមូលដ្ឋាននៃទំនាក់ទំនងមួយចំនួន។ ករណីសិក្សា អាចផ្តល់អោយយើងនូវការវិភាគស៊ីជំរៅនិងលំអិតមួយ ទៅលើក្រុម ឬមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ។ ដូចនេះ យើងមិនអាចទាញជាសន្និដ្ឋានរួមបាន ពីករណីសិក្សាបាននោះទេ។ តែវិធីសាស្ត្រនេះ អាចជាឧទាហរណ៍សំរាប់សិក្សាមួយដ៏ល្អ ដែលអាចបង្ហាញពីចំណុច ឬទិដ្ឋភាពមួយចំនួនរបស់កម្មវិធីមួយ ឬបញ្ហាណាមួយ ក្នុងករណីសិក្សានោះ។

### ៦.១.៣. ការរៀបចំឧបករណ៍ប្រមូលទិន្នន័យ

ឧបករណ៍ដែលប្រើសំរាប់ប្រមូលទិន្នន័យ គឺជាទំរង់មួយដែលត្រូវបានប្រើសំរាប់កត់ត្រាការឆ្លើយតប ឬ ការអង្កេត ក្នុងកំឡុងពេលធ្វើការនៅមូលដ្ឋាន។ ឧបករណ៍សំរាប់ប្រមូលទិន្នន័យ រួមមាន :

- កំរងសំនួរ សំរាប់ការសំភាសន៍ជាផ្លូវការ និងការសំភាសន៍បែបរចនាសម្ព័ន្ធ (គ្រប់សំនួរដែលត្រូវសួរទាំងអស់ ត្រូវចុះនៅក្នុងកំរងសំនួរនេះ សំរាប់ធ្វើការសំភាសន៍ផ្ទាល់ខ្លួន)
- សំនួរនាំមុខសំរាប់ការពិភាក្សាជាក្រុមចំណាប់អារម្មណ៍
- សំនួរនាំមុខ សំរាប់ការសំភាសន៍ស៊ីជំរៅ
- បញ្ជីត្រួតពិនិត្យ ដែលត្រូវប្រើក្នុងពេលអង្កេត
- ក្រដាស ឬសៀវភៅ សំរាប់កត់ត្រាទិន្នន័យ នៅពេលពិនិត្យឯកសារដែលពាក់ព័ន្ធ
- ក្រដាស ឬសៀវភៅ សំរាប់កត់ត្រាគំហើញនានា ពីការវាស់វែង

ខាងក្រោមនេះ គឺជាវិធីសាស្ត្រមួយចំនួន ដែលអាចជួយអោយយើងបង្កើតទំរង់បែបបទ ឬបញ្ជីត្រួតពិនិត្យខាង លើបាន :

១. ត្រូវសំរេចចិត្ត ថាតើឧបករណ៍អ្វីខ្លះត្រូវបង្កើតឡើង ហើយតើពត៌មានអ្វីខ្លះ ត្រូវប្រមូលដោយប្រើ ឧបករណ៍នីមួយៗនោះ។

២. ពិនិត្យឡើងវិញលើទំរង់ស្រដៀងៗគ្នានេះ ដែលបានប្រើក្នុងការសិក្សាស្រាវជ្រាវផ្សេងៗ ដើម្បីបានជាគំនិតអនុវត្តជាក់ស្តែងមួយចំនួន។

៣. ពិភាក្សារួមជាក្រុមតូចៗ ឬជាមួយក្រុមការងារ ដើម្បីលើកជាសំនួរ កំណត់ប្រភេទនៃវិធីសាស្ត្រ និង ដើម្បីរចនាឧបករណ៍នោះ។ បន្ទាប់មកទៀត ត្រូវរៀបចំជាសេចក្តីព្រាងដំបូងមួយ ដោយផ្អែកលើ លទ្ធផលនៃការពិភាក្សារួមជាក្រុមតូចនោះ។

៤. សុំយោបល់កែលំអលើសេចក្តីព្រាងដំបូងនោះ ពីអ្នកផ្សេងៗទៀត។

៥. កែលំអលើសេចក្តីព្រាងដំបូងនោះ ដោយផ្អែកលើយោបល់កែលំអ ដែលយើងទទួលបាន ហើយបន្ទាប់មកទៀត ត្រូវរៀបចំជាសេចក្តីព្រាងលើកទី២។

៦. ធ្វើតេស្តសាកល្បងសេចក្តីព្រាងលើទី២។ ការធ្វើតេស្តសាកល្បង មានន័យថា យើងយកសេចក្តីព្រាងលើកទី២នោះ ទៅអនុវត្តនៅមូលដ្ឋានជាមួយក្រុមមនុស្សមួយចំនួនតូច ដោយចាត់ទុកវាថា ជាឧបករណ៍មួយដែលត្រូវប្រើជាផ្លូវការហើយ។ ក្នុងកំឡុងពេលនិងក្រោយការធ្វើតេស្តសាកល្បងនេះ ត្រូវប្រមូលយកនូវរាល់យោបល់កែលំអ និងយោបល់ត្រលប់មួយចំនួនដូចខាងក្រោម ពីអ្នកសំភាសន៍ ឬអ្នកអង្កេត ព្រមទាំងពីអ្នកចូលរួមផងដែរ។

- លំដាប់លំដោយនៃសំនួរ
- ការយល់ដឹងលើសំនួរ ( ការប្រើប្រាស់ភាសា )
- ភាពសមស្របរបស់សំនួរ
- សរសេរអក្សរសំងាត់ចំពោះការឆ្លើយតប ( សូមពិនិត្យក្នុងផ្នែក ដែលបង្ហាញពីការរៀបចំកំរងសំនួរ ដើម្បីស្វែងយល់ពីអត្ថន័យរបស់វា)
- តំរូវការពេលវេលាដែលត្រូវបំពេញបញ្ចប់ទំរង់បែបបទនីមួយៗ

៧. ពិនិត្យឡើងវិញលើសេចក្តីព្រាងលើទី២នេះ
ដោយផ្អែកលើគំហើញដែលបានមកពីការសាកល្បង បន្ទាប់មកទៀត ត្រូវរៀបចំសេចក្តីព្រាងចុងក្រោយ។

## ៦.២. ការវិភាគទិន្នន័យ

ជាញឹកញាប់ ការតាមដាននិងវាយតំលៃ មិនត្រូវបានធ្វើអោយលើសពីការប្រមូលទិន្នន័យនោះទេ គ្រាន់តែមានការវិភាគលើទិន្នន័យដែលប្រមូលបាននោះបន្តិចបន្តួចប៉ុណ្ណោះ ឬអាចមិនមានការវិភាគទិន្នន័យផងក៏មាន។ ការវិភាគលើគំហើញនានា ដែលបានមកពីការតាមដាននិងវាយតំលៃ តំរូវអោយយើងពិនិត្យយ៉ាងដិតដល់លើទិន្នន័យដែលបានប្រមូល និងតំរូវអោយយើងធ្វើការបញ្ជាក់ និងរៀបចំទិន្នន័យទាំងនោះ ការយល់ដឹងពីទំនាក់ទំនងរបស់វា និងត្រូវកំណត់ពីធាតុសំខាន់ៗរបស់វា ដើម្បីអោយយើងអាចទទួលបានពត៌មាន និងអាចលើកជាសេចក្តីសិទ្ធិដ្ឋាន និងសេចក្តីសំរេចសំរាប់អនុវត្តសកម្មភាពបន្តទៀត។ ការវិភាគជាពិសេសការវិភាគដែលមាន ការចូលរួមពីអ្នកដែលពាក់ព័ន្ធ និងអ្នកទទួលផល អាចជួយអោយយើង :

- កែលំអការយល់ដឹង និង ភាពច្បាស់លាស់
- កំណត់ភាពលំអៀង ដោយការត្រួតពិនិត្យផ្ទៀងផ្ទាត់ពត៌មាន
- យល់បានច្បាស់ពីស្ថានភាព ហេតុការណ៍ និងដំណើរការ ព្រមទាំងអាចសំរេចបានការឯកភាពរួមមួយ
- ពង្រឹងភាពជាម្ចាស់លើសេចក្តីសន្និដ្ឋាន និងលើកទឹកចិត្តអោយមានការផ្លាស់ប្តូរ (ដោយប្រើការវិភាគបែបចូលរួម)។

### ៦.២.១. ដំណាក់កាលទាំង២ក្នុងការវិភាគទិន្នន័យ

ការវិភាគទន្នន័យ ជាមធម្មតាអាចចែកជាពីរដំណាក់កាល គឺ :

១. **ការសង្ខេបទិន្នន័យ** : ប្រមូលទិន្នន័យ ដែលបានមកពីការសំភាសន៍ជាក្រុម កំណត់ហេតុនៃការសង្កេត និងកំរងសំនួរដែលបានបំពេញរួច។ ធ្វើការសង្ខេប ដោយរាប់ចំនួនអ្នកដែលផ្តល់ចំលើយដូចៗគ្នា ឬដែលបាននិយាយស្រដៀងៗគ្នាលើ ប្រធានបទណាមួយ។

ក្នុងការរាប់ចំនួនបែបនេះ សំរាប់**ទិន្នន័យបិរមាណ** គឺវាមានភាពងាយស្រួលច្រើន (ព្រោះថា ទិន្នន័យបរិមាណ គឺនិយាយពីចំនួននេះឯង)។ ដើម្បីសង្ខេបទិន្នន័យ យើងត្រូវ :

- រាប់ចំនួន និងរៀបចំវា ដោយដាក់នៅក្នុងតារាងសង្ខេប
- បំបែកទិន្នន័យទៅតាមប្រភេទដែលពាក់ព័ន្ធ ( ឧទាហរណ៍ តាមភេទ អាយុ ការអប់រំ ការងារ ឬទីកន្លែងស្នាក់នៅជាដើម ។ល។ )
- បង្ហាញពត៌មានទៅតាមរូបភាពផ្សេងៗ ដូចជា ភាគរយ អត្រា មធ្យមភាគ ចំណុចកណ្តាល និងជាលំដាប់

ក្នុងការរាប់ចំនួនបែបនេះ សំរាប់**ទិន្នន័យគុណភាព** គឺវាមានការលំបាកជាង (ព្រោះថា វានិយាយពីការពិពណ៌នា)។ មុននឹងធ្វើការសង្ខេប យើងត្រូវធ្វើការងារបន្ថែម ទៀតមួយចំនួនសិន ដូចជា :

- ចុះលេខកូដលើការឆ្លើយតប ហើយធ្វើការរាប់ចំនួនវា
- កំណត់ប្រភេទផ្សេងៗគ្នានៃការឆ្លើយតប និងចំនួន ឬភាគរយនៃការឆ្លើយតបនោះ ទៅតាមប្រភេទនីមួយៗ
- បង្ហាញពត៌មាន ដែលរួមមានទាំងពត៌មានស្តីពីប្រវត្តិរបស់កម្មវិធី ឬ ការស្រង់ពាក្យសំដីពីការសំភាសន៍ យកមកបង្ហាញជាឧទាហរណ៍។

២. **ការបកស្រាយទិន្នន័យ** :បន្ទាប់ពីធ្វើការសង្ខេបទិន្នន័យរួចហើយ ត្រូវធ្វើការវិភាគទិន្នន័យដោយប្រុងប្រយ័ត្ន។ ទិន្នន័យមានន័យបែបណា ឬនិយាយពីអ្វី ? ត្រូវចាំអោយបានច្បាស់ពីទិសដៅ និងលទ្ធផលរំពឹងទុករបស់កម្មវិធី ឬគំរោងដែលយើងធ្វើការតាមដាននិងវាយតំលៃ។ ឆ្លើយតបទៅនឹងទិសដៅ និងលទ្ធផលរំពឹងទុកនេះ តើការសន្និដ្ឋានបែបណា និងអនុសាសន៍អ្វីខ្លះ ដែលត្រូវ

លើកឡើង? បើសិនជាក្នុងការប្រមូលទិន្នន័យ យើងបានប្រើឧបករណ៍មួយចំនួន ដូចជាការពិភាក្សាជាក្រុមចំណាប់ អារម្មណ៍ ការអង្កេត សំខាន់បំផុត យើងត្រូវសំរបសំរួលលទ្ធផលដែលបានមកពីឧបករហណ៍ទាំងនេះ ដើម្បីអោយប្រាកដថា វាគ្មានចំណុចផ្ទុយគ្នា។ អ្នកដែលយល់ដឹងពីការអនុវត្តន៍កិច្ចសន្យា អាច នឹងមានប្រយោជន៍ ក្នុងការពន្យល់ពីគំហើញមួយចំនួន។

## ៦.២.២. គោលការណ៍ណែនាំខ្លះទៅសំរាប់វិភាគទិន្នន័យ

ការវិភាគទិន្នន័យ គឺជាដំណើរការបន្តមួយ សំរាប់ពិនិត្យទិន្នន័យដែលបានប្រមូល ដើម្បីទទួលបានពត៌មាន ពីទិន្នន័យទាំងនោះ។ ប្រើការវិភាគសំរាប់បង្កើតសំនួរបន្ថែមទៀត ដើម្បីផ្ទៀងផ្ទាត់ពត៌មានដំបូង និងដើម្បីធ្វើការសន្និដ្ឋាន។ ការវិភាគទិន្នន័យ គឺជាដំណើរការមួយ ព្យាយាមធ្វើអោយទិន្នន័យដែលបានប្រមូល ប្រកបដោយអត្ថន័យនិងខ្លឹមសារ។ ការវិភាគទិន្នន័យ មិនគួរបញ្ឈប់ឡើយ រហូតដល់រាល់ទិន្នន័យទាំងអស់ ត្រូវបានប្រមូល ចប់សព្វគ្រប់។

គោលការណ៍ណែនាំមួយចំនួនសំរាប់វិភាគទិន្នន័យ គឺ :

- ពិនិត្យលើទិន្នន័យសង្ខេប ហើយសិក្សាស្វែងយល់ពីទំនាក់ទំនងពីផ្នែកមួយទៅផ្នែកមួយទៀត។ ពិនិត្យមើល ថាតើយើងអាចទាញជាសេចក្តីសន្និដ្ឋានបែបណា ផ្អែកលើទិន្នន័យសង្ខេបនោះ (ត្រូវចងចាំអោយច្បាស់នូវទិសដៅ និងគោលដៅរបស់គំរោង)។
- រៀបចំតារាងបញ្ហាសំខាន់ៗ និងរៀបចំតារាងគំហើញមួយ ស្របនឹងតារាងបញ្ហាសំខាន់ៗនេះ។ ពិនិត្យមើលលើទិន្នន័យរបស់អ្នក ដើម្បីស្វែងរកចំណុចខុសគ្នា ព្រមទាំងការប្រែប្រួល។ ត្រូវវិនិច្ឆ័យពីកំរិតសំខាន់ នៃពត៌មានដែលយើងទទួលបាននោះ។
- បង្កើតបញ្ជីរសំនួរដោយផ្អែកលើគោលបំណងនៃការវាយតំលៃ (ឬផ្អែកលើ ទិសដៅរបស់គំរោង) ហើយព្យាយាម បកស្រាយសំនួរទាំងនោះ ដោយប្រើទិន្នន័យដែលបានប្រមូល។
- ប្រើដ្យាក្រាម វិធីសាស្រ្តធ្វើចំណាត់ថ្នាក់ និងឧបករណ៍វិភាគផ្សេងៗទៀត។
- ពិនិត្យលើលទ្ធផល និងការសន្និដ្ឋានរបស់អ្នក ដោយបង្ហាញវាដល់អ្នកផ្តល់ពត៌មានសំខាន់ៗ ឬក្រុមសមាជិកសហគមន៍។

- ត្រូវធ្វើការទិទានខ្លួនឯង : តើអ្នកយល់លើពត៌មាននោះដែរឬទេ?
- លទ្ធផលត្រូវតែស៊ីសង្វាក់គ្នា និងមិនមានចំណុចផ្ទុយគ្នា។ សេចក្តីថ្លែងពីរដែលមានភាពផ្ទុយគ្នា គឺមិនអាចពិតប្រាកដដូចគ្នា ក្នុងពេលតែមួយនោះទេ។ បើសិនជាលទ្ធផលរបស់អ្នកផ្ទុយទៅនឹងពត៌មានដែលមានស្រាប់ (secondary data) ឬពត៌មានផ្សេងៗទៀតនោះ អ្នកត្រូវតែអាចពន្យល់ថា មកពីមូលហេតុអ្វី។ លទ្ធផលរបស់អ្នក គួរតែអាចជឿទុកចិត្តបាន។

## ៦.២.៣. ការគ្រប់គ្រងពត៌មាន និង ការទុកដាក់ទិន្នន័យ

ក្នុងអំឡុងពេលនៃការអនុវត្តន៍គំរោង ព្រមទាំងលទ្ធផលរបស់ការតាមដាន និងវាយតំលៃ គឺមានទិន្នន័យជាច្រើនដែលត្រូវបានប្រមូល។ ទិន្នន័យទាំងនេះ មិនមែនត្រូវការចាំបាច់ សំរាប់តែរយៈពេលខ្លី ក្រោយពីត្រូវបានប្រមូលនោះទេ តែវាក៏សំរាប់ប្រើនៅរយៈពេលយូរអង្វែងក្រោយៗមកទៀត (ដើម្បីប្រៀបធៀបស្ថានភាពមុននិងក្រោយការអនុវត្តន៍គំរោង)។ ជាការសំខាន់ ទិន្នន័យដែលបានប្រមូល ត្រូវតែរក្សាទុកដាក់អោយបានត្រឹមត្រូវ និងតាមលក្ខណៈជាប្រព័ន្ធ ដើម្បីងាយស្រួលរក នៅពេលណាដែលយើងត្រូវការវាម្តងទៀតនៅពេលក្រោយ។

ទិន្នន័យរបស់គំរោង គឺមិនមែនត្រូវបានប្រើដោយមនុស្សតែម្នាក់នោះទេ។ ដូចនេះ ជាការសំខាន់ បើសិនជានៅពេលណាដែលមាននណាម្នាក់ត្រូវការពត៌មាន ឬទិន្នន័យនេះ ពួកគេអាចរកឃើញដោយមិនចាំបាច់ពឹងពាក់ច្រើនទៅលើអ្នកដែលបានទុកដាក់ទិន្នន័យ ឬពត៌មាននេះទេ។ ដូចនេះ ចាំបាច់ត្រូវមានប្រព័ន្ធមួយដើម្បីទុកដាក់ និងគ្រប់គ្រងទិន្នន័យ និងពត៌មាន។ នៅពេលបង្កើតប្រព័ន្ធគ្រប់គ្រងពត៌មាននិងទិន្នន័យ មានសំនួរ៤ដែលយើងត្រូវពិចារណា :

### ១. តើទិន្នន័យ និងពត៌មានអ្វីខ្លះ ដែលត្រូវរក្សាទុក?

ការរក្សាទុកទិន្នន័យ និងពត៌មាន គឺត្រូវការសំរាប់កំរិត ពីរយ៉ាង : ដើម្បីកសាងយុទ្ធសាស្រ្តគំរោង និងតាមដានការប្រតិបត្តិ។ ជាគោលការណ៍ អ្វីៗដែលអ្នកសំរេចចិត្តធ្វើការតាមដាននិងវាយតំលៃនឹង ត្រូវរក្សាទុកតាមវិធីសាស្រ្តមួយចំនួន។ ទិន្នន័យដែលត្រូវរក្សាទុកទាំងនោះ មានជាច្រើន

ដូចជា ទិន្នន័យពីការរីកចំរើនលើការអនុវត្តន៍គំរោង ទិន្នន័យពីការពិនិត្យឡើងវិញលើគំរោងប្រចាំឆ្នាំ ទិន្នន័យរបស់ប្រព័ន្ធទិន្នន័យអ្នកពាក់ព័ន្ធសំខាន់ៗ ការផ្លាស់ប្តូរពត៌មានស្តីពីផលប៉ះពាល់ និងកំណត់ហេតុអង្គ ប្រជុំជាដើម។ល។ ដូច្នេះ ត្រូវពិចារណាដោយប្រុងប្រយ័ត្ន ថាតើទិន្នន័យ និងពត៌មានអ្វីខ្លះ ដែលត្រូវបញ្ជូនអោយអ្នកដ៏ទៃ ទោះជាសំរាប់សរសេររបាយការណ៍ និងសំរាប់សំរេចចិត្តក៏ដោយ។

## ២. តើអ្នកណាដែលត្រូវការទិន្នន័យ និងពត៌មាន ហើយនៅពេលណា ?

របៀបរក្សាទុកទិន្នន័យ គឺអាស្រ័យលើអ្នកដែលត្រូវការទិន្នន័យ និងពត៌មាននោះ និងថាតើពួកគេត្រូវការវាញឹកញាប់បែបណា។ ពត៌មានសំរាប់យុទ្ធសាស្ត្រគំរោង គឺមានសារៈសំខាន់ខ្លាំងណាស់សំរាប់អោយអ្នកគ្រប់គ្រងគំរោង (និងមន្ត្រីគំរោង ព្រមទាំងដៃគូអនុវត្តគំរោង ) គណៈកម្មាធិការដឹកនាំ តំណាងអ្នកពាក់ព័ន្ធសំខាន់ៗ និងសំរាប់ស្ថាប័នផ្តល់ជំនួយ។ ទិន្នន័យ និងពត៌មាន ស្តីពីប្រតិបត្តិការ គឺសំខាន់ដល់ក្រុមអ្នកអនុវត្តន៍ការងារនៅថ្នាក់មូលដ្ឋាន អ្នកគ្រប់គ្រងផ្នែកមួយរបស់គំរោង និងអ្នកដែលពាក់ព័ន្ធនឹងការងារនោះ។

សំរាប់ការរក្សាទុកទិន្នន័យ និងពត៌មាន ជាការសំខាន់ យើងត្រូវពិចារណាពីជំនាញរបស់អ្នកប្រើប្រាស់ និងប្រភេទនៃទំនាក់ទំនង ដែលអ្នកប្រើទាំងនោះពេញចិត្ត។ យើងត្រូវរក្សាទុកទិន្នន័យ និងពត៌មាន ដែលមាននៅលើក្រដាស នៅកន្លែងណាដែលគេត្រូវការប្រើវា។ សូមកុំសន្មត់ថា ទិន្នន័យនិងពត៌មានទាំងអស់ ត្រូវថតចំលង ផ្សព្វផ្សាយ និងរក្សាទុកនៅគ្រប់កំរិត និងគ្រប់កន្លែងនោះ។ ទិន្នន័យនិងពត៌មានទាំងនេះ ត្រូវតែរក្សាទុកនៅកន្លែងដែលគេត្រូវការប្រើវាតែប៉ុណ្ណោះ។ មានន័យថា ត្រូវទុកទិន្នន័យ និងពត៌មានដើមនៅនឹងអ្នកដែលបានផលិតវាឡើង។

## ៣. តើទិន្នន័យ និងពត៌មានអ្វីខ្លះដែលត្រូវរក្សាទុក ?

ដោយសារបច្ចុប្បន្ននេះ យើងមានកុំព្យូទ័រ ហើយមានមនុស្សកាន់តែច្រើនឡើងៗ ដែលអាចប្រើប្រាស់វាបាន ដូចនេះ គឺយើងគួរតែគ្រប់គ្រងទិន្នន័យ និងពត៌មាននេះដោយកុំព្យូទ័រ។ ត្រូវពិចារណាដោយប្រុងប្រយ័ត្នក្នុងការសំរេចចិត្តថាតើគួរថែរក្សា ឬមិនថែរក្សាទុកទិន្នន័យ និងពត៌មានតាមមធ្យោបាយជាអេឡិកត្រូនិកបែបនេះ។ មានគុណសម្បត្តិខ្លះៗដែរ ក្នុងការថែរក្សាទុកទិន្នន័យនិង

ពត៌មានជាអេឡិកត្រូនិក បើសិនជាមានមនុស្សជាច្រើនត្រូវការវា ឬក៏ ដើម្បីអោយមនុស្សម្នាក់ អាចទទួលបានទិន្នន័យនេះ យ៉ាងឆាប់រហ័សនៅកន្លែងផ្សេងៗគ្នានោះ។ ប៉ុន្តែ បើសិនជាទិន្នន័យ នេះមិនទំនងជានឹងត្រូវបានប្រើជាប្រចាំក្នុងពេលអនាគត ហើយបើសិនជាទិន្នន័យនេះ ចាំបាច់ សំរាប់តែមួយកន្លែង គឺវាមិនមានតំលៃ ក្នុងការបញ្ចូលវាទៅក្នុងកុំព្យូទ័រនោះទេ។

ជាការសំខាន់ ត្រូវរក្សាទុកទិន្នន័យលើក្រដាស និងតាមប្រព័ន្ធអេឡិត្រូនិច្ច ជាលក្ខណៈប្រព័ន្ធ។ ជា ញឹកញាប់ យើងប្រើផែនទី ស៊ីមី និងប្រអប់ ដើម្បីដាក់ទិន្នន័យលើក្រដាស ទៅតាមលំដាប់លំដោយ របស់វា (ដូចជា ទៅតាមកាលបរិច្ឆេទ ដែលទិន្នន័យបានទទួល ឬក៏កាលបរិច្ឆេទដែលពត៌មាន ត្រូវបានបង្កើតឡើង) ឬទៅតាមលំដាប់នៃប្រធានបទ (ឧ.ហ តាមប្រធានបទនីមួយៗ)។ តែសំរាប់ ទិន្នន័យអេឡិចត្រូនិក យើងត្រូវដាក់វាក្នុង sub-directory និងក្នុងប្រព័ន្ធទិន្នន័យ ដើម្បីកុំអោយ នៅពេលដែលយើងត្រូវការ មានការលំបាកក្នុងការស្វែងរកវាមកវិញម្តងទៀត។

ការពិពណ៌នាសង្ខេបពីទិន្នន័យសំខាន់ៗ ដែលបានប្រើនៅក្នុងកម្មវិធីសិលានេះ គឺមាននៅក្រោម។

## ៤. តើយើងត្រូវរក្សាទុកទិន្នន័យ និងពត៌មានទាំងនេះ ក្នុងរយៈពេលយូរប៉ុណ្ណា?

ត្រូវវាយតំលៃជាប្រចាំថា តើពត៌មាននិងទិន្នន័យអ្វីខ្លះដែលត្រូវរក្សាទុក ហើយតើពត៌មាននិង ទិន្នន័យ អ្វីខ្លះដែលត្រូវបោះបង់ចោល ។

ប្រព័ន្ធរក្សាទុកទិន្នន័យនិងពត៌មាន នឹងត្រូវស្ទះ និងត្រូវបានប្រើលើសកំណត់ បើសិនជាយើងមិន ធ្វើបច្ចុប្បន្នភាពវាជាប្រចាំទេនោះ។ គ្មានទិន្នន័យ និងពត៌មានណាដែលយើងត្រូវរក្សាទុកជារហូត ទេ។ តាមច្បាប់ មានឯកសារមួយចំនួន ត្រូវរក្សាទុកអោយបានប៉ុន្មានឆ្នាំ (ជាពិសេសឯកសារ ដែលទាក់ទងទៅនឹងហិរញ្ញវត្ថុ និងការចំណាយរបស់គំរោង)។ ទិន្នន័យនិងឯកសារមួយចំនួនទៀត ក៏អាចត្រូវការចាំបាច់ ក្នុងមួយកំឡុងពេលរបស់គំរោង ឬ ដែលអ្នកអាចយកវាមកធ្វើការប្រៀបធៀប ការផ្លាស់ប្តូរដែលបានកើតឡើងផងដែរ។ ទិន្នន័យដែលយើងត្រូវការសំរាប់យកមកធ្វើការប្រៀប ធៀបនេះ ដូចជាទិន្នន័យបន្ទាត់ដ្ឋាន ទិន្នន័យសង្ខេបការីកចំរើននៅក្នុងការអនុវត្តន៍ និងពត៌មាន ស្តីពីផលប៉ះពាល់ជាបណ្តោះអាស័ន្ន។ នៅមានទិន្នន័យនិងឯកសារមួយចំនួនទៀត ក្រៅពីសំរាប់

គំរោងខ្លួនឯង ក៏ជាប្រភពពត៌មាន មួយដ៏មានប្រយោជន៍សំរាប់អ្នកស្រាវជ្រាវ និងអ្នកវាយតំលៃ ទោះជាគំរោងបានបញ្ចប់ហើយក៏ដោយ។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏នៅមានទិន្នន័យជាច្រើនទៀត អាចត្រូវបានបោះបង់ចោលផងដែរ។ នេះជាការពិតមួយសំរាប់ឯកសារថតចំលង ក៏ដូចជាទិន្នន័យ ដែលបានបញ្ចូលក្នុងកុំព្យូទ័រដែរ។

## ៦.៣. ប្រព័ន្ធទិន្នន័យនៅក្នុងកម្មវិធីសិលា

មានទិន្នន័យមួយចំនួនដែលបានដើរតួរយ៉ាងសំខាន់ក្នុងកម្មវិធីសិលា :

- ប្រព័ន្ធទិន្នន័យឃុំ (CDB)
- ប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យារបស់កម្មវិធីសិលា (SCD)
- ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID)

### ៦.៣.១ ប្រព័ន្ធទិន្នន័យឃុំ

**ប្រព័ន្ធទិន្នន័យឃុំ** (CDB) ដែលបានចាប់ផ្តើមឡើង ជាប្រព័ន្ធទិន្នន័យរបស់កម្មវិធីសិលា គឺជាប្រព័ន្ធពត៌មានថ្នាក់ជាតិ របស់នាយកដ្ឋានផែនការនៃក្រសួងផែនការ។ CDB ត្រូវបានគ្រប់គ្រងដោយមន្ទីរផែនការខេត្ត ក្រោមការត្រួតពិនិត្យបច្ចេកទេសរបស់ក្រសួងផែនការ។

ក្នុងប្រព័ន្ធទិន្នន័យឃុំនេះ មានទិន្នន័យឯកភាព (standard data) ដែលត្រូវប្រមូលរៀងរាល់ឆ្នាំ ដោយប្រធានភូមិទាំងអស់ទូទាំងប្រទេស ដោយប្រើសៀវភៅទិន្នន័យភូមិជាឧបករណ៍ បូករួមជាមួយនឹងទិន្នន័យថ្នាក់ឃុំបន្ថែមទៀត (ជាធម្មតា ទិន្នន័យនេះត្រូវបានចាប់ផ្តើមប្រមូលពីខែធ្នូ ដល់ខែមករា)។ ទិន្នន័យទាំងនេះ គឺត្រូវបានបញ្ចូលចូលទៅក្នុងប្រព័ន្ធទិន្នន័យខេត្ត ហើយបន្ទាប់មកទៀត ពត៌មានស្តីពីស្ថានភាពឃុំ ត្រូវបានបង្កើតឡើងដោយផ្អែកលើទិន្នន័យដែលបានប្រមូលទាំងនេះ។ ពត៌មានស្តីពីស្ថានភាពឃុំនេះ នឹងត្រូវបានបោះពុម្ពហើយផ្ញើទៅថ្នាក់ស្រុកនិងឃុំ ដើម្បីទុកជាធនធានមួយ សំរាប់ដំណើរការកសាងផែនការមូលដ្ឋាន ហើយពត៌មានស្តីពី ស្ថានភាពឃុំជាអេឡិចត្រូនិក នឹងត្រូវបញ្ជូនទៅក្រសួងផែនការក្នុងក្រុងភ្នំពេញ ដើម្បីចងក្រង និងវិភាគនៅថ្នាក់ ជាតិ។

ប្រព័ន្ធទិន្នន័យឃុំ មានទិសដៅចំនួន៤ សំរាប់ :

១. **ការកសាងផែនការ:** CDB បានផ្តល់ពត៌មានយោង និងរបាយការណ៍ សំរាប់រៀបចំពត៌មានស្តីពីស្ថានភាពឃុំ ស្រុក និងខេត្ត ហើយជាពិសេស វាបានផ្តល់នូវតំរូវការនានា សំរាប់ការកសាងផែនការ។ ពត៌មានដែល CDB បានផ្តល់អោយនោះ ជារួមគឺមាន៥ចំណុច សំរាប់ការកសាងផែនការ ដូចដែលមានចែងនៅក្នុងច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ។ ចំណុចទាំង៥នោះគឺ: សង្គម សេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន និងរដ្ឋបាល/សន្តិសុខ។ ផែនការដែលបានបង្កើតឡើងនៅក្នុង CDB អាចជួយកំណត់បាននូវបញ្ហាមួយចំនួន ដោយប្រៀបធៀបជាមួយមូលដ្ឋាន និងតំបន់ផ្សេងៗទៀត ហើយវាក៏អាចជួយក្នុងការកំណត់ អាទិភាពជំនួយផងដែរ។ ឯកសារសំរាប់កសាងផែនការ ដូចជា ពត៌មានស្តីពីស្ថានភាពឃុំ គឺត្រូវបញ្ជូនត្រលប់ទៅអោយឃុំវិញ សំរាប់ការប្រើប្រាស់របស់ពួកគេ។

២. **របាយការណ៍ និងការតាមដានលើការផ្លាស់ប្តូរ:** CDB បង្កើតរបាយការណ៍ សំរាប់សូចនាករទាំងអស់ ដែលបានប្រមូលតាមរយ:សៀវភៅទិន្នន័យភូមិ និងទិន្នន័យដែលបានមកពីជំរឿនកាលពីឆ្នាំ ១៩៩៨ ព្រមទាំងទិន្នន័យដែលបានមកពីក្រសួងមួយចំនួន ដូចជា ក្រសួងអប់រំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងរៀបចំដែនដីនិងនគររូបនីយកម្ម។ CDB ជាអ្នកបង្កើតរបាយការណ៍ ដែលអាចប្រៀបធៀបការអនុវត្តន៍លើសូចនាករទាំងអស់ ពីមួយពេលទៅមួយពេល និងតាមដានការប្រែប្រួល របស់សូចនាករទាំងនោះ។ CDB ក្រៅពីមានតារាង វាក៏មានលេខកូដភូមិសាស្ត្រផងដែរ ដែលអាចអោយយើងដាក់សូចនាករនីមួយៗនៅក្នុងផែនទីថ្នាក់ភូមិ ឬថ្នាក់លើជាងនេះទៀតក៏បាន។

៣. **ការវិភាជន៍ធនធាន:** ទិសដៅមួយក្នុងចំណោមទិសដៅសំខាន់ៗរបស់ CDB គឺជួយដល់ក្រសួងផែនការ ក្នុងការអោយចំណាត់ថ្នាក់ឃុំនីមួយៗទូទាំងប្រទេស ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាមូលនិធិឃុំ ក្នុងការវិភាជន៍ប្រចាំឆ្នាំលើធនធានរបស់មូលនិធិឃុំ។ ប្រព័ន្ធទិន្នន័យឃុំ ដែលផ្អែកលើចំណាត់ថ្នាក់ភាពក្រីក្រ ជួយអោយរដ្ឋាភិបាល អាចធ្វើការវិភាជន៍ធនធានទៅអោយឃុំដែលមានភាពក្រីក្រ ហើយដែលភាពក្រីក្រនេះ គឺជាលក្ខណ:វិនិច្ឆ័យមួយនៃរូបមន្តសំរាប់វិភាជន៍ធនធាន។ ការធ្វើចំណាត់ថ្នាក់ភាពក្រីក្រ គឺផ្អែកទៅលើ " សូចនាករតំណាងភាពក្រីក្រ (proxy indicators) "

ដែលបានកំណត់ បន្ទាប់ពីការពិនិត្យ ឡើងវិញយ៉ាងទូលំទូលាយលើការសិក្សាពីភាពក្រីក្រ ដែលបានធ្វើឡើងនៅទូទាំងប្រទេស។

៤. **សំណើពិសេស:** ទិសដៅមួយផ្សេងទៀតរបស់ CDB គឺ ផ្តល់ភាពងាយស្រួល ដល់ខេត្តទាំងអស់ក្នុង ប្រទេសកម្ពុជាក្នុងការប្រើប្រាស់ប្រព័ន្ធពត៌មានភូមិ ដែលយើងអាចយកវាមកធ្វើជារបាយការណ៍ខ្លីៗ តារាងនិងគំហើញជាសង្ខេបនានា តាមសំណើរបស់មន្ទីរជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាលនិងភ្នាក់ងារអភិវឌ្ឍន៍នានា។ CDB ក៍អាចជួយកំណត់ទីកន្លែង សំរាប់ធ្វើការសិក្សាស្រាវជ្រាវស៊ីជំរៅលើសេដ្ឋកិច្ច-សង្គមផងដែរ។

ការប្រើប្រាស់ប្រព័ន្ធទិន្នន័យឃុំសំរាប់ការតាមដាន និងវាយតំលៃ គឺសំខាន់ដើម្បីគាំទ្រដល់ការរៀបចំរបាយការណ៍ និងដើម្បីពិនិត្យមើលថាតើ មានភាពប្រសើរឡើងខ្លះដែរឺទេ លើស្ថានភាពសេដ្ឋកិច្ច-សង្គម នៅថ្នាក់មូលដ្ឋាន។ CDB គឺមិនសមស្របសំរាប់ធ្វើការប៉ាន់ប្រមាណពីផលប៉ះពាល់របស់កម្មវិធីសិលានោះទេ ព្រោះថា ឯកតាសំខាន់របស់ CDB គឺជាទិន្នន័យតាមភូមិ មិនមែនតាមគ្រួសារនោះទេ។

### ៦.៣.២ ប្រព័ន្ធទិន្នន័យកិច្ចសន្យារបស់កម្មវិធីសិលា (SCD)

ប្រព័ន្ធទិន្នន័យកិច្ចសន្យារបស់កម្មវិធីសិលា (SCD) គឺជាប្រព័ន្ធមួយសំរាប់គ្រប់គ្រងកិច្ចសន្យារបស់កម្មវិធីសិលា។ កិច្ចសន្យាមាន៣ប្រភេទ គឺ :

១. **កិច្ចសន្យារវាងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងភ្នាក់ងារអនុវត្តន៍** : វាគឺជាអនុកិច្ចសន្យាដែលទាក់ទងទៅនឹងការវិនិយោគរបស់មូលនិធិវិនិយោគខេត្ត។ កិច្ចសន្យាទាំងនេះ ត្រូវបានចុះហត្ថលេខាដោយប្រធានភ្នាក់ងារអនុវត្តន៍កិច្ចសន្យា និងអភិបាលខេត្ត ក្នុងនាមជាប្រធាននៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (PRDC)។ SCD បានរក្សាទុកចំណុចមួយចំនួនរបស់អនុកិច្ចសន្យាទាំងនេះ គឺខ្ទង់ថវិកាលំអិត សកម្មភាពដែលបានគ្រោងទុក បរិមាណលទ្ធផលជារូបវន្ត ផែនការសកម្មភាពប្រចាំខែ និងការរីកចំរើនធៀបទៅនឹងលទ្ធផលគ្រោងទុក និងការចំណាយ។ លទ្ធផល

រំពឹងទុកដែលមាននៅក្នុងកិច្ចសន្យា គឺបានជ្រើសរើសចេញពីបញ្ជីលទ្ធផលឯកភាព (standard outputs) ដែលភ្ជាប់ទៅនឹង សកម្មភាព នៅក្នុងតារាងតក្កភាពរបស់កម្មវិធីសិលា។

២. **កិច្ចសន្យារវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត**: កិច្ចសន្យាទាំងនេះ គឺសង្ខេបនូវរាល់អនុកិច្ចសន្យាទាំងអស់ និងរួមជាមួយនឹងតំលៃគាំទ្រកម្មវិធី នៃផ្នែកនីមួយៗរបស់គ.ប្រ។ កិច្ចសន្យានេះ ត្រូវចុះហត្ថលេខាដោយអភិបាលខេត្ត ក្នុងនាមជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា (គ.ដ.ន.ស)។ SCD ជាអ្នករក្សាទុកពត៌មានរបស់កិច្ចសន្យានេះផងដែរ ដូចជា ផែនការសកម្មភាព ថវិកា និងការរីកចំរើនរបស់កិច្ចសន្យានីមួយៗរបស់ខេត្ត។

៣. **កិច្ចសន្យារវាង គ.ដ.ន.ស.និងក្រសួង** : កិច្ចសន្យាទាំងនេះទាក់ទងទៅនឹងសកម្មភាពនៅថ្នាក់ជាតិរបស់ក្រសួង និងភ្នាក់ងារអនុវត្តន៍ ដែលចូលរួមក្នុងកម្មវិធីសិលា។ កិច្ចសន្យាទាំងនេះ ត្រូវបានចុះហត្ថលេខាដោយជនបង្គោលកម្មវិធីសិលានៅក្នុងក្រសួង ឬភ្នាក់ងារទាំងនោះ ជាមួយអគ្គលេខាធិការ គ.ដ.ន.ស។ SCD រក្សាទុកពត៌មានមួយចំនួនរបស់កិច្ចសន្យានេះ ដូចជាផែនការសកម្មភាព ថវិកា និងការរីកចំរើន។

SCD គឺមានប្រយោជន៍យ៉ាងសំខាន់ ទាំងនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ :

## ថ្នាក់ខេត្ត

SCDជួយដល់អ្នកគ្រប់គ្រងកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ ជាមួយគណៈកម្មធិការអភិវឌ្ឍន៍ជនបទខេត្តក្នុងការ :

- រៀបចំកិច្ចន្យាកម្មវិធីសិលាប្រចាំឆ្នាំ និងធ្វើអោយការវិសោធនកម្មកិច្ចសន្យាកាន់តែងាយស្រួល
- រក្សាទុកទិន្នន័យ ដូចជា ផែនការសកម្មភាព ថវិកា ការរីកចំរើន និងលទ្ធផលរំពឹងទុក
- រៀបចំរបាយការណ៍ត្រីមាស និងរបាយការណ៍បញ្ចប់កិច្ចសន្យា ដោយប្រើ SCD

ផ្នែកគ្រប់គ្រងកិច្ចសន្យារបស់គ.ប្រ ទទួលប្រយោជន៍មួយចំនួនពី SCD គឺ :

- ពត៌មានរបស់កិច្ចសន្យាទាំងអស់ ដែលទាក់ទងទៅនឹងកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ត្រូវបានរក្សាទុកនៅក្នុង SCD ក្នុងទំរង់បែបបទតែមួយ ដែល ធ្វើអោយកាន់តែងាយស្រួល ក្នុងការរៀបចំរបាយការណ៍សង្ខេប ស្តីពីការអនុវត្តន៍កម្មវិធី និងក្នុងការ វិភាគទិន្នន័យរបស់កិច្ចសន្យាផ្សេងៗទៀត។
- SCD បានធ្វើអោយកាន់តែងាយស្រួល ក្នុងការរៀបចំកិច្ចសន្យា រវាងគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត និងក្នុងការធ្វើវិសោធនកម្មកិច្ចសន្យា។
- SCD ជួយដល់ផ្នែកគ្រប់គ្រងកិច្ចសន្យា ក្នុងការរៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំកាន់តែងាយស្រួល។
- SCD គឺជាប្រព័ន្ធទិន្នន័យមួយ ដែលផ្ទុកទៅដោយធនធានពត៌មានជាច្រើន សំរាប់ការតាមដាន និង វាយតំលៃនៅថ្នាក់ខេត្ត។

## ថ្នាក់ជាតិ

នៅពេលណាដែលក្រសួងនិងភ្នាក់ងារទាំងឡាយ ដែលអនុវត្តសកម្មភាពកម្មវិធីសិលានៅថ្នាក់ជាតិ ចាប់ផ្តើមប្រើប្រាស់ SCDនេះ ពួកគេនឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ដូចដែលមាននៅក្នុងកិច្ចសន្យា រវាងភ្នាក់ងារអនុវត្តន៍ ជាមួយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តដែរ។

ផ្នែកគ្រប់គ្រងកិច្ចសន្យារបស់ គ.ជ.ន.ស ទទួលប្រយោជន៍មួយចំនួនពី SCD គឺ :

- ពត៌មានទាំងអស់ ដែលទាក់ទងទៅនឹងកិច្ចសន្យារបស់កម្មវិធីសិលា ត្រូវបានរក្សាទុកនៅក្នុង SCD ក្នុងទំរង់បែបបទតែមួយ ដែលធ្វើអោយកាន់តែងាយស្រួល ក្នុងការរៀបចំរបាយការណ៍សង្ខេប ស្តីពីការអនុវត្តន៍កម្មវិធី និងក្នុងការវិភាគទិន្នន័យរបស់កិច្ចសន្យាផ្សេងៗទៀតរបស់ភ្នាក់ងារអនុវត្តន៍ ទាំងអស់របស់កម្មវិធីសិលា (ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត)។
- SCDជួយដល់ផ្នែកគ្រប់គ្រងកិច្ចសន្យា ក្នុងការរៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ សំរាប់កម្មវិធីសិលាទាំងមូល។

- SCD គឺជាប្រព័ន្ធទិន្នន័យមួយ ដែលផ្ទុកទៅដោយធនធានពត៌មានជាច្រើន សំរាប់ការតាមដាន និង វាយតំលៃនៅថ្នាក់ជាតិ។

## ៦.៣.៣ ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID)

ប្រព័ន្ធទិន្នន័យគ្រប់គ្រងពត៌មានរបស់គំរោង (PID) គឺជាប្រព័ន្ធទិន្នន័យមួយ ដែលជំនួសប្រព័ន្ធទិន្នន័យមូលនិធិអភិវឌ្ឍន៍មូលដ្ឋាន (LDF Database)។ PID គឺជាឧបករណ៍មួយដ៏សំខាន់ សំរាប់តាមដានគំរោងរបស់ឃុំ ដែលបានអនុវត្តជាមួយនឹងមូលនិធិឃុំ។ គ.ប្រ របស់ គ.អ.ជ.ខ ជាអ្នកថែរក្សា និងគ្រប់គ្រង PID ហើយ PIDនេះ ក៏ជាឧបករណ៍មួយ សំរាប់ធ្វើការតាមដានការអនុវត្តន៍សកម្មភាពរបស់មូលនិធិឃុំ ទូទាំងខេត្ត។

ប្រព័ន្ធទិន្នន័យនេះ នឹងបញ្ចូលនូវរាល់ពត៌មានទាំងអស់ ដែលទាក់ទងទៅនឹងគំរោងរបស់មូលនិធិឃុំ និងលទ្ធផលរំពឹងទុក ដែលអនុវត្តដោយក្រុមប្រឹក្សាឃុំ រួមទាំងពត៌មានហិរញ្ញវត្ថុប្រចាំខែ ស្តីពីការចំណាយ ដែលបានធ្វើបច្ចុប្បន្នភាពដោយរតនាគារខេត្ត នឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនេះ។ ពត៌មានដែលអាចមាននៅក្នុង PID គឺ :

- **ពត៌មានរបស់គំរោង :** ដូចជា ឈ្មោះ និងលេខកូដភូមិសាស្ត្ររបស់ឃុំ ឈ្មោះគំរោង ទិសដៅគំរោង និងចំនួនអ្នកទទួលផលពីគំរោង។ល។
- **ប្រតិបត្តិការនិងការថែរក្សា ព្រមទាំងលក្ខណៈវិនិច្ឆ័យសំរាប់អនុវត្តតាម:** ឧ.ហ អាយុកាលប៉ាន់ស្មានលើការប្រើប្រាស់លទ្ធផលរបស់គំរោង ចន្លោះពេលប៉ាន់ស្មានក្នុងការថែរក្សា តំលៃប៉ាន់ស្មានសំរាប់ថែរក្សាជាប្រចាំ និងប្រចាំឆ្នាំ និងការចំណាយសំរាប់ប្រតិបត្តិការប្រចាំឆ្នាំ។ល។
- **ពត៌មានរបស់កិច្ចសន្យា:** ដូចជា ប្រភេទកិច្ចសន្យា ឈ្មោះអ្នកម៉ៅការ តំលៃរបស់កិច្ចសន្យា ការវិភាជន៍ មូលនិធិឃុំ សំរាប់កិច្ចសន្យានោះ កាលបរិច្ឆេទចុះហត្ថលេខាលើកិច្ចសន្យា និងគំរោងកាលវិភាគនៃការ ទូទាត់។

- **លទ្ធផលរំពឹងទុក:** ដូចជា ទីតាំងរបស់លទ្ធផល (បើសិនជាអាចធ្វើទៅបាន សូមបញ្ជាក់ពី GPS ផង) ប្រភេទ និងបរិមាណនៃលទ្ធផល ព្រមទាំងតំលៃលើលទ្ធផល។ល។
- **ការរីកចំរើន:** ដូចជា កាលបរិច្ឆេទនៃរបាយការណ៍រីកចំរើន ភាគរយនៃការសំរេចបាន ការប៉ាន់ប្រមាណ លើគុណភាព និងទឹកដៃ ការប្រកាន់ខ្ជាប់ជាមួយនឹងគំរោងដែលបានលើកឡើង។ល។
- **ការទូទាត់:** ដូចជា ការបរិច្ឆេទ និងចំនួននៃការទូទាត់។
- **លទ្ធផល:** អត្រាសំរេចបាននៃលទ្ធផលរបស់គំរោង ដោយធៀបទៅនឹងទិសដៅរបស់គំរោង។

នៅថ្នាក់ខេត្ត ផ្នែករដ្ឋបាលមូលដ្ឋាន (LAU) របស់ គ.ប្រ នឹងទទួលខុសត្រូវ ក្នុងការថែរក្សាទិន្នន័យនេះ ដោយសហការជាមួយផ្នែកគាំទ្របច្ចេកទេស (TSU) ។ LAU នឹងរៀបចំរបាយការណ៍រីកចំរើនជាប្រចាំ ស្តីពី ការអនុវត្តន៍ កិច្ចសន្យារបស់ឃុំ ដោយប្រើប្រព័ន្ធទិន្នន័យនេះ ដើម្បីដាក់ជូនទៅគ.ប្រ និងអភិបាលខេត្ត។ តែទោះជាយ៉ាង ណាក៏ដោយ ពត៌មានភាគច្រើន ក្នុងប្រព័ន្ធទិន្នន័យនេះ នឹងត្រូវបានប្រមូលដោយ TSU ហើយ LAU អាចយល់ ស្របអោយ TSU ជាអ្នកទទួលខុសត្រូវលើការបញ្ចូលទិន្នន័យ នៅពេលសមស្រប។ នៅថ្នាក់ជាតិ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ (DoLA/MOI) ជាអ្នកថែរក្សា PID នេះ ។ DoLA នឹងផ្តល់ឯកសារចំលងថ្មីៗ ស្តីពីប្រព័ន្ធទិន្នន័យនេះ ទៅអោយ STFS និងក្រសួងអភិវឌ្ឍន៍ជនបទ។

# សៀវភៅណែនាំ ស្តីពី
# ការតាមដាន និងវាយតំលៃរបស់
# កម្មវិធីសិលា

# ផ្នែកទី៧

# របាយការណ៍ និងការប្រើប្រាស់ពត៌មាន



ការបង្កើតគំនិត ដោយប្រើវិធីសាស្ត្រពិភាក្សារួមគ្នា គឺជាវិធីសាស្ត្រមួយដ៏ល្អបំផុត ក្នុងការកំណត់ជំរើស និងលក្ខណៈវិនិច្ឆ័យជ្រើសរើស។

លទ្ធផលរបស់ជំហានទី៣ និងជំហានទី៤ អាចបង្កើតបានជាអនុសាសន៍ សំរាប់គំរោង ដែលគួរតែសរសេរនៅក្នុងជំពូកចុងក្រោយ នៃរបាយការណ៍វាយតំលៃ។ ការវាយតំលៃត្រូវបានបញ្ចប់ ក្រោយពីបានអនុវត្តបញ្ចប់ជំហានទី៤ នៃដំណើរការនេះ។

## ៥. អនុវត្តដំណោះស្រាយ និង វាយតំលៃលើលទ្ធផល

ការពិនិត្យមើលថាតើអនុសាសន៍ដែលបានលើកឡើង មានប្រសិទ្ធភាព ឬមិនមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហា ត្រូវបានធ្វើឡើងតាមរយៈដំណើរការតាមដានជម្ងតាមួយ (ហើយវាមិនមែនជាផ្នែកមួយនៃការវាយតំលៃលើគំរោងទេ)។

## ៧.១. សេចក្ដីផ្ដើម

មានអ្នកអាន/ទស្សនិកជនជាច្រើន ដែលចង់អានពត៌មានរបស់ការតាមដាននិងវាយតំលៃ។ ឧទាហរណ៍ៈ ចាំបាច់យើង ត្រូវរាយការណ៍ពីការរីកចំរើនរបស់គំរោង ឬកម្មវិធី ដល់អ្នកគ្រប់គ្រង ភ្នាក់ងារអនុវត្តន៍ គណៈកម្មាធិការដឹកនាំ ភ្នាក់ងារផ្ដល់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងៗ។ ទាំងភ្នាក់ងារផ្ដល់ជំនួយ និងអ្នកគ្រប់គ្រង ត្រូវការពត៌មានជាចាំបាច់ ស្ដីពីផលប៉ះពាល់ តែដោយឡែក ភាគីអ្នកអនុវត្តន៍ គឺចង់ដឹង ពីបញ្ហានានាដែលបានកើតឡើង ដើម្បីស្វែងរកដំណោះស្រាយ។

នៅពេលដែលបង្ហាញ ឬធ្វើទំនាក់ទំនងស្ដីពីពត៌មានតាមដាននិងវាយតំលៃ សូមធ្វើការចងចាំនូវចំណុចមួយចំនួយ ដូចខាងក្រោម :-

- **ត្រូវដឹងថា អ្នកណាជាអ្នកអាន/ទស្សនិកជន** : តើអ្នកណាខ្លះ ត្រូវការពត៌មាន? ហើយពត៌មានអ្វីខ្លះដែលគេត្រូវការ? តើចាំបាច់ត្រូវមានការទទួលខុសត្រូវចំពោះសកម្មភាព និងសេចក្ដីសំរេចចិត្ត ឬការតស៊ូមតិណាមួយដែរឺទេ? តើអ្នកចង់បានអ្វីខ្លះពីអ្នកអាន/ទស្សនិកជននោះ? តើត្រូវមានមាតិកាអត្ថបទនិងទំរង់បែបបទណាមួយដែលសមស្របបំផុត សំរាប់សរសេររបាយការណ៍តាមដាននិងវាយតំលៃនេះ?
- **កសាងយុទ្ធសាស្ត្រទំនាក់ទំនងក្នុងប្រព័ន្ធតាមដាននិងវាយតំលៃ** : ត្រូវរៀបចំចំណុចនេះអោយច្បាស់តាំងពីពេលចាប់ផ្ដើម ដូចជាត្រូវរៀបចំប្រព័ន្ធលំហូរពត៌មាន និងកំណត់អ្នកដែលទទួលខុសត្រូវលើការទំនាក់ទំនង ព្រមទាំងត្រូវកំណត់ថា ពត៌មានអ្វីខ្លះដែលត្រូវទំនាក់ទំនង នៅពេលណា និងញឹកញាប់បែបណា។
- **វិនិយោគលើយុទ្ធសាស្ត្រទំនាក់ទំនង** : អ្នកដែលមានសមត្ថភាព គឺជាអ្នកដែលអាចធ្វើអោយការបង្ហាញនិងរបាយការណ៍ មានលក្ខណៈជាអាជីព តាមរូបភាពខុសៗពីគ្នា។

## ៧.២. គោលការណ៍ណែនាំទូទៅសំរាប់សរសេររបាយការណ៍

ការរាយការណ៍ពត៌មានជាទៀងទាត់ គឺវាមានសារៈសំខាន់ណាស់ ដែលអាចអោយយើងរក្សាទុកនូវរាល់ឯកសារទាំងឡាយ ស្តីពីលទ្ធផលរបស់គំរោងឬរបស់កម្មវិធី។ ការសរសេររបាយការណ៍ពត៌មានដែលប្រកបដោយខ្លឹមសារ គឺវាចាំបាច់ ត្រូវអោយមានទំនាក់ទំនងជាមួយលទ្ធផលនៃទិន្នន័យដែលបានប្រមូល និងពត៌មានដែលបានពីការវិភាគ។ របាយការណ៍ គឺតែច្បាស់ ហើយត្រូវបកស្រាយខ្លីៗ តែចំណុចចង់បាន នូវអ្វីដែលបានធ្វើ វិធីសាស្ត្រដែលបានប្រើ សន្និដ្ឋាន ព្រមទាំងអនុសាសន៍ដែលបានលើកឡើង។

គោលការណ៍ទូទៅសំរាប់សរសេររបាយការណ៍តាមដាន ឬរបាយការណ៍វាយតំលៃ គឺដូចគ្នា តែអ្វីដែលខុសគ្នានោះ គឺរបៀបក្នុងការបង្ហាញពត៌មាន។ ពត៌មានតាមដាន គឺតែងតែត្រូវបានដាក់នៅក្នុងរបាយការណ៍ទៀងទាត់ (ដូចជា: របាយការណ៍រីកចំរើនប្រចាំខែ ឬប្រចាំត្រីមាស) តែរបាយការណ៍វាយតំលៃ ភាគច្រើនគឺជារបាយការណ៍ ដែលត្រូវរៀបចំដាច់ដោយឡែកពីរបាយការណ៍ទៀងទាត់។

ខាងក្រោមនេះ គឺជាចំណុចទូទៅមួយចំនួន ក្នុងការសរសេររបាយការណ៍តាមដាន និងវាយតំលៃ :

- **ខ្លី :** របាយការណ៍ដែលខ្លី ទទួលបានការយកចិត្តទុកដាក់អានជាងរបាយការណ៍វែង។ អ្នកអានមិនមានពេលវេលា សំរាប់អានរបាយការណ៍ណា ដែលវែងនោះទេ។
- **ច្បាស់ :** របាយការណ៍ ត្រូវតែងាយអាន និងងាយយល់។ សូមជៀសវាងការប្រើពាក្យបច្ចេកទេស និងភាសាមិនត្រឹមត្រូវ (jargon)។ ត្រូវប្រើពាក្យដែលសាមញ្ញ ហើយច្បាស់ៗ ដែលអ្នកអានគ្រប់រូបអាចអាន និងយល់បាន។
- **ប្រើប្រយោគខ្លីៗ:** ព្យាយាមប្រើពាក្យមិនអោយលើសពី១៦ពាក្យក្នុងមួយប្រយោគ ហើយប្រយោគនោះទៀតសោត ត្រូវតែជាប្រយោគវិជ្ជមាន។ សូមកុំបញ្ចូលខ្លឹមសារផ្សេងៗគ្នាក្នុងប្រយោគតែមួយ។
- **ត្រូវចោលបន្ទាត់ពីកថាខ័ណ្ឌមួយ ទៅកថាខ័ណ្ឌមួយ និងការរៀបចំ :** ដើម្បីអោយការរៀបចំមួយកាន់តែច្បាស់ ត្រូវបំបែកអត្ថបទ អោយទៅជាកថាខ័ណ្ឌខ្លីៗ ដើម្បីធ្វើអោយអ្នកអានងាយយល់។ ត្រូវលើកគំនិតសំខាន់ ក្នុងកថាខ័ណ្ឌនីមួយៗ។

- **ត្រូវប្រើក្បាលរឿងតូចៗ** (Subheading): ត្រូវប្រើក្បាលសេចរឿងតូចៗ ដើម្បីធ្វើអោយអ្នកអានអាចចងចាំបាននូវអ្វីដែលគេអាន ហើយក៏ដើម្បីធ្វើអោយរបាយការណ៍កាន់តែទទួលបានការចាប់អារម្មណ៍ពីអ្នកអានផងដែរ។
- **សង្កត់ន័យសំខាន់ៗ:**ដើម្បីសង្កត់ន័យឬខ្លឹមសារណាមួយក្នុងអត្ថបទ យើងត្រូវប្រើអក្សរធំ គូសបន្ទាត់ពីក្រោម អក្សរទ្រេត ឬត្រូវដាក់អោយខ្មៅលើអត្ថបទណាមួយដែលយើងយល់ថាសំខាន់ ប៉ុន្តែមិនត្រូវធ្វើបែបនេះអោយហួសហេតុពេល ដែលត្រូវរចនាម៉ូដផ្សេងៗគ្នា ក្នុងទំព័រមួយនោះ។ ឧ.ហ សៀវភៅណែនាំនេះ បានប្រើមិនលើសពី Fonts អក្សរចំនួន៣ និង Fonts ទំហំចំនួន២ឡើយ។
- **ត្រូវប្រើជាបញ្ជី និងតារាង :** យើងអាចបង្ហាញពត៌មានបានយ៉ាងច្បាស់ល្អ ដោយដាក់វាក្នុងតារាង ឬរៀបចំជាចំណុច (bullets)។ ធ្វើបែបនេះ គឺមិនសូវអស់ចន្លោះច្រើន ហើយងាយស្រួលសំរាប់អ្នកអានផងដែរ។
- **ត្រូវបង្ហាញការរកឃើញទាំងឡាយ ក្នុងលក្ខណៈដែលងាយយល់:** ភាគច្រើន តែងតែមានការលំបាក និងស្មុគស្មាញ ក្នុងការបកស្រាយពត៌មាននិងការរកឃើញជាពាក្យសំដី។ ក្រៅពីដាក់ពត៌មានជាចំណុចៗ និងដាក់ក្នុងតារាងនោះ ក្រាភិកនិងផែនទី ក៏អាចធ្វើអោយពត៌មានសំខាន់ៗ កាន់តែងាយស្រួលយល់បន្ថែមទៀតផងដែរ។
- **ត្រូវពិនិត្យឡើងផ្ទាត់របាយការណ៍ដោយប្រុងប្រយ័ត្ន:** បើសិនជាអាចធ្វើទៅបាន ត្រូវពិនិត្យលើអក្ខរាវិរុទ្ធក្នុងឯកសារទាំងមូល។ ក្រោយពេលដែលរបាយការណ៍ត្រូវបានសរសេរចប់ ត្រូវទុកពេលមួយថ្ងៃ ដើម្បីពិនិត្យសារឡើងវិញម្តងទៀត មុននឹងសំរេចបញ្ចប់របាយការណ៍។ យកល្អ គួរតែសូមអោយអ្នករួមការងារ ឬអ្នកគ្រប់គ្រង អានសេចក្តីព្រាងរបាយការណ៍នោះសិន ដើម្បីទទួលបានយោបល់កែលំអ។
- **ចែកចាយទាន់ពេលវេលា:** ធានាថា របាយការណ៍ ត្រូវបានចែកចាយទាន់ពេលវេលា ជាពិសេសនៅពេលដែលរបាយការណ៍នោះ ត្រូវប្រើសំរាប់គោលបំណងធ្វើសេចក្តីសំរេចចិត្ត។

## ៧.៣. ការសរសេររបាយការណ៍ក្នុងកម្មវិធីសិលា

ក្នុងកម្មវិធីសិលា របាយការណ៍ជាច្រើន ត្រូវបានរៀបចំដោយខេត្ត និងក្រសួង/ភ្នាក់ងារនានានៅថ្នាក់ជាតិ (ទាំងរបាយការណ៍ទៀងទាត់ និងរបាយការណ៍រីកចំរើន)។ ការសរសេររបាយការណ៍ គឺត្រូវរួមបញ្ចូល

ការងារជាច្រើន ហើយវាជាការប្រថុយប្រថាន ដែលត្រូវសរសេររបាយការណ៍ តាមទំលាប់ ឬ សរសេរដើម្បីសរសេរ ដោយមិនមានគោលបំណងច្បាស់លាស់។

ការរៀបចំរបាយការណ៍ គឺត្រូវទាមទារអោយមានពេលវេលា និងថាមពលគ្រប់គ្រាន់ ហើយដែលធ្វើអោយពេលវេលា និងថាមពល ត្រូវបានដកចេញពីការអនុវត្តន៍សកម្មភាពសំខាន់ៗរបស់កម្មវិធីសិលា។ ដូចនេះការសរសេររបាយការណ៍ ជាសំខាន់ត្រូវ :

- **កំណត់ពេលវេលាដែលត្រូវការសំរាប់រៀបចំរបាយការណ៍ និងគ្រប់គ្រងនិងវិភាគរបាយការណ៍ :** របាយការណ៍ គួរតែត្រូវបានសរសេរអោយចំៗចំណុចដែលចង់បាន ដោយមិនចាំបាច់មានកថាខ័ណ្ឌពណ៌នាវែងៗ តែចាំបាច់ត្រូវផ្តល់ជាអប្បបរិមានូវពត៌មាន ដែលសំខាន់ៗ សំរាប់ចែករំលែកជាមួយអ្នកផ្សេងៗទៀត។
- **ធ្វើអោយរបាយកាយណ៍នេះ មានលក្ខណៈស្តង់ដា និងស្វ័យប្រវត្តិ តាមដែលអាចធ្វើទៅបាន:** ត្រូវមានផ្នែកមួយជាលក្ខណៈស្តង់ដា ដែលពត៌មានបរិមាណ ត្រូវបានបង្កើតឡើង ដោយស្វ័យប្រវត្តិតាមរយៈកម្មវិធីប្រព័ន្ធទិន្នន័យ។ ការប្រើគំរូបែបបទជាស្តង់ដា សំរាប់ផ្នែកបរិយាយ គឺអាចជួយការរៀបចំផ្នែកនេះ កាន់តែបានឆាប់រហ័ស។
- **ជៀសវាងការសរសេររបាយការណ៍ស្ទួនគ្នា :** គ.ប្រ នៃគ.អ.ជ.ខ និង ការិយាល័យគាំទ្រថ្នាក់ខេត្តរបស់កម្មវិធីសិលា ត្រូវសហការគ្នា។ ចំណុចណាមួយ ដែលត្រូវបានរាយការណ៍ដោយ គ.ប្រ ហើយនោះ ការិយាល័យគាំទ្រកម្មវិធីសិលា មិនចាំបាច់សរសេរម្តងទៀតនោះទេ ដូចគ្នានេះដែរ បើសិនជា ការិយាល័យគាំទ្រកម្មវិធីសិលាថ្នាក់ខេត្ត បានរាយការណ៍ពីចំណុចណាមួយហើយនោះ គ.ប្រ មិនចាំបាច់រាយការណ៍ទៀតទេ (លើកលែងតែ ការបកប្រែពីខ្មែរ ទៅអង់គ្លេស)។

តំរូវការក្នុងការសរសេររបាយការណ៍ និងការរៀបចំឯកសារនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវបានពិភាក្សាក្នុងផ្នែកបន្ទាប់ដូចតទៅនេះ

## ៧.៣.១. ភ្នាក់ងារអនុវត្តន៍នៅថ្នាក់ខេត្ត

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អនុកិច្ចសន្យាប្រចាំឆ្នាំរបស់គ.អ.ជ.ខ ជាមួយ ភ្នាក់ងារអនុវត្តន៍ | 📄[៦] ——— | ——— | ——— | ——— | ——— | ——— | ——— | ——— | ——— | ——— | ——— | |
| របាយការណ៍ប្រចាំខែ | 📄 | 📄 | | 📄 | 📄 | | 📄 | 📄 | | 📄 | 📄 | |
| របាយការណ៍ប្រចាំត្រីមាស | ——— | ——— | →📄 | ——— | ——— | →📄 | ——— | ——— | →📄 | | | |
| របាយការណ៍បញ្ចប់កិច្ចសន្យា (សំរាប់អនុកិច្ចសន្យា) | ——— | →📄[៧] | | | | | | | | | | |

នៅរៀងរាល់ដើមឆ្នាំ ភ្នាក់ងារអនុវត្តន៍នីមួយៗ ដែលមានកិច្ចសន្យាកម្មវិធីសិលា ជាមួយ គ.អ.ជ.ខ ត្រូវរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ។ កិច្ចសន្យានេះ ជាកិច្ចសន្យាដែលធ្វើឡើងរវាងភ្នាក់ងារអនុវត្តន៍ខ្លួនឯង ជាមួយនឹងគ.អ.ជ.ខ ហើយដែលត្រូវបានរៀបចំឡើងដោយប្រើប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យារបស់កម្មវិធីសិលា (SCD) ។ គំរូបែបបទជាឯកភាពរបស់កិច្ចសន្យានេះ ក៏ដូចជាកិច្ចសន្យាផ្សេងៗទៀតដែលបានលើកឡើងនៅក្នុងផ្នែកនេះ គឺមាននៅក្នុងសៀវភៅណែនាំ SCD ។

រៀងរាល់ខែ ភ្នាក់ងារអនុវត្តន៍នីមួយៗ ត្រូវផ្តល់របាយការណ៍ប្រចាំខែទៅអោយ ផ្នែកគ្រប់គ្រងកិច្ចសន្យារបស់ គ.ប្រ នៃ គ.អ.ជ.ខ។ ផ្នែកខ្លះនៃរបាយការណ៍ប្រចាំខែនេះ យើងអាចបង្កើតចេញពី SCD ។ នៅពេលចុងបញ្ចប់ត្រីមាស របាយការណ៍ប្រចាំខែ ត្រូវជំនួសដោយរបាយការណ៍ប្រចាំត្រីមាសវិញ (លើកលែងតែត្រីមាសទី៤ ព្រោះថា របាយការណ៍បញ្ចប់កិច្ចសន្យា នឹងផ្តល់នូវរាល់ពត៌មានទាំងអស់ដែលមាននៅក្នុងរបាយការណ៍ត្រីមាសទី៤នេះ)។

---

៦ បន្ទាត់ផ្តេក បង្ហាញពី កំឡុងពេលរបស់គំរោង កិច្ចសន្យា ឬរបាយការណ៍ ។ បន្ទាត់នេះ មិនបានបញ្ជាក់ពីពេលវេលាសំរាប់ព្រាងគំរោង ឬកិច្ចសន្យា ឬសំរាប់រៀបចំរបាយការណ៍ឡើយ ។

៧ ជំរើសសំរាប់ខែកុម្ភៈ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ដើម្បីបង្ហាញថា របាយការណ៍បញ្ចប់កិច្ចសន្យា មិនចាំបាច់ជាន់នឹងរបាយការណ៍ចុងឆ្នាំនោះទេ ។

ជាគោលការណ៍ កិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ទាំងអស់ ត្រូវបញ្ចប់នៅចុងឆ្នាំ។ ប៉ុន្តែ ក្នុងករណីខ្លះ អាចមានសកម្មភាពមួយចំនួន មិនត្រូវបានអនុវត្តបញ្ចប់ពេញលេញនៅត្រឹមចុងខែធ្នូ ដែលចាំបាច់តំរូវអោយមានពេលវេលាបន្ថែមទៀត ដើម្បីអនុវត្តបញ្ចប់សកម្មភាពដែលនៅសេសសល់ទាំងនោះ។ ការពន្យាពេលលើការអនុវត្តន៍មួយ អាចធ្វើទៅបាន ក្រោយពីការពិគ្រោះយោបល់ជាមួយផ្នែក CAU និងក្រោយពីការវាយតំលៃលើហេតុផលនៃសំណើសុំពន្យាពេលការអនុវត្តន៍។ នៅពេលបញ្ចប់កិច្ចសន្យា ត្រូវរៀបចំ "របាយការណ៍បញ្ចប់កិច្ចសន្យា"។ ផ្នែកខ្លះនៃរបាយការណ៍នេះ ក៏អាចបង្កើតចេញពី SCD ផងដែរ។

### ៧.៣.២. គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា ថ្នាក់ខេត្ត | 📄— | — | — | — | — | — | — | — | — | — | — | — |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ (ផ្ញើទៅ STFS) | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 |
| ធ្វើបច្ចុប្បន្នភាព SCD ប្រចាំត្រីមាស | | | 📄 | | | 📄 | | | 📄 | | | 📄 |
| របាយការណ៍ប្រចាំត្រីមាស | — | — | —📄 | — | — | —📄 | — | — | —📄 | | | |
| របាយការណ៍ប្រចាំឆ្នាំ | — | — | — | — | — | — | — | — | — | — | — | —📄 |
| របាយការណ៍បញ្ចប់កិច្ចសន្យា GOV | — | —📄 | | | | | | | | | | |

គ្រប់កិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ទាំងអស់ រួមនិងសកម្មភាពគាំទ្រកម្មវិធីសិលា បង្កើតបានជាកម្មវិធីសិលាថ្នាក់ខេត្ត ប្រចាំឆ្នាំ។ នៅដើមឆ្នាំ ខេត្តនីមួយៗ ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងកិច្ចសន្យា GOV របស់ខ្លួន។ កិច្ចសន្យា GOV នេះ គឺជាកិច្ចសន្យាមួយ ដែលបានមកពីការបូកសរុបនូវរាល់អនុកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ថ្នាក់ខេត្តទាំងអស់ ហើយដែលធ្វើឡើងរវាង គ.អ.ជ.ខ និង គ.ជ.ន.ស។

រៀងរាល់ខែ ផ្នែកហិរញ្ញវត្ថុរបស់គ.ប្រ ត្រូវផ្ញើពត៌មានស្តីពីការចំណាយប្រចាំខែរបស់ខ្លួន ទៅ STFS ដែលជាកន្លែងប្រមូលផ្តុំនូវរាល់ពត៌មានសំរាប់កម្មវិធីសិលាទាំងមូល។

ពត៌មានស្តីពីកិច្ចសន្យា ត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្ត ហើយផ្នែក CAU ត្រូវផ្ញើ SCD ដែលបានធ្វើបច្ចុប្បន្នភាពហើយទៅ ភ្នំពេញ រៀងរាល់ចុងត្រីមាសនីមួយៗ។ គ.អ.ជ.ខ ក៏ត្រូវរៀបចំរបាយការណ៍ប្រចាំត្រីមាសផងដែរ លើកលែងតែ ត្រីមាសទី៤ ព្រោះថា ក្នុងត្រីមាសទី៤នេះ គឺត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលវាយតំលៃលើការរីកចំរើនទូទៅ ក្នុងរយៈពេលមួយឆ្នាំ។ របាយការណ៍ចុងក្រោយមួយទៀត ដែលត្រូវរៀបចំ គឺរបាយការណ៍បញ្ចប់កិច្ចសន្យា របស់កិច្ចសន្យា GOV។

ផ្នែកនីមួយៗ របស់គ.ប្រ គួរតែរៀបចំផែនការសកម្មភាពនិងថវិកាផ្ទៃក្នុងរបស់ខ្លួន នៅរៀងរាល់ដើមឆ្នាំ ដើម្បីធានាថា រាល់សកម្មភាពសំខាន់ៗ ត្រូវបានអនុវត្តយ៉ាងសមស្រប និងមានធនធានគ្រប់គ្រាន់។ បន្ថែមលើនេះទៅទៀត គួរតែរៀបចំ ឬមិនចាំបាច់រៀបចំអោយមានរបាយការណ៍ផ្ទៃក្នុង ជាទៀងទាត់ ដែលផ្នែកនីមួយៗរបស់ គ.ប្រ ត្រូវផ្ញើទៅ គ.ប្រ គឺជាការសំរេចចិត្តរបស់ គ.ប្រ ខ្លួនឯង។

### ៧.៣.៣. ក្រសួង/ភ្នាក់ងារនៅថ្នាក់ជាតិ

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រសួង/ភ្នាក់ងារអនុវត្តកម្មវិធីសិលា | 📄 —— | —— | —— | —— | —— | —— | —— | —— | —— | —— | —— | —— |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ (ផ្ញើទៅ STFS) | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 |
| របាយការណ៍ប្រចាំត្រីមាស | —— | —— | —— 📄 | —— | —— | —— 📄 | —— | —— | —— 📄 | | | |
| របាយការណ៍បញ្ចប់កិច្ចសន្យា | —— | —— 📄 —— | —— | —— | —— | —— | —— | —— | —— | —— | —— | —— |

ក្រសួង ឬភ្នាក់ងារអនុវត្តន៍នៅថ្នាក់ជាតិ ដែលអនុវត្តសកម្មភាពកម្មវិធីសិលា ត្រូវរៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនេះ គឺជាកិច្ចសន្យាដែលបានធ្វើឡើងរវាងក្រសួង ឬភ្នាក់ងារនៅថ្នាក់ជាតិ ជាមួយ គ.ជ.ន.ស។

បើសិនជាក្រសួង ឬភ្នាក់ងារអនុវត្តន៍ ជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់កម្មវិធីសិលាដោយខ្លួនឯង ដោយមិនចាំបាច់អោយ STFS ជាអ្នកចាត់ចែងជំនួសនោះ ពួកគេត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ដើម្បីផ្ញើជូនទៅ STFS ។

ក្រសួង និងភ្នាក់ងារអនុវត្តន៍ថ្នាក់ជាតិ ត្រូវរៀបចំរបាយការណ៍ប្រចាំត្រីមាស សំរាប់ត្រីមាសនីមួយៗ និងរបាយការណ៍បញ្ចប់កិច្ចសន្យា នៅនៅរៀងរាល់ចុងឆ្នាំ។

### ៧.៣.៤. គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា STF

| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិលា | 📄 | | | | | | | | | | | |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ (ផ្ញើទៅ STF) | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 | 📄 |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស (ផ្ញើទៅម្ចាស់ជំនួយរបស់កម្មវិធីសិលា) | | | 📄 | | | 📄 | | | 📄 | | | 📄 |
| របាយការណ៍ប្រចាំត្រីមាស | | | 📄 | | | 📄 | | | 📄 | | | |
| របាយការណ៍ប្រចាំឆមាស (ផ្ញើទៅក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី) | | | | | | 📄 | | | | | | 📄 |
| របាយការណ៍ប្រចាំឆ្នាំ | | | | | | | | | | | | 📄 |

តាមរយៈលេខាធិការដ្ឋានរបស់ខ្លួន គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សំរាប់កម្មវិធីទាំងមូល។ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនេះ នឹងបកស្រាយពីអ្វីដែលកម្មវិធីសិលា នឹងធ្វើនៅមួយឆ្នាំខាងមុខ ដើម្បីឈានទៅសំរេចបានទិសដៅរបស់ខ្លួន និងពីរបៀបដែលថ្នាក់ខេត្ត និងអ្នកអនុវត្តន៍កម្មវិធីសិលានៅថ្នាក់ជាតិ អាចចូលរួមក្នុងការអនុវត្តន៍សកម្មភាពរបស់កម្មវិធីនេះ។

STFS ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ STF ជារៀងរាល់ខែ និងត្រូវរៀបចំរបាយការណ៍រីកចំរើន ផ្នែកហិរញ្ញវត្ថុ រៀងរាល់ត្រីមាស ដើម្បីដាក់ជូនទៅម្ចាស់ជំនួយនានា របស់កម្មវិធីសិលា។

ការពិពណ៌នាពីការរីកចំរើន លើការអនុវត្តន៍កម្មវិធីសិលា គឺត្រូវធ្វើឡើងនៅក្នុងរបាយការណ៍រីកចំរើន ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ដែលបកស្រាយពីទិដ្ឋភាពទូទៅលើការអនុវត្តន៍កម្មវិធី។ ទន្ទឹមនឹងនេះ ក្នុងឯកសារកម្មវិធីសិលា ឆ្នាំ ២០០១-២០០៥ ក៏បានបញ្ជាក់ផងដែរថា តាមរយៈ STFS គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ត្រូវរៀបចំរបាយការណ៍ប្រចាំឆមាស ដើម្បីដាក់ជូនទៅក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រីផងដែរ។

## ៧.៣.៥. ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍លើសូចនាកររបស់កម្មវិធីសិលា

សូចនាករសំខាន់ៗសំរាប់តាមដានការអនុវត្តន៍កម្មវិធីសិលា នៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត គឺមាននៅក្នុងផ្នែកទី៣ និងផ្នែកទី៤ នៃឯកសារនេះ។ ការសរសេររបាយការណ៍លើការប្រែប្រួលរបស់សូចនាករទាំងនេះ គឺត្រូវធ្វើឡើងជាទៀងទាត់ តាមពេលកំណត់ជាក់លាក់មួយ ប៉ុន្តែមិនមានន័យថា ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍ពីការប្រែប្រួលរបស់សូចនាករទាំងអស់ ត្រូវធ្វើឡើងដូចគ្នានោះទេ។ តារាងលើទំព័របន្ទាប់នេះ នឹងបង្ហាញពីសូចនាករមួយចំនួនដែលត្រូវសរសេររៀងរាល់ត្រីមាស និងសូចនាករមួយចំនួនទៀតដែលត្រូវសរសេរប្រចាំឆ្នាំ។ បន្ថែមលើនេះ វាក៏បង្ហាញពីភាពញឹកញាប់សំរាប់ប្រមូល ឬ ធ្វើបច្ចុប្បន្នភាពទិន្នន័យនៅថ្នាក់ជាតិ និង/ឬ នៅថ្នាក់ខេត្តផងដែរ។

| សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| **គោលដៅ: រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ តាមរយៈអភិបាលកិច្ចល្អ** | | | | | |
| ១. ការកាត់បន្ថយលើកំរិតភាពក្រីក្រនៅថ្នាក់ជាតិ | | | កម្មវិធី មិនមានគោលបំណងជាពិសេសក្នុងការតាមដាន និងវាយតំលៃលើការចូលរួមរបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រទេ។ ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា នឹងត្រូវបានតាមដាននិង វាយតំលៃដោយភាគីផ្សេងៗ។ | | |
| ២.ការកាត់បន្ថយភាពខុសគ្នានៃកំរិតក្រីក្ររវាងបុរស និងស្ត្រី | | | | | |
| **ទិសដៅ: រៀបចំប្រព័ន្ធ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការនានា ដើម្បីគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព** | | | | | |
| ១.បទពិសោធន៍ខាងវិមជ្ឈការនិងវិសហមជ្ឈការរបស់កម្មវិធីសិលា ត្រូវបានលើកឡើងនៅក្នុងលិខិតគតិយុត្តិផ្សេងៗ | | | ច្បាប់ ប្រកាស ក្រឹត្យ អនុក្រឹត្យ គោលការណ៍ណែនាំ។ល។ | ជាបន្ត | ប្រចាំត្រីមាស |
| ២.ប្រពន្ធ័កសាងផែនការរៀបចំថវិកា លទ្ធកម្មនិងការអនុវត្តន៍គំរោងនានា ដែលទទួលការគាំទ្រពីមូលនិធិឃុំ និងរបាយការណ៍តាមបែបវិមជ្ឈការ ត្រូវបានអនុវត្ត នៅគ្រប់ឃុំ។ | | | តារាងទិន្នន័យតាមដានសង្ខេប ស្តីពីការអនុវត្តន៍របស់ឃុំ នៅថ្នាក់ជាតិ | បច្ចុប្បន្នភាពប្រចាំខែ | ប្រចាំត្រីមាស |
| | | | តារាងតាមដានការអនុវត្តន៍របស់ ឃុំ នៅក្នុងខេត្តនីមួយៗ | | |
| ៣.ប្រពន្ធ័ និងរចនាសម្ព័ន្ធគាំទ្រដល់ការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម និងការអនុវត្តន៍គំរោងមូលនិធិឃុំ ព្រមទាំងរបាយការណ៍តាមបែបវិមជ្ឈការ គឺត្រូវបានអនុវត្តនៅគ្រប់ខេត្ត។ | | | របាយការណ៍របស់ក្រសួងស្តីពីការអនុវត្តន៍វិមជ្ឈការ | ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ | ប្រចាំត្រីមាស |
| | | | របាយការណ៍ពីភ្នាក់ងារថ្នាក់ខេត្ត | | |
| ៤. ការឆ្លើយតបតាមតំរូវការនៃអាទិភាពដែលបាន កំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ បានកើនឡើងប្រចាំឆ្នាំ តាមរយៈកិច្ចសន្យាបណ្តោះអាសន្ន។ | | | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | ម្តងក្នុង១ឆ្នាំ គឺនៅ ចន្លោះខែវិច្ឆិកា_ខែធ្នូ | ប្រចាំឆ្នាំ |
| | | | លទ្ធផលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក | | |

| សូចនាករសំខាន់ៗ | ថ្នាក់ | | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| | ជាតិ | ខេត្ត | | | |
| ៥.ចំនួនកិច្ចសន្យាបណ្តោះអាសន្ន ដែលបានចុះហត្ថលេខា ដោយមន្ទីរ និង NGO ជាមួយឃុំនៅឯសិក្ខាសាលាលសមាហរណកម្មថ្នាក់ស្រុក មានការកើនឡើង។ | | | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | ម្តងក្នុង១ឆ្នាំ គឺនៅចន្លោះខែវិច្ឆិកា-ខែធ្នូ | ប្រចាំឆ្នាំ |
| | | | លទ្ធផលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក | | |
| ៦. ចំនួនស្ត្រីដែលមានតំណែងជាអ្នកដឹកនាំ នៅថ្នាក់ ឃុំនិងនៅថ្នាក់ខេត្ត មានការកើនឡើង | | | ចំនួនសរុបនៃស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ និងដែលជាសមាជិក PBC នៅថ្នាក់ជាតិ។ | ប្រចាំឆ្នាំ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | ប្រចាំឆ្នាំ |
| | | | ចំនួនស្ត្រីសង្ខេបសរុប ដែលមាននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និងថ្នាក់ខេត្ត | ប្រចាំឆ្នាំ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ PRDC | |
| | | | ចំនួនស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ និងដែលជាសមាជិក PBC | ប្រចាំឆ្នាំ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ឃុំ | |
| | | | ចំនួនស្ត្រីដែលមាននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត | ប្រចាំឆ្នាំ ក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ PRDC | |
| ៧. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយមូលនិធិឃុំ | | | ការសំរេចចិត្តរបស់ MEF លើការចូលរួមរបស់រដ្ឋាភិបាលក្នុងមូលនិធិឃុំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ៨. ចំណូលបុគ្គលជាមធ្យម ត្រូវបានផ្ទេរតាមរយៈមូលនិធិឃុំ | | | ការវិភាជន៍របស់មូលនិធិឃុំ និងតួលេខប្រជាពលរដ្ឋរបស់ឃុំ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ៩. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយខេត្តសំរាប់ជាទុន ដើម្បីយកទៅអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ | | | ការសំរេចចិត្តរបស់ MEF លើការចូលរួមរបស់រដ្ឋាភិបាលក្នុងការគាំទ្រ ដល់ការវិនិយោគខេត្តតាមរយៈវិសហមជ្ឈការ | បើសិនជាអនុម័ត ត្រូវធ្វើជាប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ១០.ចំណូលបុគ្គលជាមធ្យមត្រូវបានផ្ទេរតាមរយៈ PIF ដោយខេត្តនីមួយៗ | | | ការវិភាជន៍របស់ PIF និងតួលេខសរុបនៃប្រជាពលរដ្ឋក្នុងខេត្ត | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |

| សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| ១១.ចំនួនធនធានដែលបានគ្រប់គ្រងប្រចាំឆ្នាំដោយរាជធានីខេត្តដែលប្រើប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ ដែលកម្មវិធីសិលាបានបង្កើតឡើង | | | របាយការណ៍ពី MEF និងម្ចាស់ជំនួយ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | | | របាយការណ៍ពីរាជធានីខេត្ត | | |
| ១២. ចំណូលផ្ទាល់ខ្លួនរបស់ឃុំ និងខេត្ត | | | កំណត់ហេតុរបស់MEFនិងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំរបស់ខេត្តនិងឃុំថ្នាក់ជាតិ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | | | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំពីខេត្ត និងឃុំ | | |
| **លទ្ធផលទី១: ស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ ត្រូវបាន ពង្រឹង ហើយប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព** | | | | | |
| ១. នៅត្រីមាសចុងក្រោយនៃឆ្នាំនីមួយៗ ឃុំទាំងអស់ត្រូវរៀបចំផែនការអភិវឌ្ឍន៍ ឬកម្មវិធីវិនិយោគឃុំ និង ថវិកាប្រចាំឆ្នាំ | | | តារាងទិន្នន័យតាមដានសង្ខេបឃុំនៅថ្នាក់ជាតិ | ធ្វើបច្ចុប្បន្នភាពរៀងរាល់ខែ | ប្រចាំឆ្នាំ |
| | | | តារាងទិន្នន័យតាមដានសង្ខេបរបស់ឃុំ តាមខេត្ត នីមួយៗ | | |
| ២. ភាគរយនៃផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ និង ថវិកាប្រចាំឆ្នាំ ដែលត្រូវបានពិនិត្យលើនីត្យានុកូលភាព ដោយអភិបាលខេត្ត | | | របាយការណ៍សង្ខេបពីវាយតំលៃរបស់ខេត្តលើ CDP/CIP និងថវិកាឃុំ នៅថ្នាក់ជាតិ | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | | | របាយការណ៍វាយតំលៃរបស់ខេត្តលើ CDP/CIP និងថវិកាឃុំ នៅថ្នាក់ជាតិ | | |
| ៣. ខេត្តទាំងអស់ត្រូវបង្កើតផែនការអភិវឌ្ឍន៍ខេត្ត៥ឆ្នាំ និងផែនការវិនិយោគរំកិល៣ឆ្នាំ | | | ឯកសារ PDP និង PIP | PDP រៀងរាល់៥ឆ្នាំម្តង PIP ត្រូវ updateរាល់ឆ្នាំ | ប្រចាំឆ្នាំ |
| ៤. ចំនួនក្រុមប្រឹក្សាឃុំ/បុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនីតិវិធី ព្រមទាំងទំហំនៃវគ្គបណ្តុះបណ្តាល | | | លទ្ធផលសង្ខេបពីតារាងទិន្នន័យតាមដានរបស់ឃុំ នៅថ្នាក់ជាតិ | ធ្វើបច្ចុប្បន្នភាពរាល់ខែ | ប្រចាំត្រីមាស |
| | | | របាយការណ៍បណ្តុះបណ្តាល | ម្តងម្កាល | |
| | | | តារាងទិន្នន័យតាមដានរបស់ឃុំក្នុងខេត្តនីមួយៗ | ធ្វើបច្ចុប្បន្នភាពប្រចាំខែ | |
| | | | របាយការណ៍ឃុំ | ប្រចាំខែ | |

| សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| | | ■ | របាយការណ៍បណ្តុះបណ្តាល | ម្តងម្តាល | ប្រចាំត្រីមាស |
| ៥. ចំនួនបុរស និងស្ត្រីនៅថ្នាក់ស្រុក និងថ្នាក់ខេត្តដែលទទួលបានការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនិតិវិធី ព្រមទាំងទំហំនៃការបណ្តុះបណ្តាល | ■ | | SCD | ធ្វើបច្ចុប្បន្នភាពប្រចាំខែ | ប្រចាំត្រីមាស |
| | ■ | | របាយការណ៍បណ្តុះបណ្តាល | ម្តងម្តាល | |
| | | ■ | SCD | ធ្វើបច្ចុប្បន្នភាពប្រចាំខែ | |
| | | ■ | របាយការណ៍បណ្តុះបណ្តាល | ម្តងម្តាល | |
| ៦. ចំនួនបុរស និងស្ត្រីនៅថ្នាក់ខេត្ត និងស្រុក ដែលបានផ្តល់ការគាំទ្រដល់ឃុំ | ■ | | ការសង្ខេបរបស់ថ្នាក់ជាតិស្តីពីកំរិតបុគ្គលិកគាំទ្រខេត្ត | បច្ចុប្បន្នភាពប្រចាំឆ្នាំ | ប្រចាំត្រីមាស |
| | | ■ | កំរិតគាំទ្របុគ្គលិកថ្នាក់ខេត្ត | បច្ចុប្បន្នភាពប្រចាំត្រីមាស | |
| ៧. ភាពញឹកញាប់នៃការគាំទ្ររបស់ថ្នាក់ខេត្ត ទៅអោយថ្នាក់ឃុំ | ■ | | របាយកាណ៍សង្ខេប ប្រចាំឆ្នាំរបស់ POLA | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | | ■ | របាយការណ៍ព្រចាំឆ្នាំរបស់ POLA និង របាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់ឃុំ | ប្រចាំខែ (ឃុំ)<br>ប្រចាំឆ្នាំ (ខេត្ត) | |
| | | ■ | កំណត់ហេតុទស្សនកិច្ច និងសកម្មភាពគាំទ្ររបស់មន្ត្រីផ្សេងៗរបស់ ExCom | ប្រចាំខែ | |
| ៨. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ការបញ្ជ្រាបយេនឌ័រ | ■ | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | ■ | | PID | បច្ចុប្បន្នភាពប្រចាំត្រីមាស | |
| | | ■ | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា ថ្នាក់ខេត្ត | ប្រចាំឆ្នាំ | |
| | | ■ | PID | បច្ចុប្បន្នភាពប្រចាំខែ | |

| សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| ៩. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| | | | PID | បច្ចុប្បន្នភាពប្រចាំត្រីមាស | |
| | | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា ថ្នាក់ខេត្ត | ប្រចាំឆ្នាំ | |
| | | | PID | បច្ចុប្បន្នភាពប្រចាំត្រីមាស | |
| ១០. ចំនួន និងស្ថានភាពនៃកិច្ចសន្យារបស់ក្រសួង ដែលកំពុងអនុវត្ត | | | SCD | | |
| **លទ្ធផលទី២ : សេវាកម្ម និងការវិនិយោគប្រកប ដោយគុណភាព និងប្រសិទ្ធភាពត្រូវ បានផ្តល់ដើម្បីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន** | | | | | |
| ១. ចំនួន និងស្ថានភាពនៃកិច្ចសន្យា/គំរោងដែលប្រើប្រាស់មូលនិធិឃុំ ដែលកំពុងអនុវត្ត ស្របទៅតាម CDP | | | PID | បច្ចុប្បន្នភាពប្រចាំត្រីមាស | បច្ចុប្បន្នភាពប្រចាំត្រីមាស |
| | | | PID | បច្ចុប្បន្នភាពប្រចាំខែ | |
| ២.ភាគរយនៃការទូរទាត់ចុងក្រោយទៅអោយអ្នកម៉ៅការ ដែលធ្វើគំរោងក្រោមមូលនិធិឃុំ ក្នុងរយៈពេល១២ខែ នៃការអនុម័តលើថវិកាឃុំ | | | PID | បច្ចុប្បន្នភាពប្រចាំត្រីមាស | ប្រចាំឆ្នាំ |
| | | | PID | បច្ចុប្បន្នភាពប្រចាំខែ | |
| ៣.ការវាយតំលៃលើផលប៉ះពាល់របស់គំរោងចាំធំៗ ដែលទទួលមូលនិធិឃុំ | | | ការអង្កេតលើទិន្នន័យបន្ទាត់ផ្សារ ស្តីពី សេដ្ឋកិច្ចសង្គម និងការតាមដានបន្ត | ២០០៣<br>២០០៤, ២០០៦ | ប្រចាំឆ្នាំ |
| ៤. ការវាយតំលៃពីផលប៉ះពាល់របស់គោលនយោបាយវិមជ្ឈការលើជីវភាពយេនឌ័រ និងភាពងាយរងគ្រោះ | | | ការអង្កេតលើទិន្នន័យបន្ទាត់ផ្សារ ស្តីពី សេដ្ឋកិច្ចសង្គម និងការតាមដានបន្ត | ២០០៣<br>២០០៤, ២០០៦ | ពេលអនុវត្ត |
| ៥. ភាគរយនៃគំរោងដែលគាំទ្រដោយមូលនិធិឃុំ ដែលមានគុណភាពបច្ចេកទេសល្អតាមស្តង់ដា | | | សវនកម្មបច្ចេកទេស | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ៦.ការយល់ឃើញរបស់បុរសនិងស្ត្រីបានកើនឡើង លើភាពសមស្រប ទំនាក់ទំនងនិងគុណភាពនៃសេវាកម្មនិងវិនិយោគសំរាប់គំរោងដែលគាំទ្រដោយមូលនិធិឃុំនិងPIF | | | ការស្ទាបស្ទង់ការពេញចិត្តរបស់អ្នកទទួលផល | ២០០៤, ២០០៥ | **ប្រចាំឆ្នាំ** |

| សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | ភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យ | ភាពញឹកញាប់ក្នុងការសរសេររបាយការណ៍សំរាប់កម្មវិធីសិលា |
|---|---|---|---|---|---|
| | | | ការវាយតំលៃលើកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍និង PRDC | ប្រចាំឆ្នាំ | ប្រចាំឆ្នាំ |
| ៧.ចំនួន និងស្ថានភាពនៃកិច្ចសន្យាខេត្តដែលកំពុងអនុវត្ត | | | SCD | បច្ចុប្បន្នភាពប្រចាំត្រីមាស | បច្ចុប្បន្នភាពប្រចាំត្រីមាស |
| | | | SCD | បច្ចុប្បន្នភាពប្រចាំខែ | |
| **លទ្ធផលទី ៣: រួមចំណែកកែលំអគោលនយោបាយជាតិ និងបទបញ្ញត្តិនានាសំរាប់ វិមជ្ឈការ វិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ** | | | | | |
| ១.ប្រសិទ្ធភាពរបស់ប្រព័ន្ធ របនាសម្ព័ន្ធ និងនីតិវិធិ ត្រូវបានធ្វើការកែលំអរជាបន្ត ដោយការពិនិត្យសារឡើងវិញ និងការវាយតំលៃ | | | ពិនិត្យស៊ីជំរៅជាប្រចាំលើការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម ការអនុវត្តន៍ និងប្រព័ន្ធគ្រប់គ្រង | យ៉ាងហោចណាស់ម្តង ក្នុង ១ឆ្នាំ | ប្រចាំឆ្នាំ |
| ២. សិក្ខាសាលាថ្នាក់ជាតិដោយផ្តោតទៅលើការត្រួតពិនិត្យជាទៀងទាត់លើប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការរបស់រដ្ឋាភិបាល និងកម្មវិធីសិលា | | | របាយការណ៍សិក្ខាសាលា | យ៉ាងហោចណាស់ម្តង ក្នុង ១ឆ្នាំ | ប្រចាំឆ្នាំ |
| ៣. បទពិសោធន៍លើវិមជ្ឈការនិងវិសហមជ្ឈការ ដែលបានមកពីកម្មវិធីសិលានោះ បានយកទៅប្រើ សំរាប់បង្កើតគោលនយោបាយថ្នាក់ជាតិ | | | ការវិភាគលើរបាយការណ៍ ប្រកាស កំណត់ហេតុ និងគោលនយោបាយ របស់ក្រសួង និងសន្និសីទ ជាផ្លូវការ របស់មន្ត្រីរដ្ឋាភិបាល | ជាបន្ត | ប្រចាំឆ្នាំ |
| ៤. បទពិសោធន៍របស់កម្មវិធីសិលាលើបញ្ហាអន្តរវិស័យ (ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន និងការបញ្ជ្រាបយេនឌ័រ ) នឹងត្រូវបានលើកឡើងក្នុងគោលនយោបាយ និងការអនុវត្តន៍ | | | សេចក្តីថ្លែងការ របាយការណ៍ប្រជុំ ការសិក្សាវាយតំលៃ | ម្តងម្កាល | ប្រចាំឆ្នាំ |
| ៥. ការសន្ទនាជាយុទ្ធសាស្ត្រលើវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានណែនាំ ដោយពិសោធន៍របស់កម្មវិធីសិលា | | | របាយការណ៍សិក្សាជាយុទ្ធសាស្ត្រ | ២០០៣, ២០០៤, ២០០៥ | ប្រចាំឆ្នាំ |
| | | | របាយការណ៍វេទិកាកម្មវិធីសិលា | យ៉ាងហោចម្តង ក្នុង១ឆ្នាំ | |
| ៦. ចំណេះដឹង អាកប្បកិរិយា ការអនុវត្តន៍ និងជំនឿ បានធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចមូលដ្ឋានល្អ | | | ការអង្កេតលើ KAP និងជំនឿ | ២០០៤, ២០០៦ | ពេលអនុវត្ត |

## ៧.៤. ការប្រើប្រាស់ពត៌មាន និងការធ្វើសេចក្តីសំរេចចិត្ត

នៅទីបញ្ចប់ ជាដំណាក់កាលដ៏សំខាន់បំផុត គឺត្រូវប្រើពត៌មានដែលទទួលបានពីការតាមដាន និងវាយតំលៃ ដើម្បីធ្វើអោយប្រសើរឡើងដល់ការអនុវត្តន៍គំរោងរបស់កម្មវិធីសិលាទាំងមូល។ សេចក្តីសំរេចចិត្ត ត្រូវបានធ្វើឡើង ដោយផ្អែកលើពត៌មាននេះ ដើម្បីធ្វើអោយសំរេចបានគោលដៅ ដែលបានកំណត់នៅក្នុងផែនការ និងដើម្បីកំណត់វិធីសាស្ត្រដោះស្រាយបញ្ហាដែលបានកើតឡើង ដូចជា ការពន្យាពេលក្នុងការអនុវត្តន៍កម្មវិធី ទិសដៅខ្លះ មិនសូវជាមានទំនាក់ទំនង ដូចដែលបានគិតនៅពេលរៀបចំគំរោង ឬបញ្ហាផ្សេងៗទៀត ។ ល។

ក្នុងករណីនីមួយៗ យើងត្រូវតែសំរេចចិត្ត ដែលការសំរេចចិត្តនេះ អាចមានឥទ្ធិពលដល់ផលប៉ះពាល់ និងប្រសិទ្ធភាពរបស់គំរោង ឬកម្មវិធីសិលា។ តើត្រូវធ្វើអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាដែលបានរកឃើញ? តើត្រូវផ្តល់អនុសាសន៍អ្វីខ្លះ ដើម្បីបន្តអនុវត្តគំរោង? ដូចនេះ ជានិច្ចកាល ការធ្វើសេចក្តីសំរេចចិត្ត គឺមិនមែនងាយស្រួលនោះទេ ប៉ុន្តែចំណុចមួយចំនួនដូចខាងក្រោម អាចជួយអោយយើងធ្វើសេចក្តីសំរេចចិត្តបាន :

- ត្រូវកំណត់អោយច្បាស់/រកអោយឃើញបញ្ហាដែលបានកើតឡើង និងមូលហេតុរបស់វា
- ប្រមូល និងគ្រប់គ្រងរាល់ពត៌មានដែលទាក់ទងទាំងអស់ តាមលក្ខណៈជាប្រព័ន្ធ
- កំណត់ដំណោះស្រាយជំរើសមួយចំនួន ដើម្បីដោះស្រាយបញ្ហា
- វាយតំលៃលើដំណោះស្រាយជំរើសទាំងនោះ ដើម្បីយកទៅដោះស្រាយបញ្ហាដែលបានរកឃើញ

ការធ្វើសេចក្តីសំរេចមួយប្រកបដោយគុណភាពល្អ គឺត្រូវធ្វើឡើងតាមរយៈដំណើរការជាជំហានៗ រហូតដល់ចំណុចចុងក្រោយ គឺការជ្រើសរើស ជំរើសមួយដែលប្រសើរបំផុត ក្នុងចំណោមជំរើសជាច្រើន ដើម្បីយកទៅដោះស្រាយ។ ជំហានសំខាន់ៗ ក្នុងដំណើរការនេះ គឺមាននៅក្នុងតារាងទំព័របន្ទាប់។ ជំហាននីមួយៗ ត្រូវបានដាក់នៅផ្នែកខាងលើ ហើយសំនួរសំខាន់ៗ សំរាប់ដំណើរការ និងឧបករណ៍សំរាប់ធ្វើការសំរេចចិត្ត គឺមាននៅខាងក្រោមជំហាននីមួយៗនោះ។

១. **ត្រួតពិនិត្យទិន្នន័យ ផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតំលៃ** : នៅពេលធ្វើការវាយតំលៃ ទិន្នន័យដែលបានប្រមូល យ៉ាងហោចណាស់ គួរតែអាចឆ្លើយតបទៅនឹងសំនួរមួយចំនួន ដូចខាងក្រោម :

- តើគំរោងមានប្រសិទ្ធភាពដែរឺទេ? (តើគំរោងបានសំរេចអ្វីដែលវាត្រូវធ្វើដែរឺទេ?)
- តើគំរោងមានសមត្ថភាពដែរឺទេ? (តើគំរោងសំរេចបានលទ្ធផលរំពឹងទុក ក្នុងការចំណាយមួយសមស្របដែរឺទេ?)
- តើគំរោងធានាបាន ចីរភាពដែរឺទេ?
- តើមានហេតុបច្ច័យអ្វីខ្លះ ដែលមិនបានគិតទុកជាមុនដែរឺទេ? (វិជ្ជមាន ឬ អវិជ្ជមាន?)
- តើការពិចារណាជាដំបូង (ការសន្មត់) សំរាប់លើកគំរោង នៅតែមានសុពលភាពឬ?
- តើគំរោងបច្ចុប្បន្ន គឺជាវិធីសាស្រ្តមួយដ៏ល្អបំផុត ដែលត្រូវតែអនុវត្តបន្តឬ?
- តើគំរោងនេះ មានផលប៉ះពាល់អ្វីខ្លះ ដល់បរិស្ថាន?
- តើវាមានភាពរំញោចដល់បញ្ហា ដែលទាក់ទងនឹងយេនឌ័រដែររឺទេ?

សំរាប់ការតាមដាន ជំហាននេះ គឺវាងាយស្រួលបំពេញណាស់។ របាយការណ៍តាមដាន នឹងបង្ហាញនូវបញ្ហាផ្ទាល់ៗ ដែលទាក់ទងនឹងការអនុវត្តន៍សកម្មភាព ហើយគេអាចឈានចូលជំហានទី២ (ឬជំហានទី៣ ) បានភ្លាមៗតែម្តង។

| | ជំហានទី១ | ជំហានទី២ | ជំហានទី៣ | ជំហានទី៤ | ជំហានទី៥ |
|---|---|---|---|---|---|
| គោលបំណង | ត្រួតពិនិត្យទិន្នន័យដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតំលៃ | កំណត់បញ្ហាសំខាន់ៗ និងមូលហេតុរបស់វា | បង្កើតដំណោះស្រាយជាជំរើស | កំណត់លក្ខណៈវិនិច្ឆ័យជ្រើសរើសជំរើស | អនុវត្តដំណោះស្រាយវាយតំលៃលើលទ្ធផល |
| សំនួរសំខាន់ៗ | តើវា .....<br>● មានប្រសិទ្ធភាព?<br>● មានសមត្ថភាព?<br>● មានចីរភាព?<br><br>តើអ្វីខ្លះជា ...<br>● ផលប៉ះពាល់លើបរិស្ថាន?<br>● ហេតុបច្ច័យដែលមិនបានគិតទុកជាមុន? | <u>ហេតុអ្វី?</u><br>(តើអ្វីខ្លះជាមូលហេតុនៃបញ្ហាទាំងនេះ?) | តើអ្វីខ្លះជាជំរើស? | ● ចំណាយ<br>● ភាពដែលអាចធ្វើបាន<br>● ប្រសិទ្ធភាព<br>● ពេលវេលា<br>● ការចូលរួម<br>● ...(ផ្សេងៗ) | តើដំណោះស្រាយនេះអាចដោះស្រាយបញ្ហាបានដែរឬទេ? |
| ឧបករណ៍ | ● ការវិភាគពី SWOT<br>● ការវិភាគពីនិន្នាការ<br>● ការវិភាគលើ KAP<br>● អោយចំណាត់ថ្នាក់ និងអោយពិន្ទុ<br>● ការវិភាគលើចំណាយ និងប្រយោជន៍ | ● មែកធាងបញ្ហា<br>● លំហាត់ " ប៉ុន្តែ ហេតុអ្វី? " | ● ការពិភាក្សារួមគ្នា | ● ពិភាក្សារួមគ្នា<br>● ដាក់ពិន្ទុ<br>● អោយចំណាត់ថ្នាក់ | ● ការតាមដាន<br>● ការប្រមូលទិន្នន័យ |

## ២. កំណត់បញ្ហាសំខាន់ៗ និងមូលហេតុដែលអាចធ្វើអោយមានបញ្ហានោះ

ការត្រួតពិនិត្យលើទិន្នន័យ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់មួយចំនួន គឺតែងតែអាចធ្វើអោយយើងអាចយល់ដឹងបានកាន់តែច្បាស់ពីបញ្ហាជាក់លាក់មួយចំនួននោះ។ ត្រូវសំរេចចិត្តថាតើបញ្ហាណាខ្លះ ដែលពិតជាសំខាន់បំផុត បន្ទាប់មកត្រូវវិភាគវាបន្តទៀត។ ការខកខានមិនបានកំណត់អោយបានច្បាស់ពីមូលហេតុពិតប្រាកដរបស់បញ្ហាសំខាន់ៗ គឺតែងតែធ្វើអោយការសំរេចចិត្ត ពីដំណោះស្រាយមិនបានល្អ ឬក៏អាចនាំអោយមានការសន្និដ្ឋាន មិនសមស្របផងដែរ។

ការស្វែងរកមូលហេតុ ជួនកាលមានន័យថា ជាការប្រមូលពត៌មានបន្ថែម។ បញ្ហាខ្លះ គឺមានមូលហេតុច្បាស់លាស់ ប៉ុន្តែបញ្ហាខ្លះទៀត ក៏មិនមែនងាយស្រួល ក្នុងការកំណត់អោយបានច្បាស់ពីមូលហេតុរបស់វាទេ ហើយជួនកាល ដើម្បីដឹងអោយបានច្បាស់ពីមូលហេតុរបស់វា យើងត្រូវបង្កើតសំនួរស្រាវជ្រាវបន្ថែមទៀត ឬក៏ត្រូវប្រមូលហេតុការណ៍ គំនិត និងទស្សនៈផ្សេងៗបន្ថែមទៀតពីបុគ្គលិកគំរោង និងមនុស្សផ្សេងៗទៀត។ មែកធាងបញ្ហា (problem trees) គឺជាឧបករណ៍មួយដ៏មានប្រយោជន៍ សំរាប់ការវិភាគលើមូលហេតុរបស់បញ្ហាមួយចំនួន។

លទ្ធផលរបស់ជំហានទី១ និងទី២ គួរតែត្រូវបានលើកឡើងក្នុងរបាយការណ៍វាយតំលៃ នៅក្នុងជំពូក " សន្និដ្ឋាន "។

## ៣. បង្កើតដំណោះស្រាយ ជាជំរើស

នៅពេលដែលមូលហេតុរបស់បញ្ហា ត្រូវបានរកឃើញហើយនោះ ត្រូវស្វែងរកដំណោះស្រាយរបស់បញ្ហា។ ត្រូវពិនិត្យមើលជារួម ដោយប្រុងប្រយ័ត្នលើពត៌មានដែលមាន និងសិក្សាមើល ថាតើពត៌មានផ្សេងៗគ្នាទាំងនោះ វាមានទំនាក់ទំនងគ្នាបែបណា។ ជាងនេះទៅទៀត ត្រូវប្រើបទពិសោធន៍ គំនិតច្នៃប្រឌិត និងការយល់ដឹងផ្ទាល់ខ្លួន ដើម្បីបង្កើតបញ្ជីជំរើសមួយ (សំរាប់បញ្ហាទាំងអស់) ជាឧទាហរណ៍ ដោយប្រើវិធីសាស្ត្រពិភាក្សារួមគ្នា។

ការចំណាយពេល ដើម្បីវិភាគពីបញ្ហា និងការស្វែងរកដំណោះស្រាយផ្សេងៗគ្នា អាចបង្កើតឱកាសក្នុងការរកឃើញដំណោះស្រាយល្អៗ ដែលពិតជាអាចដោះស្រាយបញ្ហាបាន នៅទីបំផុត។ ដំណោះស្រាយបែបនេះ គឺមានគុណភាព និងប្រសិទ្ធភាពខ្លាំងណាស់ ក្នុងការដោះស្រាយបញ្ហា សំរាប់រយៈពេលយូរអង្វែង។

## ៤. កំណត់លក្ខណៈវិនិច្ឆ័យ និងជ្រើសរើសជំរើស

ក្នុងចំណោមជំរើសទាំងឡាយ ត្រូវសិក្សាមើលថាតើ ជំរើសណាមួយដែលល្អបំផុត។ សូមចុះបញ្ជីនូវជំរើសណាដែលល្អ និងជំរើសណាដែលមិនល្អ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជាការចំណាយ ភាពងាយស្រួលក្នុងការអនុវត្តន៍ ឬកំរិតចូលរួមរបស់អ្នកទទួលផលពីគំរោង។ល។ សូមអោយមុឹងម៉ាត់សំរាប់ ជំរើសនីមួយៗ។

ត្រូវត្រួតពិនិត្យលើជំរើសទាំងឡាយ ដែលមានលក្ខណៈបែបបច្ចេកទេស ឬ ភាពដែលអាចធ្វើបានរបស់វា (បន្ថែមលើលក្ខណៈវិនិច្ឆ័យសំខាន់ៗផ្សេងៗទៀត)។ ក្នុងការវាយតំលៃ ការអោយចំណាត់ថ្នាក់លើប្រយោជន៍របស់អនុសាសន៍ គឺជារឿយៗ (តែមិនមែនជានិច្ចកាលនោះទេ) ជាបន្ទុករបស់អ្នកអនុវត្តន៍គំរោង មិនមែនអ្នកវាយតំលៃទេ។ សំរាប់ការតាមដាន សំខាន់ណាស់ ដែលត្រូវអនុវត្តតាមដំណើរការនេះ តាំងពីចាប់ផ្តើមរហូតដល់ចប់ ដូចនេះ ការសំរេចអាចត្រូវបានធ្វើឡើង ដើម្បីធ្វើអោយប្រសើរឡើងដោយផ្ទាល់ សំរាប់ការអនុវត្តន៍គំរោង។

ជំហានទី៣ និងជំហានទី៤ អាចត្រូវបានធ្វើឡើងយ៉ាងល្អ ជាមួយនឹងក្រុមមនុស្សជាច្រើន។ ការអនុវត្តន៍តាមដំណើរការបែបចូលរួម មិនត្រឹមតែអាចធ្វើអោយដំណោះស្រាយដែលបានលើកឡើងទទួលបានការគាំទ្រពីមនុស្សគ្រប់គ្នានោះទេ តែវាក៏អាចធ្វើអោយដំណោះស្រាយនោះ ល្អបំផុតផងដែរ (ទោះបីជាដំណោះស្រាយ ត្រូវអាស្រ័យទៅលើសារជាតិរបស់បញ្ហានីមួយៗក៏ដោយ)។ ជាសត្យានុម័ត មនុស្ស២នាក់ អាចយល់ដឹងបានច្រើនជាងមនុស្សម្នាក់ ហើយមនុស្ស១០នាក់ អាចដឹងបានច្រើនជាងមនុស្ស២នាក់។ ដូចនេះ ជាការប្រសើរ បើសិនជាធ្វើការសំរេចចិត្តអ្វីមួយដែលសំខាន់ ចាំបាច់សូមអោយសមាជិកក្រុមទាំងអស់ បានចូលរួមក្នុងដំណើរការសំរេចចិត្តនោះ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១:

| ចំណាត់ថ្នាក់ទិសដៅ | សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| **គោលដៅ :** រួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈអភិបាលកិច្ចល្អ | ១. ការកាត់បន្ថយលើកំរិតភាពក្រីក្រនៅថ្នាក់ជាតិ<br>២.ការកាត់បន្ថយភាពខុសគ្នានៃកំរិតក្រីក្ររវាងបុរស និងស្ត្រី | | | កម្មវិធី មិនមានគោលបំណងជាពិសេសក្នុងការតាមដាន និងវាយតំលៃលើការចូលរួមរបស់ខ្លួនក្នុងការកាត់បន្ថយភាពក្រីក្រទេ។ ការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា នឹងត្រូវបានតាមដាននិង វាយតំលៃដោយភាគីផ្សេងៗ។ | | |
| **ទិសដៅ:** រៀបចំប្រព័ន្ធ និងយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការនានា ដើម្បីគ្រប់គ្រងកិច្ចអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយចីរភាព | ១.បទពិសោធន៍ខាងវិមជ្ឈការនិងវិសហមជ្ឈការរបស់កម្មវិធីសិលា ត្រូវ បានលើកឡើងនៅក្នុងលិខិតគតិយុត្តិផ្សេងៗ | | | ច្បាប់ ប្រកាស ក្រឹត្យ អនុក្រឹត្យ គោលការណ៍ណែនាំ។ល។ | STFS | ប្រមូលនិងរៀបចំឯកសារលើការចូលរួមរបស់កម្មវិធីសិលា |
| | ២.ប្រពន្ធ័កសាងផែនការរៀបចំថវិកា លទ្ធកម្មនិងការអនុវត្តន៍គំរោងនានា ដែលទទួលការគាំទ្រពីមូលនិធិឃុំ និងរបាយការណ៍តាមបែបវិមជ្ឈការ ត្រូវបានអនុវត្តនៅគ្រប់ឃុំ។ | | | តារាងទិន្នន័យតាមដានសង្ខេប ស្តីពីការអនុវត្តន៍របស់ឃុំនៅថ្នាក់ជាតិ | DoLA (ផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិង ដាក់បញ្ចូលទៅក្នុងតារាងតាមដាន។ ថ្នាក់ជាតិត្រូវធ្វើការសង្ខេប ដោយប្រើ តារាងទិន្នន័យទាំងនេះ។ |
| | | | | តារាងតាមដានការអនុវត្តន៍របស់ឃុំ នៅក្នុងខេត្តនីមួយៗ | POLA | ទិន្នន័យត្រូវបានប្រមូល និងបញ្ចូលក្នុងតារាងទិន្នន័យ |
| | ៣.ប្រពន្ធ័ និងរចនាសម្ព័ន្ធគាំទ្រដល់ការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម និងការអនុវត្តន៍គំរោងមូលនិធិឃុំ ព្រមទាំងរបាយការណ៍តាមបែប វិមជ្ឈការ ក៏ត្រូវបានអនុវត្តនៅគ្រប់ខេត្ត។ | | | របាយការណ៍របស់ក្រសួងស្តីពីការអនុវត្តន៍វិមជ្ឈការ | PMEU(ផ្អែកលើរបាយការណ៍ពី MoP, MEF, MoI,MRD,និងNCSC) | របាយការណ៍ប្រចាំឆ្នាំ និង របាយការណ៍ប្លង់ម្កាល |
| | | | | របាយការណ៍ពីភ្នាក់ងារថ្នាក់ខេត្ត | មន្ទីរខេត្ត និងអង្គភាពរបស់ ExCom | ការពិនិត្យប្រហាណ និងរបាយការណ៍ |
| | ៤. ការឆ្លើយតបតាមតំរូវការនៃអាទិភាពដែលបាន កំណត់នៅក្នុងផែនការ អភិវឌ្ឍន៍ឃុំ បានកើនឡើងប្រចាំឆ្នាំ តាមរយៈកិច្ចសន្យាបណ្តោះអាសន្ន។ | | | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | PMEU | ការចងក្រងនូវរាល់លទ្ធផលរបស់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក របស់គ្រប់ខេត្តក្រុង |
| | | | | លទ្ធផលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក | មន្ទីរផែនការ | ភាគរយនៃសំណើរបស់ឃុំ ដែលទទួលបានការឆ្លើយតបជាវិជ្ជមាន |

| ឋានានុក្រមគោលដៅ | សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| | ៥.ចំនួនកិច្ចសន្យាបណ្ណោះអាសន្ន ដែលបានចុះហត្ថលេខាដោយមន្ទីរ និង NGO ជាមួយឃុំនៅឯសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក មានការកើនឡើង។ | | | លទ្ធផលសង្ខេបសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក នៅថ្នាក់ជាតិ | PMEU | ការចងក្រងនូវរាល់លទ្ធផលរបស់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក របស់គ្រប់ខេត្តក្រុង |
| | | | | លទ្ធផលសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក | មន្ទីរផែនការ | ចំនួន TA ដែលបានចុះហត្ថលេខា |
| | ៦. ចំនួនស្ត្រីដែលមានតំណែងជាអ្នកដឹកនាំ នៅថ្នាក់ឃុំ និងនៅថ្នាក់ខេត្ត មានការកើនឡើង | | | ចំនួនសរុបនៃស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ និងដែលជាសមាជិក PBC នៅថ្នាក់ជាតិ។ | DoLA (ដោយផ្អែក លើពត៌មានពី POLA) | ចងក្រងទិន្នន័យដែលបានប្រមូលនៅគ្រប់ខេត្ត |
| | | | | ចំនួនស្ត្រីសង្ខេបសរុប ដែលមាននៅ ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និង ថ្នាក់ខេត្ត | POU | កំណត់ហេតុរបស់បុគ្គលិកកម្មវិធីសិលា |
| | | | | ចំនួនស្ត្រីដែលជាសមាជិកក្រុមប្រឹក្សាឃុំ និងដែល ជាសមាជិក PBC | POLA | ពីរបាយការណ៍ឃុំ និងពត៌មានប្រមូលដោយ DFT |
| | | | | ចំនួនស្ត្រីដែលមាននៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត | អង្គភាព FU និង CAU របស់ ExCom | កំណត់ហេតុរបស់បុគ្គលិកកម្មវិធីសិលា |
| | ៧. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយមូលនិធិឃុំ | | | ការសំរេចចិត្តរបស់ MEF លើការចូលរួមរបស់រដ្ឋាភិបាលក្នុងមូលនិធិឃុំ | MEF និងគណៈកម្មាធិការមូលនិធិឃុំ | ប្រកាសប្រចាំឆ្នាំស្តីពីការចូលរួមរបស់រដ្ឋាភិបាល ក្នុងមូលនិធិឃុំ |
| | ៨.ចំណូលបុគ្គលជាមធ្យម ត្រូវបានផ្ទេរតាមរយៈមូលនិធិឃុំ | | | ការវិភាជន៍របស់មូលនិធិឃុំ និងតួលេខប្រជាពលរដ្ឋរបស់ឃុំ | MEF និង MoP | អត្រានៃការវិភាជន៍មូលនិធិឃុំ និងចំនួនប្រជាពលរដ្ឋសរុប |
| | ៩. ធនធានថវិកាជាតិ ត្រូវបានវិភាជទៅអោយខេត្ត សំរាប់ជាទុន ដើម្បីយកទៅអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ | | | ការសំរេចចិត្តរបស់ MEF លើការចូលរួមរបស់រដ្ឋាភិបាលក្នុងការគាំទ្រ ដល់ការវិនិយោគខេត្តតាមរយៈវិសហមជ្ឈការ | MEF | ប្រកាសរបស់ MEF |
| | ១០.ចំណូលបុគ្គលជាមធ្យមត្រូវបានផ្ទេរតាមរយៈ PIF ដោយខេត្តនីមួយៗ | | | ការវិភាជន៍របស់ PIF និងតួលេខសរុបនៃប្រជាពលរដ្ឋក្នុងខេត្ត | POU | អត្រា PIF និងចំនួនប្រជាពលរដ្ឋក្នុងខេត្តនីមួយៗ |
| | ១១.ចំនួនធនធានដែលបានគ្រប់គ្រងប្រចាំឆ្នាំដោយរាជធានី/ខេត្តដែលប្រើ ប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ ដែលកម្មវិធីសិលាបានបង្កើតឡើង | | | របាយការណ៍ពី MEF និងម្ចាស់ជំនួយ | MEF និងម្ចាស់ជំនួយ | ប្រកាស កំណត់ហេតុ និងការព្រាស្រ័យទាក់ទងគ្នា |

| ជំនាន់ក្រុមគោលដៅ | សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| | | | | របាយការណ៍ពីរាជធានីខេត្ត | មន្ទីរខេត្ត | ប្រកាស កំណត់ហេតុ និងការប្រាស្រ័យទាក់ទងគ្នា |
| | ១២. ចំណូលផ្ទាល់ខ្លួនរបស់ឃុំ និងខេត្ត | | | កំណត់ហេតុរបស់MEFនិងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបប្រចាំឆ្នាំរបស់ខេត្តនិងឃុំថ្នាក់ជាតិ | MEF និងរាជធានីខេត្ត | ប្រកាស កំណត់ហេតុ និងការប្រាស្រ័យទាក់ទងគ្នា |
| | | | | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំពីខេត្ត និងឃុំ | រតនាគារ និងមន្ទីរខេត្ត | របាយការណ៍ប្រចាំឆ្នាំ ប្រកាស កំណត់ ហេតុនិងការប្រាស្រ័យគ្នា |
| **លទ្ធផលទី១:** ស្ថាប័នពាក់ព័ន្ធគ្រប់ថ្នាក់ ត្រូវបានពង្រឹង ហើយប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុវត្តន៍ ប្រកបដោយប្រសិទ្ធិភាព | ១. នៅត្រីមាសចុងក្រោយនៃឆ្នាំនីមួយៗ ឃុំទាំងអស់ត្រូវរៀបចំផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគឃុំ និងថវិកាប្រចាំឆ្នាំ | | | តារាងទិន្នន័យតាមដានសង្ខេបឃុំនៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិងដាក់បញ្ចូលទៅក្នុង តារាងតាមដាន។ ថ្នាក់ជាតិត្រូវធ្វើការសង្ខេប ដោយប្រើតារាងទិន្នន័យទាំងនេះ។ |
| | | | | តារាងទិន្នន័យតាមដានសង្ខេបរបស់ឃុំ តាមខេត្ត នីមួយៗ | POLA | ទិន្នន័យត្រូវបានប្រមូល និងបញ្ចូលក្នុងតារាងទិន្នន័យក្នុងខេត្តនីមួយៗ |
| | ២. ភាគរយនៃផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគឃុំ និង ថវិកាប្រចាំឆ្នាំ ដែលត្រូវបានពិនិត្យលើនីត្យានុកូលភាពដោយអភិបាលខេត្ត | | | របាយការណ៍សង្ខេបពីវាយតំលៃរបស់ខេត្តលើ CDP/CIP និងថវិកាឃុំ នៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ការវាយតំលៃលើ CDP/CIP និងថវិកាឃុំ |
| | | | | របាយការណ៍វាយតំលៃរបស់ខេត្តលើ CDP/CIP និងថវិកាឃុំ | POLA , PDoEF | ការវាយតំលៃលើ CDP/CIP និងថវិកាឃុំ |
| | ៣.ខេត្តទាំងអស់ត្រូវបង្កើតផែនការអភិវឌ្ឍន៍ខេត្ត៥ឆ្នាំ និងផែនការវិនិយោគរំកិល៣ឆ្នាំ | | | ឯកសារ PDP និង PIP | PDoP | វាយតំលៃលើឯកសារគោលផែនការ |
| | ៤. ចំនួនក្រុមប្រឹក្សាឃុំ/បុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនីតិវិធី ព្រមទាំងទំហំនៃវគ្គបណ្តុះបណ្តាល | | | លទ្ធផលសង្ខេបពីតារាងទិន្នន័យតាមដានរបស់ឃុំ នៅថ្នាក់ជាតិ | DoLA (ដោយផ្អែកលើពត៌មានពី POLA) | ខេត្តនីមួយៗប្រមូលទិន្នន័យនិងដាក់បញ្ចូលទៅក្នុង តារាងតាមដាន។ ថ្នាក់ជាតិត្រូវធ្វើការសង្ខេបដោយប្រើតារាងទិន្នន័យទាំងនេះ។ |
| | | | | របាយការណ៍បណ្តុះបណ្តាល | POU (ផ្អែកលើពត៌មានពី MoP, MEF, MoI, MRD, NCSC) | របាយការណ៍បណ្តុះបណ្តាល |

| ចំណាត់ក្រុមទិសដៅ | សូចនាករសំខាន់ៗ | ថ្នាក់ ជាតិ | ថ្នាក់ ខេត្ត | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| | | | | តារាងទិន្នន័យតាមដានរបស់ឃុំក្នុងខេត្តនីមួយៗ | POLA | ទិន្នន័យត្រូវបានប្រមូល និងបញ្ចូលក្នុងតារាងទិន្នន័យក្នុងខេត្តនីមួយៗ |
| | | | | របាយការណ៍ឃុំ | POLA | ផ្នែកកសាងសមត្ថភាពក្នុងរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំរបស់ឃុំ |
| | | | | របាយការណ៍បណ្តុះបណ្តាល | POLA មន្ទីរខេត្ត និង អង្គភាព របស់ ExCom | របាយការណ៍ |
| | ៥. ចំនួនបុរស និងស្ត្រីនៅថ្នាក់ស្រុក និងថ្នាក់ខេត្តដែលបានទទួលការបណ្តុះបណ្តាលលើទស្សនទាន ប្រព័ន្ធ និងនីតិវិធី ព្រមទាំងទំហំនៃការ បណ្តុះបណ្តាល | | | SCD | POU | សៀវភៅណែនាំ SCD |
| | | | | របាយការណ៍បណ្តុះបណ្តាល | POU (ផ្អែកលើពត៌មានពី MoP, MEF, MoI, MRD, NCSC) | របាយការណ៍ |
| | | | | SCD | អង្គភាព CAU របស់ ExCom | សៀវភៅណែនាំ SCD |
| | | | | របាយការណ៍បណ្តុះបណ្តាល | POLA មន្ទីរខេត្ត និង អង្គភាព របស់ ExCom | របាយការណ៍ |
| | ៦. ចំនួនបុរស និងស្ត្រីនៅថ្នាក់ខេត្ត និងស្រុកដែលបានផ្តល់ការគាំទ្រ ដល់ឃុំ | | | ការសង្ខេបរបស់ថ្នាក់ជាតិស្តីពីកិច្ចការបុគ្គលិក គាំទ្រខេត្ត | POU | កំណត់ហេតុបុគ្គលិក |
| | | | | កិច្ចការបុគ្គលិក គាំទ្រខេត្ត | អង្គភាព របស់ ExCom | កំណត់ហេតុបុគ្គលិក |
| | ៧. ភាពញឹកញាប់នៃការគាំទ្ររបស់ថ្នាក់ខេត្តទៅអោយថ្នាក់ឃុំ | | | របាយការណ៍សង្ខេប ប្រចាំឆ្នាំរបស់ POLA | DoLA (ដោយផ្អែកលើពត៌មានពី POLA) | របាយការណ៍ប្រចាំឆ្នាំរបស់ POLA |
| | | | | របាយការណ៍ប្រចាំឆ្នាំរបស់ POLA និងប្រចាំខែ ប្រចាំឆ្នាំរបស់ឃុំ | POLA | ផ្នែកទស្សនកិច្ចគាំទ្រដល់ឃុំ |
| | | | | កំណត់ហេតុនៃទស្សនកិច្ច និងសកម្មភាពគាំទ្ររបស់មន្ត្រីអង្គភាព ExCom | អង្គភាព ExCom | របាយការណ៍សកម្មភាព |
| | ៨. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ ការបញ្ជ្រាបយេនឌ័រ | | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា | POU | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធី សិលា ដែលបានរៀបចំ |

| ឋានានុក្រមនិងគោលដៅ | សូចនាករសំខាន់ៗ | ថ្នាក់ | | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| | | ជាតិ | ខេត្ត | | | |
| | | | | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| | | | | ផែនការសកម្មភាពនិងថវិកាកម្មវិធីសិលាខេត្ត | PRDC | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធី សិលា ដែលបានរៀបចំ |
| | | | | PID | PRDC ExCom TUS | សូមមើលសៀវភៅណែនាំ PID |
| | ៩. ធនធានដែលបានកៀងគរនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ឃុំ សំរាប់ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន | | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលា | POU | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធីសិលា ដែលបានរៀបចំ |
| | | | | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| | | | | ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ របស់កម្មវិធីសិលាខេត្ត | PRDC | តាមទំរង់បែបបទ និងដំណើរការរបស់កម្មវិធីសិលា ដែលបានរៀបចំ |
| | | | | PID | PRDC ExCom TUS | សូមមើលសៀវភៅណែនាំ PID |
| | ១០. ចំនួន និងស្ថានភាពនៃកិច្ចសន្យារបស់ក្រសួង ដែលកំពុងអនុវត្ត | | | SCD | POU | សៀវភៅណែនាំ SCD |
| **លទ្ធផលទី២ :** សេវាកម្ម និងការវិនិយោគប្រកបដោយ គុណភាព និងប្រសិទ្ធភាពត្រូវ បានផ្តល់ ដើម្បីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន | ១. ចំនួន និងស្ថានភាពនៃកិច្ចសន្យា/គំរោងដែលប្រើប្រាស់មូលនិធិឃុំ ដែលកំពុងអនុវត្ត ស្របទៅតាម CDP | | | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |

| ឋានានុក្រមនិសរដេរ | សូចនាករសំខាន់ៗ | ថ្នាក់ | | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | ឯកសារយោង |
|---|---|---|---|---|---|---|
| | | ជាតិ | ខេត្ត | | | |
| | | | | PID | PRDC ExCom TUS | សូមមើលសៀវភៅណែនាំ PID |
| | ២.ភាគរយនៃការទូរទាត់ចុងក្រោយទៅអោយអ្នកម៉ៅការដែលធ្វើគំរោង ក្រោមមូលនិធិឃុំ ក្នុងរយៈពេល១២ខែនៃការអនុម័តលើថវិកាឃុំ | | | PID | POU (ផ្អែកលើទិន្នន័យក្រុមប្រឹក្សាឃុំផ្តល់អោយ និងទិន្នន័យដែល TSU បានបញ្ចូលក្នុង PID) | សូមមើលសៀវភៅណែនាំ PID |
| | | | | PID | PRDC ExCom TUS | សូមមើលសៀវភៅណែនាំ PID |
| | ៣. ការវាយតំលៃលើផលប៉ះពាល់របស់គំរោងចាំនគំរូដែលទទួលមូលនិធិឃុំ | | | ការអង្កេតលើទិន្នន័យបន្ទាត់ដ្ឋាន ស្តីពី សេដ្ឋកិច្ចសង្គម និងការតាមដានបន្ត | PMEU | របាយការណ៍អង្កេត |
| | ៤. ការវាយតំលៃពីផលប៉ះពាល់របស់គោលនយោបាយវិមជ្ឈការលើ ជីវភាព យេនឌ័រ និងភាពងាយរងគ្រោះ | | | ការអង្កេតលើទិន្នន័យបន្ទាត់ដ្ឋាន ស្តីពី សេដ្ឋកិច្ចសង្គម និងការតាមដានបន្ត | PMEU | របាយការណ៍អង្កេត |
| | ៥. ភាគរយនៃគំរោងដែលគាំទ្រដោយមូលនិធិឃុំដែលមានគុណភាព បច្ចេកទេសល្អតាមស្តង់ដា | | | សវនកម្មបច្ចេកទេស | STFS | សូមមើលសៀវភៅណែនាំ PID |
| | | | | សវនកម្មបច្ចេកទេស | PRDC ExCom TUS | សូមមើលសៀវភៅណែនាំអនុវត្តគំរោង |
| | ៦.ការយល់ដឹងរបស់បុរសនិងស្ត្រីបានកើនឡើង លើភាពសមស្រប ទំនាក់ទំនងនិងគុណភាពនៃសេវាកម្ម និងវិធិយោគសំរាប់គំរោងដែលគាំទ្រដោយមូលនិធិឃុំ និង PIF | | | ការអង្កេតលើការពេញចិត្តរបស់អ្នក ទទួលផល | PMEU | កំណត់តាមក្រោយ |
| | | | | ការវាយតំលៃលើកិច្ចសន្យារបស់ភ្នាក់ងារអនុវត្តន៍ និង PRDC | ភ្នាក់ងារអនុវត្តន៍ និង PRDC | ការវាយតំលៃបញ្ចប់កិច្ចសន្យា |
| | ៧.ចំនួន និងស្ថានភាពនៃកិច្ចសន្យាខេត្តដែលកំពុងអនុវត្ត | | | SCD | POU | សូមមើលសៀវភៅណែនាំ SCD |
| | | | | SCD | PRDC ExCom CAU | សូមមើលសៀវភៅណែនាំ SCD |
| **លទ្ធផលទី ៣:** រួមចំណែកកែលំអគោលនយោបាយជាតិ និងបទបញ្ញត្តិនានាសំរាប់ វិមជ្ឈការ វិសហមជ្ឈការ និងការកាត់បន្ថយភាពក្រីក្រ | ១.ប្រព័ន្ធ របនាសម្ព័ន្ធ និងនីតិវិធិ ត្រូវបានធ្វើការកែលំអប្រសិទ្ធភាពជាបន្ត ដោយការពិនិត្យសារឡើងវិញ និងការវាយតំលៃ | | | ការពិនិត្យស៊ីជំរៅជាប្រចាំលើការកសាងផែនការ ការរៀបចំថវិកា លទ្ធកម្ម ការអនុវត្តន៍ និងប្រព័ន្ធគ្រប់គ្រង | STFS | ការវាយតំលៃនិងវិភាគលើប្រព័ន្ធ |

| ផែនការក្រុមនិយោជិត | សូចនាករសំខាន់ៗ | ថ្នាក់ | | មធ្យោបាយផ្ទៀងផ្ទាត់ជាក់លាក់ | អ្នកទទួលខុសត្រូវ | វិធីសាស្ត្រ |
|---|---|---|---|---|---|---|
| | | ជាតិ | ខេត្ត | | | |
| | ២. សិក្ខាសាលាថ្នាក់ជាតិដោយផ្តោតទៅលើការត្រួតពិនិត្យជាទៀងទាត់ លើប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការរបស់រដ្ឋាភិបាល និងកម្មវិធីសិលា | | | របាយការណ៍សិក្ខាសាលា | STFS | ការវិភាគលើរបាយការណ៍ |
| | ៣. បទពិសោធន៍លើវិមជ្ឈការនិងវិសហមជ្ឈការដែលបានមកពីកម្មវិធីសិលានោះ បានយកទៅប្រើ សំរាប់បង្កើតគោលនយោបាយថ្នាក់ជាតិ | | | ការវិភាគលើរបាយការណ៍ ប្រកាស កំណត់ហេតុនិងគោលនយោបាយ របស់ក្រសួង និងសន្ទរកថា ជាផ្លូវការ របស់មន្ត្រីរដ្ឋាភិបាល | PMEU | ការវិភាគលើឯកសារ |
| | ៤. បទពិសោធន៍របស់កម្មវិធីសិលាលើបញ្ហាអន្តរវិស័យ (ការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងការបញ្រ្ជាប យេនឌ័រ ) នឹងត្រូវបានលើកឡើងក្នុងគោលនយោបាយ និងការអនុវត្តន៍ | | | សេចក្តីថ្លែងការ របាយការណ៍ប្រជុំ ការសិក្សាវាយតំលៃ | PMEU | ការត្រួតពិនិត្យឡើងវិញ |
| | ៥.ការសន្ទនាជាយុទ្ធសាស្ត្រលើវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានណែនាំដោយពិសោធន៍របស់កម្មវិធីសិលា | | | របាយការណ៍សិក្សាជាយុទ្ធសាស្ត្រ | PMEU | ការវិភាគលើរបាយការណ៍ |
| | | | | របាយការណ៍វេទិកាកម្មវិធីសិលា | STFS | ការវិភាគលើរបាយការណ៍ |
| | ៦. ចំណេះដឹង អាកប្បកិរិយា ការអនុវត្តណ៍ និងជំនឿបានធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ចមូលដ្ឋានល្អ | | | ការអង្កេតលើ KAP និងជំនឿ | PMEU | ការសិក្សា និងការអង្កេត |